# ក

# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


១៦-៦-២០០៦ -ព្រះរាជក្រម នស/រកម/០៦០៦/០១៤ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញាបាសែល ស្តីពីការត្រួតពិនិត្យចលនាដឹកជញ្ជូន និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែន ៤២៨៥


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


២៧-៦-២០០៦ -អនុក្រឹត្យលេខ ៦០ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៤៣៥៧

២៩-៦-២០០៦ -អនុក្រឹត្យលេខ ៦១ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជា ៤៣៥៩

២៧-៦-២០០៦ -អនុក្រឹត្យលេខ ៤៤០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៣៦២

២៧-៦-២០០៦ -អនុក្រឹត្យលេខ ៤៤១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៣៦៣

២៧-៦-២០០៦ -អនុក្រឹត្យលេខ ៤៤២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៣៦៤

២៨-៦-២០០៦ -អនុក្រឹត្យលេខ ៤៤៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៣៦៥

២៨-៦-២០០៦ -អនុក្រឹត្យលេខ ៤៤៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៤៣៦៦

២៨-៦-២០០៦ -អនុក្រឹត្យលេខ ៤៤៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៣៦៨

២៨-៦-២០០៦ -អនុក្រឹត្យលេខ ៤៤៦ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៤៣៦៩

២៨-៦-២០០៦ -អនុក្រឹត្យលេខ ៤៤៧ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ៤៣៧០

២៨-៦-២០០៦ -អនុក្រឹត្យលេខ ៤៤៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៤៣៧១

២៨-៦-២០០៦ -អនុក្រឹត្យលេខ ៤៤៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៤៣៧៧

២៨-៦-២០០៦ -អនុក្រឹត្យលេខ ៤៥០ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៤៣៧៨

២៩-៦-២០០៦ -អនុក្រឹត្យលេខ ៤៥១ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៤៣៧៩

២៩-៦-២០០៦ -អនុក្រឹត្យលេខ ៤៥២ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៤៣៨០

២៩-៦-២០០៦ -អនុក្រឹត្យលេខ ៤៥៣ អនក្រ.តត ស្តីពីការតែងតាំងមុខងារ នាយទាហាន ៤៣៨៣

២៩-៦-២០០៦ -អនុក្រឹត្យលេខ ៤៥៤ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៤៣៨៥

២៩-៦-២០០៦ -អនុក្រឹត្យលេខ ៤៥៥ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៤៣៨៧
២៩-៦-២០០៦ -អនុក្រឹត្យលេខ ៤៥៦ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៤៣៨៨

## III. ការងារបណ្តាក្រសួង

### ១. ទីស្តីការគណៈរដ្ឋមន្ត្រី

៣០-៦-២០០៦ -សេចក្តីសំរេចលេខ ៥៥ សសរ ស្តីពីការបង្កើតក្រុមការងារគម្រោងធ្វើឱ្យប្រសើរឡើងនូវរាជកិច្ច ៤៣៨៩

### ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៨-៦-២០០៦ -ប្រកាសអន្តរក្រសួងលេខ ៤៦៣ សហវ.ប្រក ស្តីពីការបង្កើតក្រុមការងារដឹកនាំការងាររៀបចំពិនិត្យកែលំអ កម្មវិធីសកម្មភាពអាទិភាព និង បើកផ្តល់ទឹកប្រាក់ ៤៣៩២
២៨-៦-២០០៦ -សេចក្តីណែនាំលេខ ០០៤ សហវ ស្តីពីការប្រព្រឹត្តទៅ និងភារកិច្ចរបស់គណៈកម្មការបណ្តឹងតវ៉ា ៤៣៩៨

### ៣. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២៧-៦-២០០៦ -ប្រកាសលេខ ៦៨១ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ហ្វ័រឈូន ហ្វេសិន លីមីធីត** បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "ហ្វ័រឈូន ហ្វេសិន លីមីធីត" ៤៤០២
២៧-៦-២០០៦ -ប្រកាសលេខ ៦៨២ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **វេយ ជា** បង្កើតរោងចក្រ "ផលិតប្រដាប់ព្យួរសម្លៀកបំពាក់" ដែលមានឈ្មោះថា "វេយ ជា" ៤៤០៤
២៧-៦-២០០៦ -ប្រកាសលេខ ៦៨៣ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **យុន ហ្វុង ប៊ីលឌីង មេធៀរៀល ខមភេនី អិលធីឌី** បង្កើតរោងចក្រ "ផលិតស៊ីម៉ង់ត៍ពីផលិតផលពាក់កណ្តាលសំរេច" ដែលមានឈ្មោះថា "យុន ហ្វុង ប៊ីលឌីង មេធៀ រៀល ខមភេនី អិលធីឌី" ៤៤០៦
២៧-៦-២០០៦ -ប្រកាសលេខ ៦៨៤ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **កូវ៉ា អ៊ិនវេសមេន អ៊ិនធើណេសិនណល (ខេមបូឌា)** បង្កើតរោងចក្រ "ថ្នាំលាប កុងតាក់ភ្លើងនិង ទ្វារដែកអូតូ" ដែលមានឈ្មោះថា "កូវ៉ា អ៊ិនវេសមេន អ៊ិនធើណេសិនណល (ខេមបូឌា)" ៤៤០៨
២៧-៦-២០០៦ -ប្រកាសលេខ ៦៨៥ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ខេមបូ ហ៊ៃនសាំ អិលធីឌី** បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "ខេមបូ ហ៊ៃនសាំ អិលធីឌី" ៤៤១០

ឥ

## ៤. ទីស្ដីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា


០៦-៦-២០០៦ -ប្រកាសលេខ ២៩០ ស.អ.យ ស្ដីពីការបង្កើតមជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់ របស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តបន្ទាយមានជ័យ ៤៤១២

០៦-៦-២០០៦ -ប្រកាសលេខ ២៩១ ស.អ.យ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់ របស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តបន្ទាយមានជ័យ ៤៤១៥

២៦-៦-២០០៦ -ប្រកាសលេខ ៣២៩ ស.អ.យ ស្ដីពីរបបឧបត្ថម្ភសំរាប់មណ្ឌលជីវិតថ្មី ភ្នំបាក់ ៤៤១៩

# ព្រះរាជក្រម

នស/រកម/០៦០៦/០១៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាបាសែល ស្តីពីការត្រួតពិនិត្យចលនាដឹកជញ្ជូន និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានលទ្ធភាពពិនិត្យ និងផ្តល់យោបល់លើអត្ថបទច្បាប់នេះ បានទាន់ពេលវេលាស្របតាមមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួម ក្នុងអនុសញ្ញាបាសែល ស្តីពីការត្រួតពិនិត្យចលនា ដឹកជញ្ជូន និងការបោះបង់ចោលសំណល់ គ្រោះថ្នាក់ឆ្លងដែន

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញាបាសែលស្តីពីការត្រួតពិនិត្យចលនាដឹកជញ្ជូន និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែន ដែលធ្វើនៅទីក្រុងបាសែល ប្រទេសស្វីស នាថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៨៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៦

ពរល.០៦០៦.២៧៨ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

ហត្ថលេខា

ម៉ុក ម៉ារ៉េត

លេខ: ៥៦១ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**
**ឃុន ជិនកេន**

# អត្ថបទ អនុសញ្ញាបាសែល
# ស្ដីពី
# ការត្រួតពិនិត្យចលនាដឹកជញ្ជូន
# និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែន

# *Text of Basel Convention*
# *on*
# *the Control of Transboundary Movements of Hazardous Wastes and Their disposal*

## មាត្រាទី ១
## វិសាលភាពរបស់អនុសញ្ញាអន្តរជាតិ " បាសែល "

១- គោលបំណងរបស់អនុសញ្ញា គឺសំដៅលើប្រធានបទនៃការដឹកជញ្ជូនសំណល់ឆ្លងដែន ដែលជាប្រភេទសំណល់គ្រោះថ្នាក់ ។

ក- ប្រភេទសំណល់ស្ថិតក្នុងឧបសម្ព័ន្ធទី I មិនត្រូវមានលក្ខណៈដូចសំណល់នៅក្នុងឧបសម្ព័ន្ធទី III ឡើយ ។

ខ- ប្រភេទសំណល់ដែលមិនស្ថិតក្នុងវាក្យខ័ណ្ឌ " ក " ប៉ុន្តែអាចកំណត់ ឬក៏អាចចាត់ទុកថាជាសំណល់គ្រោះថ្នាក់បាន ដោយយោងតាមច្បាប់នៃប្រទេសនិមួយៗរបស់ភាគី ដែលធ្វើការនាំចេញ នាំចូល និងធ្វើការដឹកជញ្ជូនឆ្លងកាត់ ។

២- "សំណល់ដទៃទៀត" ដែលជាគោលបំណងរបស់អនុសញ្ញា គឺសំដៅលើប្រភេទសំណល់ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី II ។

៣- សំណល់ដែលមានជាតិវិទ្យុសកម្ម ពុំស្ថិតក្រោមការត្រួតពិនិត្យរបស់អនុសញ្ញាអន្តរជាតិ "បាសែល" ទេ ប៉ុន្តែវាជាភារកិច្ចត្រួតពិនិត្យរបស់ប្រព័ន្ធអង្គការអន្តរជាតិ ដែលមានច្បាប់អន្តរជាតិកំណត់ទៅលើសារធាតុវិទ្យុសកម្មដាច់ដោយឡែក ។

៤- ការបញ្ចេញសំណល់ពីការប្រើប្រាស់ធម្មតាតាមនាវា ពុំស្ថិតក្រោមការត្រួតពិនិត្យរបស់អនុសញ្ញានេះទេ ប៉ុន្តែវាស្ថិតក្រោមការត្រួតពិនិត្យរបស់ច្បាប់អន្តរជាតិផ្សេងៗទៀត ។

## មាត្រាទី ២
## និយមន័យ

១- "**សំណល់**" ជាសារធាតុ ឬវត្ថុទាំងឡាយណាដែលត្រូវបានបោះចោល ឬមានបំណងបោះចោល ឬតំរូវអោយបោះចោល ដោយអនុលោមតាមច្បាប់ជាតិរបស់ប្រទេសនិមួយៗ ។

២- "**ការគ្រប់គ្រង**" ជាការប្រមូល ការដឹកជញ្ជូន និងការចាក់ចោលសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត រួមទាំងការថែរក្សាទីលានចាក់សំណល់បន្ទាប់ពីធ្វើការចាក់ចោលរួចមក ។

៣- "**ការដឹកជញ្ជូនឆ្លងដែន**" ការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀតពីតំបន់មួយទៅតំបន់មួយផ្សេងទៀត ដែលតំបន់នោះស្ថិតនៅក្រោមអំណាចត្រួតត្រារបស់ប្រទេសផ្សេងគ្នា យ៉ាងហោចណាស់ត្រូវពាក់ព័ន្ធនឹងច្បាប់ដឹកជញ្ជូននៃប្រទេសចំនួនពីរដែរ ។

៤- "**ការបោះបង់ចោល**" រាល់ដំណើរការនៃការបោះបង់ចោលសំណល់ នឹងត្រូវបានបញ្ជាក់ក្នុងឧបសម្ព័ន្ធទី IV នៃអនុសញ្ញាអន្តរជាតិ "បាសែល" នេះ ។

៥- "**ទីតាំងអនុញ្ញាត ឬឧបករណ៍សំរាប់ទុកដាក់សំណល់**" គឺសំដៅលើទីកន្លែង ឬមធ្យោបាយសំរាប់ការចាក់ចោលសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ដែលត្រូវបានអនុញ្ញាតអោយដំណើរការសំរាប់

គោលបំណងខាងលើ តាមរយៈអាជ្ញាធរពាក់ព័ន្ធនៃប្រទេសដែលមានទីកន្លែង ឬមានមធ្យោបាយទុកដាក់សំណល់ ។

៦- " **អាជ្ញាធរមានសមត្ថកិច្ច** " ជាអាជ្ញាធររដ្ឋាភិបាលមួយ ដែលបានចាត់តាំងដោយភាគីនីមួយៗ សំរាប់ទទួលខុសត្រូវលើតំបន់ភូមិសាស្ត្រសមស្រប ការទទួលពត៌មានពីការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ក៏ដូចជាពត៌មានផ្សេងទៀតដែលទាក់ទងនឹងការដឹកជញ្ជូន និងការទទួលខុសត្រូវ ដូចមានចែងក្នុងមាត្រាទី ៦ ។

៧- " **ក្រុមការទាររួម** " ជាអង្គភាពរបស់ភាគីនីមួយៗ ដែលបានចែងនៅក្នុងមាត្រាទី ៥ សំរាប់ទទួលខុសត្រូវលើការផ្តល់ ឬការទទួលពត៌មានដូចដែលចែងនៅក្នុងមាត្រាទី ១៣ និង ១៦ ។

៨- " **ការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត** " អនុលោមទៅតាមទ្រឹស្តីបរិស្ថាន ការប្រតិបត្តិនូវរាល់ជំហាន់ការអនុវត្តន៍ គឺសំដៅធានាអោយបាននូវការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ដើម្បីការពារសុខភាពមនុស្ស និងបរិស្ថានតាមរយៈការទប់ស្កាត់រាល់ឥទ្ធិពលគ្រោះថ្នាក់ដែលកើតឡើងដោយសារសំណល់នេះ ។

៩- " **តំបន់ដែលស្ថិតនៅក្រោមច្បាប់គ្រប់គ្រងរបស់ប្រទេស** " រួមមានដី តំបន់សមុទ្រ ឬអាកាសដែលស្ថិតនៅក្រោមការចុះបញ្ជីព្រំដែនត្រឹមត្រូវតាមច្បាប់អន្តរជាតិ ដោយគោរពលើការការពារសុខភាពមនុស្ស និងបរិស្ថាន ។

១០- " **ប្រទេសនាំចេញ** " គឺភាគីដែលបានធ្វើការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតដោយមានផែនការចាប់ផ្តើមដឹកចេញ ឬបានដឹកចេញរួចទៅហើយ ។

១១- " **ប្រទេសនាំចូល** " គឺជាភាគីដែលទទួលរងការចាក់សំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀតទៅតាមផែនការកំណត់ ឬក៏ស្តុកទុកដើម្បីចាក់នៅតំបន់ក្រៅពីការកំណត់របស់ច្បាប់ ។

១២- " **ប្រទេសសំរាប់ធ្វើការដឹកជញ្ជូនឆ្លងកាត់បណ្តោះអាសន្ន** " ជាប្រទេសដែលអនុញ្ញាតអោយសកម្មភាពដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀតឆ្លងកាត់ទៅកាន់ប្រទេសមួយទៀតទៅតាមការកំណត់ ។

១៣- " **ប្រទេសដែលជាប់ពាក់ព័ន្ធ** " គឺភាគីដែលជាប្រទេសនាំចេញ នាំចូល ឬឆ្លងកាត់បណ្តោះអាសន្ននូវសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតទោះបីមិនមែនជាសមាជិករបស់អនុសញ្ញានេះក៏ដោយ ។

១៤- " **បុគ្គល** " ជាបុគ្គលស្របច្បាប់ ឬជាបុគ្គលដែលមិនស្របតាមផ្លូវច្បាប់ ។

១៥- " **ម្ចាស់នាំចេញ** " ជាបុគ្គល ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសនាំចេញណាមួយដែលបានរៀបចំការនាំចេញសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀតទៅកាន់កន្លែងដទៃ ។

១៦- " **ម្ចាស់នាំចូល** " ជាបុគ្គល ដែលស្ថិតនៅក្រោមយុត្តាធិការរបស់ប្រទេសនាំចូលណាមួយ ដែលបានរៀបចំការនាំចូលនូវសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀតពីប្រទេសក្រៅ ។

១៧- " **អ្នកដឹកជញ្ជូន** " រាល់បុគ្គល ដែលអនុវត្តការដឹកជញ្ជូនផ្ទាល់នូវសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ពីកន្លែងមួយទៅកន្លែងមួយទៀត ។

១៨- " **ម្ចាស់បង្កើតសំណល់** " ជាបុគ្គលដែលបង្កើតសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ។ បើសិនមិនស្គាល់បុគ្គលដើម នោះអ្នកដែលកំពុងកាន់កាប់ត្រួតពិនិត្យជាម្ចាស់បង្កើតសំណល់ ។

១៩- " **ម្ចាស់បោះបង់សំណល់ចោល** " ជាបុគ្គលដែលដឹកជញ្ជូន និងបោះចោលនូវសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀតដោយខ្លួនឯង ។

២០- " **អង្គការដែលមានគោលនយោបាយ និងសេដ្ឋកិច្ចរួម** " ជាអង្គការដែលបង្កើតឡើងដោយរដ្ឋ ឬប្រទេសឯករាជ្យជាច្រើន ។ សមាជិកនៃរដ្ឋ ឬប្រទេសឯករាជ្យដែលបានបញ្ជូនទៅធ្វើជាសមត្ថកិច្ចតាមផ្នែកនិមួយៗ ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់អនុសញ្ញានេះ និងបានអនុញ្ញាតត្រឹមត្រូវទៅតាមគោលការណ៍ផ្ទៃក្នុងទៅលើការចុះហត្ថលេខា ការសច្ចានុម័ត ការទទួលកិច្ចព្រមព្រៀង ភាពបញ្ជាក់ត្រឹមត្រូវ ឬក៏ការយល់ព្រម ។

២១- "**ការដឹកជញ្ជូនខុសច្បាប់** " ជាការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ដូចដែលបានបញ្ជាក់ក្នុងមាត្រាទី ៩ ។

## មាត្រាទី ៣

## និយមន័យលើសំណល់គ្រោះថ្នាក់របស់ប្រទេសនិមួយៗ

១- ភាគីនិមួយៗ នៅពេលចូលជាសមាជិកពេញសិទ្ធក្នុងអនុសញ្ញានេះបានរយៈពេល ៦ខែ ត្រូវរាយការណ៍ជូនលេខាធិការដ្ឋាន អំពីសំណល់ឯទៀតដែលពុំមានរាយឈ្មោះក្នុងតារាងឧបសម្ព័ន្ធទី I និងទី II ដែលត្រូវបានពិចារណា ឬកំណត់ថាជាសំណល់គ្រោះថ្នាក់ ផ្អែកទៅតាមច្បាប់របស់ប្រទេសនិមួយៗ និងតំរូវការស្តីពីកិច្ចព្រមព្រៀងផ្សេងៗទាក់ទងនឹងនិតិវិធីនៃការដឹកជញ្ជូនសំណល់ប្រភេទខាងលើនេះ ។

២- រាល់ភាគីនិមួយៗត្រូវជូនដំណឹងជាបន្តបន្ទាប់ទៅកាន់លេខាធិការដ្ឋាន អំពីការផ្លាស់ប្តូរពត៌មានសំខាន់ៗ ស្របតាមវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ។

៣- លេខាធិការដ្ឋានត្រូវរាយការណ៍ដល់ភាគីទាំងអស់ជាបន្ទាន់ នូវពត៌មានដែលទទួលបានស្របទៅតាមវាក្យខ័ណ្ឌទី ១ និង ២ ក្នុងមាត្រានេះ ។

៤- អ្នកធ្វើរបាយការណ៍របស់ភាគីនិមួយៗ ដូចមានក្នុងវាក្យខ័ណ្ឌទី ៣ ត្រូវទទួលខុសត្រូវលើពត៌មានរបស់ខ្លួន ដែលត្រូវបានបញ្ជូនទៅអោយភាគីផ្សេងទៀតតាមរយៈលេខាធិការដ្ឋាន ។

## មាត្រាទី ៤

## ភារកិច្ចទូទៅ

១- ក- ភាគីនិមួយៗមានសិទ្ធហាមឃាត់នូវការនាំយកមកចាក់ចោល នូវសំណល់គ្រោះថ្នាក់ រឺសំណល់ដទៃទៀត ហើយត្រូវរាយការណ៍ដល់ភាគីដទៃទៀតនូវសេចក្តីសំរេចចិត្តរបស់ខ្លួនដោយអនុលោមតាមមាត្រាទី ១៣ ។

ខ- ភាគីនិមួយៗត្រូវហាមឃាត់ ឬមិនអនុញ្ញាតនូវការនាំចេញសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត

ទៅភាគីដែលបានធ្វើការហាមឃាត់រួចហើយនូវការនាំចូលសំណល់ទាំងនេះ នៅពេលបានជូនដំណឹងអនុលោមតាមវគ្គ " ក " ខាងលើ ។

គ- ភាគីនិមួយៗត្រូវហាមឃាត់ រឺមិនអនុញ្ញាតឱ្យនាំចេញសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត បើសិនប្រទេសនាំចូលមិនបានធ្វើបញ្ជីឯកសារស្តីពីការនាំចូលអោយបានច្បាស់លាស់ ហើយក្នុងករណីប្រទេសនាំចូលនោះ មិនបានហាមឃាត់នូវការនាំចូលសំណល់នេះ ។

២- រាល់ភាគីនិមួយៗត្រូវអនុវត្តតាមវិធានការណ៍ដូចខាងក្រោមនេះ :

ក- ត្រូវធានាថាការបង្កើតសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ត្រូវបានប្រើវិធីកាត់បន្ថយឱ្យនៅចំនួនអប្បបរិមា ដោយគិតគួពីហេតុប៉ះពាល់ដល់សង្គម បច្ចេកវិទ្យា និងសេដ្ឋកិច្ច ។

ខ- ធានាឱ្យមាននិតិវិធីគ្រប់គ្រាន់ដើម្បីធ្វើការចាក់ចោលសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត តាមលក្ខណៈបច្ចេកទេសបរិស្ថាន ពិសេសពង្រឹងលើផ្នែកគ្រប់គ្រងទីលានចាក់សំណល់នោះតែម្តង ។

គ- ធានាថាបុគ្គលដែលជាប់ទាក់ទងនឹងការគ្រប់គ្រងសំណល់គ្រោះថ្នាក់ រឺសំណល់ដទៃទៀត ត្រូវមានការទទួលខុសត្រូវខ្ពស់ក្នុងការការពារនូវការពុលរបស់សំណល់ ដែលកើតឡើងដោយសារការគ្រប់គ្រងរបស់គេ ។ បើសិនមានករណីបំពុលត្រូវកាត់បន្ថយការបំពុល ដើម្បីការពារកុំអោយប៉ះពាល់ដល់សុខភាពមនុស្ស និងគុណភាពបរិស្ថាន ។

ឃ- ធានាថាការដឹកជញ្ជូនឆ្លងដែននូវសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតនឹងត្រូវបានកាត់បន្ថយអោយនៅចំនួនអប្បបរិមាតាមទ្រឹស្តីបរិស្ថាន និងមានការគ្រប់គ្រងសំណល់អោយបានត្រឹមត្រូវដើម្បីការពារសុខភាពមនុស្ស និងគុណភាពបរិស្ថាន និងទប់ស្កាត់នូវរាល់ឥទ្ធិពលអាក្រក់ទាំងឡាយ ដែលកើតឡើងដោយសារបញ្ហាសំណល់ ។

ង- មិនអនុញ្ញាតអោយមានការនាំចេញសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ទៅកាន់ប្រទេស រឺទៅកាន់ក្រុមនៃប្រទេស ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គការសេដ្ឋកិច្ច រឺនយោបាយរួមតែមួយ ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានច្បាប់ហាមប្រាមលើការនាំចូល ឬបើសិនវាមានមូលហេតុបញ្ជាក់ថាសំណល់នឹងមិនអាចគ្រប់គ្រងបានតាមលក្ខណៈបច្ចេកទេសបរិស្ថាន ដោយអនុលោមតាមការវិភាគដែលបានសំរេចដោយភាគីនៅក្នុងអង្គប្រជុំលើកទី១ ។

ច- ពត៌មានស្តីអំពីសំណើសុំធ្វើការដឹកជញ្ជូនសំណល់គ្រោះថ្នាក រឺសំណល់ដទៃទៀត ត្រូវផ្តល់ទៅឱ្យប្រទេសដែលជាប់ពាក់ព័ន្ធ អនុលោមតាមឧបសម្ព័ន្ធទី ៥ " ក " និងបញ្ជាក់ឱ្យច្បាស់អំពីឥទ្ធិពលប៉ះពាល់ដល់សុខភាពមនុស្ស និងបរិស្ថាន ដែលបណ្តាលមកពីការដឹកជញ្ជូននេះ ។

ឆ- បង្ការនូវការនាំចូលសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត បើសិនជាមានហេតុផលបញ្ជាក់ថាសំណល់ទាំងនោះពុំអាចគ្រប់គ្រងតាមលក្ខណៈបច្ចេកទេសបរិស្ថានបាន ។

ជ- សហការជាមួយគូភាគីផ្សេងៗ និងអង្គការនានាដោយផ្ទាល់ ឬតាមរយៈលេខាធិការដ្ឋានរួមមានការផ្សព្វផ្សាយពត៌មានលើការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ដើម្បីបង្កើនការគ្រប់គ្រងសំណល់ទាំងនេះតាមលក្ខណៈបច្ចេកទេសបរិស្ថាន និងសំរេចជោគជ័យក្នុងការ

ទប់ស្កាត់ការដឹកជញ្ជូនសំណល់ដោយខុសច្បាប់ ។

៣- ភាគីនិមួយៗបានកំណត់ថាការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀតដោយខុសច្បាប់ គឺជាបទឧក្រិដ្ឋ ។

៤- រាល់ភាគីនិមួយៗ ត្រូវអនុវត្តនូវវិធានការស្របច្បាប់ វិធានការរដ្ឋបាល និងវិធានការផ្សេងៗដើម្បីអនុវត្ត និងពង្រឹងច្បាប់ដែលមានចែងនៅក្នុងអនុសញ្ញា រួមទាំងវិធានការនានាដើម្បី ទប់ស្កាត់ និងដាក់ទណ្ឌកម្មដល់ការប្រព្រឹត្តល្មើសចំពោះអនុសញ្ញានេះ ។

៥- ភាគីនិមួយៗមិនត្រូវអនុញ្ញាតឱ្យមានការនាំចេញសំណល់គ្រោះថ្នាក់ រឺសំណល់ដទៃទៀតទៅកាន់ភាគីដែលពុំមែនជាសមាជិកអនុសញ្ញាបាសែល រឺក៏នាំចូលប្រភេទសំណល់នេះមកពីប្រទេសដែលពុំមែនជាសមាជិកអនុសញ្ញាបាសែលចូលមកកាន់ប្រទេសខ្លួនឡើយ ។

៦- ភាគីនិមួយៗមិនត្រូវយល់ព្រមនូវការសុំនាំចេញសំណល់គ្រោះថ្នាក់ រឺសំណល់ដទៃទៀតទៅចាក់ចោលក្នុងតំបន់ដែលមានរិតារន្តរ $60^0$ អង្សា ឬទោះជាសំណល់ទាំងនោះមិនមែនជាប្រធានបទសំរាប់ការដឹកជញ្ជូនឆ្លងដែនក៏ដោយ ។

៧- លើសពីនោះទៀត ភាគីទាំងអស់ត្រូវ :

ក- ហាមឃាត់បុគ្គលទាំងអស់ ផ្អែកទៅតាមច្បាប់កំណត់របស់ប្រទេសនិមួយៗ ស្តីពីការដឹកជញ្ជូន ឬចាក់ចោលសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត លើកលែងតែបុគ្គលនោះទទួលបានការអនុញ្ញាតអោយអនុវត្តជាមុន ។

ខ- រាល់ការដឹកជញ្ជូនឆ្លងដែននូវសំណល់គ្រោះថ្នាក់ រឺសំណល់ដទៃទៀត ត្រូវតែធ្វើការវេចខ្ចប់ បិទផ្លាកសញ្ញា និងដឹកជញ្ជូនដោយមានការព្រមព្រៀង និងទទួលស្គាល់តាមច្បាប់ និងតាមស្តង់ដារអន្តរជាតិ ។ រឺងរបាយការណ៍ដែលបានធ្វើឡើង ត្រូវមានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ។

គ- រាល់ការដឹកជញ្ជូនឆ្លងដែននូវសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ត្រូវមានឯកសារភ្ជាប់ជាមួយស្តីពីចំនុចចាប់ផ្តើមដឹកជញ្ជូនចេញ និងចំនុចចាក់ចោលសំណល់ ។

៨- ភាគីនិមួយៗ ត្រូវទាមទាអោយមានការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតដែលត្រូវនាំចេញតាមលក្ខណៈបច្ចេកទេសបរិស្ថាន ក្នុងប្រទេសដែលនាំចូល ឬកន្លែងផ្សេងៗទៀត ។ គោលការណ៍ណែនាំដែលជាប្រធានបទរបស់អនុសញ្ញាអន្តរជាតិបាសែលសំរាប់ការគ្រប់គ្រងសំណល់តាមលក្ខណៈបច្ចេកទេសបរិស្ថាន នឹងត្រូវលើកយកមកធ្វើសេចក្តីសំរេចចិត្តរវាងគូភាគីទាំងសងខាងនៅក្នុងជំនួបលើកទី ១ ។

៩- ភាគីនិមួយៗត្រូវជ្រើសរើសយកវិធានការណ៍សមស្រប ដើម្បីធានាថាការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀតនឹងត្រូវបានអនុញ្ញាត្ត បើសិន :

ក- ប្រទេសនាំចេញគ្មានសមត្ថភាពគ្រប់គ្រាន់ ទៅលើផ្នែកបច្ចេកទេស សំភារៈចាំបាច់សមត្ថភាព ឬទីលានចាក់អោយបានសមស្រប ដើម្បីបោះចោលសំណល់ដោយផ្អែកទៅតាមលក្ខណៈបច្ចេកទេសបរិស្ថាន និងប្រកបដោយប្រសិទ្ធិភាព ។

ខ- សំណល់ទាំងនេះ មានវត្ថុធាតុដើមសំរាប់ការកែច្នៃ និងទាញយកមកប្រើប្រាស់ឡើងវិញ ក្នុងវិស័យឧស្សាហកម្មនៃប្រទេសនាំចូល ។

គ- អនុលោមតាមការវិនិច្ឆ័យរបស់ភាគីផ្សេងទៀត ការដឹកជញ្ជូនសំណល់ឆ្លងដែននេះ នឹងត្រូវបានសំរេចដោះស្រាយដោយភាគីនិមួយៗ ក្នុងលក្ខខ័ណ្ឌនៃការវិនិច្ឆ័យដោយស្របតាមការចែងរបស់អនុសញ្ញានេះ ។

១០- កាតព្វកិច្ចរបស់ប្រទេសនិមួយៗ ដែលជាសមាជិករបស់អនុសញ្ញានេះ ត្រូវទទួលខុសត្រូវចំពោះសំណល់គ្រោះថ្នាក់ ដែលខ្លួនបានបង្កើតអោយបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសបរិស្ថាន ដោយមិនត្រូវស្ថិតនៅក្រោមល័ក្ខខ័ណ្ឌផ្សេងរបស់ប្រទេសនាំចូល ឬប្រទេសដែលឆ្លងកាត់ឡើយ ។

១១- អនុសញ្ញានេះមិនបានរារាំង ដល់សេចក្តីត្រូវការបន្ថែមរបស់ភាគីនិមួយៗ ស្របតាមសេចក្តីចែងរបស់អនុសញ្ញានេះ និងអនុលោមតាមបទបញ្ញាតិរបស់ច្បាប់អន្តរជាតិ ដើម្បីការពារសុខភាពមនុស្ស និងគុណភាពបរិស្ថានឱ្យកាន់តែប្រសើរឡើង ។

១២- អនុសញ្ញានេះមិនធ្វើអោយមានការប៉ះពាល់ ដល់អធិបតេយ្យភាពដែនសមុទ្រប្រទេសនិមួយៗ ដោយផ្អែកទៅតាមច្បាប់អន្តរជាតិ និងអំណាចច្បាប់ និងយុត្តាធិការចំពោះប្រទេស ដែលមានតំបន់សេដ្ឋកិច្ចរួម និងនៅក្នុងទីបរបស់គេដោយអនុលោមតាមច្បាប់អន្តរជាតិ និងការដឹកជញ្ជូនតាមនាវាឬតាមយន្តហោះ នៃប្រទេសទាំងអស់ក៏ដូចជា តាមច្បាប់នាវាចរណ៍ និងសិទ្ធសេរីភាពដូចដែលបានចែង ក្នុងច្បាប់អន្តរជាតិ ។

១៣- ភាគីនិមួយៗត្រូវទទួលខុសត្រូវចាំបាច់ ក្នុងការពិនិត្យឡើងវិញលើលទ្ធភាពក្នុងការកាត់បន្ថយបរិមាណ ឬកំរិតជាតិពុលនៃសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ដែលបាននាំចេញទៅប្រទេសដទៃ ជាពិសេសចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ។

## មាត្រាទី ៥
## ការបង្កើតក្រុមអាជ្ញាធរមានសមត្ថកិច្ច និងក្រុមការងាររួម

ដើម្បីសំរួលក្នុងការអនុវត្តន៍អនុសញ្ញានេះ ភាគីនិមួយៗត្រូវតែ :

១- ចាត់តាំង ឬបង្កើតក្រុមអាជ្ញាធរមានសមត្ថកិច្ច ឬក្រុមការងាររួមមួយ ។ ក្រុមអាជ្ញាធរមានសមត្ថកិច្ចនឹងត្រូវបានធ្វើការចាត់តាំងឡើងដើម្បីទទួលការប្រកាស ក្នុងករណីឆ្លងកាត់ប្រទេស ។

២- ពេលចូលជាសមាជិកពេញសិទ្ធរបស់អនុសញ្ញានេះបានរយៈពេលបីខែ ភាគីនិមួយៗត្រូវរាយការណ៍ជូនលេខាធិការដ្ឋានអំពីការតែងតាំងសមាសភាពនៃក្រុមអាជ្ញាធរមានសមត្ថកិច្ច និងក្រុមការងាររួម ។

៣- រាយការណ៍ជូនលេខាធិការដ្ឋានអោយបានរយៈពេលមួយខែ អំពីសេចក្តីសំរេចលើការផ្លាស់ប្តូរនានា ដែលទាក់ទងនឹងការតែងតាំងក្រុមការងាររួម ឬក្រុមអាជ្ញាធរមានសមត្ថកិច្ចថ្មីដូចដែលបានចែងនៅក្នុងវគ្គទី ២ នៃមាត្រានេះ ។

## មាត្រានី ៦
## ការដឹកជញ្ជូនឆ្លងដែនរវាងគូភាគីនិមួយៗ

1- ប្រទេសនាំចេញត្រូវចេញប្រកាស ឬស្នើដល់ម្ចាស់បង្កើត និងម្ចាស់នាំចេញសំណល់ឱ្យរាយការណ៍ជាលាយល័ក្ខអក្សរ តាមរយៈក្រុមអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចេញនោះ និងអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសដែលពាក់ព័ន្ធ អំពីសំណើសុំលើការដឹកជញ្ជូនឆ្លងដែននូវសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ។ ការប្រកាសនេះត្រូវមានជារបាយការណ៍ និងពត៌មានជាក់លាក់ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី ៥ "ក" រួមទាំងការប្រើប្រាស់ភាសាដែលប្រទេសនាំចូលអាចទទួលយល់ព្រម ។ សេចក្តីប្រកាសនេះ ត្រូវផ្ញើរទៅកាន់ប្រទេសដែលពាក់ព័ន្ធនឹងការដឹកជញ្ជូននេះ ។

២- ប្រទេសនាំចូលត្រូវទទួលខុសត្រូវ ក្នុងការប្រកាសជាលាយល័ក្ខអក្សរដូចជា ការអនុញ្ញាត្តឱ្យធ្វើការដឹកជញ្ជូនដោយមានលក្ខខ័ណ្ឌ ឬគ្មានលក្ខខ័ណ្ឌ ការបដិសេធលើការដឹកជញ្ជូន និងសំណើសុំពត៌មានបន្ថែម ។ ឯកសារថតចំលង ស្តីពីការទទួលខុសត្រូវដំណាក់កាលចុងក្រោយរបស់ប្រទេសនាំចូល ត្រូវផ្ញើរទៅកាន់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដែលជាគូភាគី ។

៣- ប្រទេសនាំចេញ មិនត្រូវអនុញ្ញាត្តអោយម្ចាស់បង្កើត ឬម្ចាស់នាំចេញសំណល់ចាប់ផ្តើមធ្វើការដឹកជញ្ជូនឆ្លងដែន លុះត្រាតែប្រទេសនាំចេញទាំងនោះទទួលបានការបញ្ជាក់ថា :

ក- អ្នកប្រកាសបានទទួលលិខិតអនុញ្ញាត្តពីប្រទេសនាំចូល

ខ- អ្នកប្រកាសបានទទួលការបញ្ជាក់ពីប្រទេសនាំចូលនូវកិច្ចសន្យារវាងម្ចាស់នាំចេញ និងម្ចាស់បោះបង់ចោល ដោយបញ្ជាក់ច្បាស់លាស់ពីការគ្រប់គ្រងសំណល់តាមលក្ខណៈបច្ចេកទេសបរិស្ថានត្រឹមត្រូវ ។

៤- រាល់ប្រទេសឆ្លងកាត់ដែលជាគូភាគី ត្រូវទទួលស្គាល់ជាបន្ទាន់ នូវបង្កាន់ដៃរបស់អ្នកប្រកាស ។ ប្រទេសដែលសំណល់ត្រូវធ្វើការឆ្លងកាត់ អាចឆ្លើយតបជាលាយលក្ខណ៍អក្សរក្នុងអំឡុងពេល៦០ថ្ងៃ សំរាប់ការអនុញ្ញាត្តដល់ការដឹកជញ្ជូនដោយមានលក្ខខ័ណ្ឌ ឬគ្មានលក្ខខ័ណ្ឌ និងភ្ជាប់លិខិតបដិសេធលើការអនុញ្ញាត្តនៃការដឹកជញ្ជូន ឬការស្នើពត៌មានបន្ថែមនានា ។

ប្រទេសនាំចេញមិនត្រូវអនុញ្ញាត្តអោយចាប់ដំណើការដឹកជញ្ជូន ដរាបណាមិនទាន់ទទួលលិខិតអនុញ្ញាត្តពីប្រទេសដែលត្រូវឆ្លងកាត់ ។ ទោះជាយ៉ាងណាក៏ដោយ បើសិននៅពេលណាមួយភាគីសំរេចថាមិនត្រូវការកិច្ចព្រមព្រៀងជាលាយលក្ខ័អក្សរក្នុងលក្ខខ័ណ្ឌទូទៅ ឬជាក់លាក់ណាមួយលើការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតឆ្លងកាត់ប្រទេសខ្លួន ឬមានការកែប្រែលើតំរូវការផ្សេងៗ នោះនឹងត្រូវជូនដំណឹងជាបន្ទាន់នូវសេចក្តីសំរេចរបស់ខ្លួនដល់គូភាគីឯទៀត យោងតាមមាត្រាទី ១៣ ។ ក្នុងករណីយឺតយ៉ាវដោយប្រទេសនាំចេញមិនបានទទួលចំលើយតបក្នុងរយៈពេល៦០ថ្ងៃ ក្រោយពីទទួលបាននូវបង្កាន់ដៃប្រកាសរបស់ប្រទេសឆ្លងកាត់ នោះប្រទេសនាំចេញអាចអនុញ្ញាត្តអោយម្ចាស់នាំចេញ ប្តឹងពីប្រទេសឆ្លងកាត់នោះបាន ។

៥- ក្នុងករណីដឹកជញ្ជូនសំណល់ ដែលបានកំណត់ត្រឹមត្រូវតាមច្បាប់ ឬបានចាត់ទុកជាសំណល់គ្រោះថ្នាក់ លុះត្រាកំណត់ដោយ :

ក- ប្រទេសនាំចេញ ត្រូវអនុវត្តទៅតាមតម្រូវការក្នុងវគ្គទី ៩ នៃមាត្រានេះ ដែលលើកពីករណីពាក់ព័ន្ធនឹងម្ចាស់នាំចូល ម្ចាស់បោះបង់ចោល ហើយប្រទេសនាំចូលត្រូវស្នើសុំ Mutatis Mutendis ចំពោះម្ចាស់នាំចេញ និងប្រទេសនាំចេញរៀងៗខ្លួន ។

ខ- ប្រទេសនាំចូល ឬដោយប្រទេសឆ្លងកាត់ដែលជាគូភាគីជាមួយប្រទេសនាំចូល ត្រូវអនុវត្តទៅតាមតម្រូវការក្នុងវគ្គទី ១ ៣ ៤ និង ៦ នៃមាត្រានេះ ហើយប្រទេសនាំចេញត្រូវស្នើសុំ Mutatis Mutendis ចំពោះម្ចាស់នាំចូល ម្ចាស់បោះបង់ចោល ឬប្រទេសនាំចូលរៀងៗខ្លួន ។

គ- សេចក្តីចែងក្នុងវគ្គទី៤ ចំពោះប្រទេសដែលត្រូវឆ្លងកាត់ត្រូវអនុវត្តសំរាប់ប្រទេសទាំងអស់នេះ ។

៦- ប្រទេសនាំចេញជាកម្មវត្ថុនៃការផ្តល់លិខិតអនុញ្ញាតដោយប្រទេសជាប់ពាក់ព័ន្ធ សំរាប់ការអនុញ្ញាតម្ចាស់បង្កើត ឬម្ចាស់នាំចេញប្រើប្រាស់ប្រកាសទូទៅ អំពីការដឹកជញ្ជូនជាប្រចាំសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតដែលមានលក្ខណៈរូប និងលក្ខណៈគីមីដូចគ្នាទៅប្រទេសដែលទទួលសំណល់ ដោយត្រូវឆ្លងកាត់តាមទីចាត់ការគយផ្នែកច្រកចេញនៃប្រទេសនាំចេញ និងតាមរយៈទីចាត់ការគយផ្នែកច្រកចូលនៃប្រទេសនាំចូល ។ ក្នុងការឆ្លងកាត់ ត្រូវទាក់ទងនឹងទីចាត់ការគយផ្នែកច្រកចេញ និងច្រកចូលរបស់ប្រទេសដែលត្រូវឆ្លងកាត់ ។

៧- តាមរយៈលិខិតអនុញ្ញាតជាផ្លូវការ ប្រទេសពាក់ព័ន្ធអាចប្រើប្រាស់ប្រកាសទូទៅ ដោយយោងតាមសេចក្តីចែងក្នុងវគ្គទី ៦ លើការផ្តល់ពត៌មានជាក់លាក់ដូចជាអំពីបរិមាណពិតប្រាកដ ឬបញ្ជីរៀបរាប់ពីរយៈពេលដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ។

៨- លិខិតអនុញ្ញាត និងការប្រកាសទូទៅទាក់ទងនឹងវគ្គទី ៦ និង ៧ អាចមានអទិភាពប្រើប្រាស់លើការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀតក្នុងរយៈពេលអតិបរិមាចំនួន ១២ខែ ។

៩- ភាគីទាំងឡាយ ត្រូវស្នើដល់បុគ្គល ដែលទទួលខុសត្រូវលើការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ឱ្យចុះហត្ថលេខាក្នុងឯកសារ ឬក្នុងបង្កាន់ដៃ ។ ហើយក៏ត្រូវស្នើផងដែរដល់ប្រទេសទទួលសំណល់ឱ្យរាយការណ៍ជូនម្ចាស់នាំចេញ និងអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចេញនូវបង្កាន់ដៃ ដែលបញ្ជាក់ថាបានបំពេញការចាក់ចោលសំណល់ទៅតាមសេចក្តីប្រកាស ។ បើសិនប្រទេសនាំចេញមិនបានទទួលពត៌មាននេះ នោះអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចេញ ឬម្ចាស់នាំចេញត្រូវធ្វើការជូនដំណឹងទៅកាន់ប្រទេសនាំចូល ។

១០- ការប្រកាស និងការឆ្លើយតបដែលជាតម្រូវការរបស់មាត្រានេះ ត្រូវផ្ញើរបញ្ជូនទៅអាជ្ញាធររបស់ភាគីពាក់ព័ន្ធ ឬអាជ្ញាធររដ្ឋាភិបាលក្នុងករណី ដែលពុំមែនជាគូភាគីក្នុងការដឹកជញ្ជូន ។

១១- រាល់ការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតត្រូវតែមានការធានារ៉ាប់រងវិញ្ញាបនប័ត្រ ឬការធានាខុសត្រូវដែលជាសំណូមពររបស់ប្រទេសនាំចូល និងប្រទេសឆ្លងកាត់ ដែលជាគូភាគី ។

## មាត្រាទី ៧
## ការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀត ពីប្រទេសមួយជាសមាជិករបស់អនុសញ្ញាអន្តរជាតិបាសែល ទៅកាន់ប្រទេសមួយទៀត ដែលមិនមែនជាសមាជិក

វគ្គទី ១ នៃមាត្រាទី ៦ របស់អនុសញ្ញានេះត្រូវអោយមានការស្នើសុំ Mutatis Mutandis ដើម្បីធ្វើការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀតពីប្រទេសមួយជាសមាជិកអនុសញ្ញាអន្តរជាតិបាសែលទៅកាន់ប្រទេសមួយទៀត ដែលមិនមែនជាភាគី ។

## មាត្រាទី ៨
## ការធានាសំរាប់ការនាំចូលជាថ្មីវិញ

នៅពេលដែលការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដ៏ទៃទៀត ត្រូវបានអនុញ្ញាតដោយប្រទេសពាក់ព័ន្ធ ប៉ុន្តែប្រធានបទមួយចំនួនដែលបានចែងក្នុងអនុសញ្ញាមិនទាន់បានបំពេញអោយបានគ្រប់ជ្រុងជ្រោយដូចមានក្នុងកិច្ចព្រមព្រៀង នោះការចាក់សំណល់នឹងចាត់ទុកថាពុំស្របតាមលក្ខណៈបច្ចេកទេសបរិស្ថាន នោះប្រទេសនាំចេញត្រូវធានានឹងយកសំណល់នោះត្រឡប់ទៅវិញក្នុងកំឡុងពេល ៩០ថ្ងៃ គិតចាប់ពីថ្ងៃ ដែលប្រទេសនាំចូលបានជូនដំណឹងទៅប្រទេសនាំចេញ និងទៅលេខាធិការដ្ឋានអនុសញ្ញាអន្តរជាតិ "បាសែល" ឬគិតចាប់ពីពេលដែលប្រទេសជាប់ពាក់ព័ន្ធ បានព្រមព្រៀងគ្នា ។ នៅទីបញ្ចប់ប្រទេស នាំចេញនិងប្រទេសត្រូវឆ្លងកាត់មិនត្រូវបង្កការរារាំង រីខានការដឹកជញ្ជូនសំណល់ទាំងនេះទៅប្រទេសនាំចេញទេ ។

## មាត្រាទី ៩
## ការដឹកជញ្ជូនខុសច្បាប់

១- គោលបំណងរបស់អនុសញ្ញានេះ សំដៅលើការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀត ដែលចាត់ទុកជាការដឹកជញ្ជូនខុសច្បាប់បើ :

ក- មិនបានផ្តល់ការប្រកាសដល់ប្រទេសជាប់ពាក់ព័ន្ធទាំងអស់ ដូចមានចែងក្នុងអនុសញ្ញានេះ ។

ខ- គ្មានការយល់ព្រមពីប្រទេសដែលជាប់ពាក់ព័ន្ធ ដូចមានចែងក្នុងអនុសញ្ញានេះ ។

គ- លិខិតអនុញ្ញាតរបស់ប្រទេសជាប់ពាក់ព័ន្ធត្រូវបានការកែបន្លំ ឬមិនត្រឹមត្រូវតាមច្បាប់ ។

ឃ- មិនបានបញ្ជាក់គ្រប់គ្រាន់តាមឯកសារ

ង- លទ្ធផលនៃការបោះបង់ចោលសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀត ផ្ទុយពីគោលការណ៍របស់អនុសញ្ញា និងច្បាប់អន្តរជាតិ ។

២- ក្នុងករណីការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដ៏ទៃទៀត ចាត់ទុកជាការដឹកជញ្ជូនខុសច្បាប់ ប្រទេសនាំចេញត្រូវធានាខុសត្រូវចំពោះសំណល់របស់គេ :

ក- ម្ចាស់នាំចេញ ឬម្ចាស់បង្កើតសំណល់ ត្រូវដឹកជញ្ជូនត្រលប់ទៅប្រទេសខ្លួន ឬទៅប្រទេសនាំចេញវិញ បើសិនចាំបាច់ គឺត្រូវដឹកជញ្ជូនដោយខ្លួនឯង ។

ខ- អនុលោមតាមសេចក្តីថ្លែងរបស់អនុសញ្ញា ក្នុងកំឡុងពេល៣០ថ្ងៃក្រោយពីមានការជូនដំណឹងចំពោះការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតមានលក្ខណៈខុសច្បាប់ ប្រទេសនាំចេញត្រូវដឹកជញ្ជូនសំណល់របស់ខ្លួន ទៅកាន់ប្រទេសនាំចេញវិញ ។ រីឯភាគីពាក់ព័ន្ធ មិនត្រូវប្រឆាំងរារាំងដល់ការដឹកជញ្ជូនសំណល់នេះទេ ។

៣- ក្នុងករណីដែលការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ចាត់ទុកជាការដឹកជញ្ជូនខុសច្បាប់ដែលបណ្តាលពីការដឹកនាំរបស់ម្ចាស់នាំចូល ឬម្ចាស់បោះបង់ចោល នោះប្រទេសនាំចូលត្រូវធានាថាសំណល់នេះ ត្រូវបានចាក់ចោលតាមលក្ខណៈបច្ចេកទេសបរិស្ថាន ដោយម្ចាស់នាំចូល ឬដោយបុគ្គលដែលទទួលខុសត្រូវក្នុងការចាក់សំណល់នេះ បើសិនចាំបាច់ដោយខ្លួនឯងក្នុងរយៈពេល ៣០ថ្ងៃ គិតពីថ្ងៃនៃការដឹកជញ្ជូនខុសច្បាប់បានដឹងឮដោយប្រទេសនាំចូល ឬក្នុងរយៈពេលដែលប្រទេសពាក់ព័ន្ធមានការយល់ព្រមគ្នា ។ នៅទីបញ្ចប់ប្រទេសពាក់ព័ន្ធ ត្រូវសហការគ្នាក្នុងការចាក់សំណល់ចោល តាមលក្ខណៈបច្ចេកទេសបរិស្ថាន ។

៤- ក្នុងករណីការទទួលខុសត្រូវលើការដឹកជញ្ជូនខុសច្បាប់ មិនអាចកំណត់បានទៅលើម្ចាស់នាំចេញ ម្ចាស់បង្កើត ម្ចាស់នាំចូល ឬអ្នកចាក់សំណល់ចោល នោះគូភាគីពាក់ព័ន្ធ ឬភាគីផ្សេងៗទៀតត្រូវធានាថាតាមរយៈការសហការគ្នា ការបោះបង់សំណល់ដែលមានបញ្ហាត្រូវប្រព្រឹត្តឡើងយ៉ាងឆាប់រហ័សតាមលក្ខណៈបច្ចេកទេសបរិស្ថាននៃប្រទេសនាំចេញ និងប្រទេសនាំចូល ឬកន្លែងផ្សេងៗទៀតដែលគិតថាជាកន្លែងសមរម្យ ។

៥- ភាគីនិមួយៗ ត្រូវធ្វើការបង្កាញពីច្បាប់ជាតិ ឬច្បាប់ក្នុងស្រុកដ៏សមស្របសំរាប់ការពារ និងដាក់ទណ្ឌកម្មដល់ការដឹកជញ្ជូនសំណល់ខុសច្បាប់ ។ ភាគីនិមួយៗត្រូវសហការគ្នាអនុវត្តទិសដៅមាត្រានេះអោយមានប្រសិទ្ធភាព ។

## មាត្រាទី ១០

## ការសហការជាលក្ខណៈអន្តរជាតិ

១- ភាគីនិមួយៗ ត្រូវសហការគ្នាដើម្បីបង្កើន និងសំរេចអោយបានលទ្ធផលល្អក្នុងការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតតាមលក្ខណៈបច្ចេកទេសបរិស្ថាន ។

២- នៅទីបញ្ចប់នេះភាគីនិមួយៗត្រូវ :

ក- ផ្អែកទៅតាមសំណើ ត្រូវបង្កើតពតិមានដែលមានលក្ខណៈទ្វេភាគី ឬពហុភាគីដើម្បីបង្កើនការត្រួតពិនិត្យឡើងវិញ លើការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតរាប់បញ្ចូលទាំងស្តង់ដារតាមបច្ចេកទេស និងការអនុវត្តន៍ទៅលើការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ។

ខ- សហការគ្នាក្នុងការត្រួតពិនិត្យឡើងវិញ នូវឥទ្ធិពលប៉ះពាល់ទៅលើសុខភាពមនុស្ស និងបរិស្ថានដែលបណ្តាលមកពីការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ។

គ- សហការគ្នាក្នុងការអនុវត្តន៍តាមច្បាប់ជាតិ បទបញ្ញា និងគោលនយោបាយរបស់ភាគីនិមួយៗក្នុងការអភិវឌ្ឍន៍ និងការអនុវត្តន៍បច្ចេកវិទ្យាបរិស្ថានថ្មី ដែលបង្កើតបរិមាណសំណល់ក្នុង

កាកសំណល់ និងបង្កើនការកែប្រែបច្ចេកវិទ្យាដែលមានស្រាប់ ដើម្បីកាត់បន្ថយការបង្កើតសំណល់ និងសំរេចនូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពទៅតាមលក្ខណៈបច្ចេកទេសបរិស្ថាន រាប់បញ្ចូលទាំង ការសិក្សាលើឥទ្ធិពលសេដ្ឋកិច្ច សង្គម និងស្ថានភាពបរិស្ថាន ដែលបណ្តាលមកពីបច្ចេកវិទ្យាថ្មី ឬបច្ចេកវិទ្យាដែលបានកែលំអរ ។

ឃ- សហការគ្នាយ៉ាងសកម្ម ក្នុងការអនុវត្តន៍ច្បាប់ជាតិ បទបញ្ញា និងគោលនយោបាយរបស់ភាគីនិមួយៗ ក្នុងការផ្លាស់ប្តូរបច្ចេកវិទ្យា និងប្រព័ន្ធគ្រប់គ្រងដែលទាក់ទងនឹងការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀត ផ្អែកតាមលក្ខណៈបច្ចេកទេសបរិស្ថាន ។ ត្រូវសហការផងដែរក្នុងការពង្រីក និងពង្រឹងសមត្ថភាពជំនាញជាមួយភាគីឯទៀត ជាពិសេសវាជាតំរូវការ និងជាសំណើផ្នែកជំនួយបច្ចេកទេសចំពោះបញ្ហាគ្រប់គ្រងសំណល់នេះ ។

ង- សហការគ្នា ក្នុងការពង្រឹងគោលការណ៍ណែនាំបច្ចេកទេស និងច្បាប់អនុវត្តការងារ ។

៣- ភាគីនិមួយៗ ត្រូវអនុវត្តការងារអោយបានល្អប្រសើរ ក្នុងន័យរួមសហការគ្នាដើម្បីជួយប្រទេសដែលកំពុងអភិវឌ្ឍន៍ក្នុងការអនុវត្តន៍មាត្រាទី ៤ ចំនុច **ក ខ គ** និង **ឃ** ក្នុងវគ្គទី **២** នេះ ។

៤- គិតគូដល់សេចក្តីត្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ការសហការគ្នារវាងភាគីនិមួយៗ និងសមត្ថកិច្ចរបស់អង្គការអន្តរជាតិ ដោយលើកទឹកចិត្តដើម្បីបង្កើន Inter-alia ចំណេះដឹងរបស់ប្រជាជនអោយកាន់តែប្រសើរឡើងលើការពង្រឹងការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ឬសំណល់ដ៏ទៃទៀត និងការជ្រើសរើសយកបច្ចេកវិទ្យាថ្មីដែលមានបរិមាណសំណល់ក្នុងកាកសំណល់ ។

## មាត្រាទី ១១
## កិច្ចព្រមព្រៀងមានលក្ខណៈជាទ្វេភាគី ពហុភាគី និងតំបន់

១- ទោះបីមានការចែងក្នុងមាត្រាទី ៤ វគ្គទី ៥ក៏ដោយ ភាគីនិមួយៗអាចចូលរួមបង្កើតកិច្ចព្រមព្រៀងជាលក្ខណៈទ្វេភាគី ពហុភាគី ឬ តំបន់រួមដោយផ្អែកទៅលើការដឹកជញ្ជូនឆ្លងដែននូវសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀតជាមួយគូភាគីជាសមាជិក ឬមិនមែនជាសមាជិករបស់អនុសញ្ញានេះបាន ដោយស្ថិតក្នុងលក្ខខ័ណ្ឌព្រមព្រៀងគ្នា ឬរៀបចំដឹកជញ្ជូនសំណល់ ដោយមិនអនុវត្តការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀតខុសពីការគ្រប់គ្រងតាមបច្ចេកទេសបរិស្ថានដូចមានចែងក្នុងអនុសញ្ញានេះ ។ ការឯកភាពគ្នា ឬការរៀបចំការដឹកជញ្ជូនសំណល់នេះត្រូវបញ្ជាក់ច្បាស់លើសេចក្តីចែង ស្តីអំពីការគ្រប់គ្រងបរិស្ថានដែលជាគោលបំណងរបស់អនុសញ្ញាអន្តរជាតិបាសែល ហើយជាពិសេសគិតគូលើផលប្រយោជន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍ ។

២- ភាគីនិមួយៗត្រូវរាយការណ៍ដល់លេខាធិការដ្ឋានអំពីកិច្ចព្រមព្រៀងលក្ខណៈជាទ្វេភាគី ពហុភាគី តំបន់ ឬការរៀបចំណាមួយយោងទៅតាមវគ្គទី ១ ដែលគេបានចូលរួមក្នុងកិច្ចព្រមព្រៀងរបស់អនុសញ្ញា ក្នុងទិសដៅត្រួតពិនិត្យការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀតឆ្លងដែនដែលធ្វើឡើងដោយគូភាគីដែលស្ថិតក្នុងកិច្ចព្រមព្រៀងនេះ ។ សេចក្តីចែងនៃអនុសញ្ញានេះ

មិនធ្វើអោយមានការប្រែប្រួលលើការដឹកជញ្ជូនឆ្លងដែន ដែលប្រព្រឹត្តឡើងស្របតាមកិច្ចព្រមព្រៀង ដោយអនុវត្តការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត តាមលក្ខណៈបច្ចេកទេស បរិស្ថានត្រឹមត្រូវទៅតាមតំរូវការរបស់អនុសញ្ញា ។

## មាត្រាទី ១២
## ការពិគ្រោះលើការទទួលខុសត្រូវរបស់អនុសញ្ញាអន្តរជាតិបាសែល

រាល់ភាគីនិមួយៗត្រូវសហការត្រួតពិនិត្យដើម្បីអនុមតិលើគោលការណ៍រៀបចំច្បាប់ និងនិតិវិធីលើការទទួលខុសត្រូវ និងការចេញសងរាល់ការខូចខាតទាំងឡាយ ដែលបណ្តាលមកពីការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតឆ្លងដែន ។

## មាត្រាទី ១៣
## ការបញ្ជូនពត៌មាន

១- ភាគីនិមួយៗត្រូវមានការយល់ដឹង និងធានារ៉ាប់រងក្នុងករណីមានគ្រោះថ្នាក់ចៃដន្យ នៅពេលគេកំពុងធ្វើការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ឬពេលចាក់ចោល ដែលបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស និងគុណភាពបរិស្ថានក្នុងប្រទេសផ្សេងៗទៀត ភាគីនោះត្រូវប្រកាសជូនដំណឹងជាបន្ទាន់ ។

២- គូភាគីនិមួយៗត្រូវរាយកាណ៍ដល់គ្រប់ភាគីនានា តាមរយៈលេខាធិការដ្ឋានអំពី :

ក- ការផ្លាស់ប្តូរត្រូវប្រព្រឹត្តតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច និងក្រុមការងាររួមអនុលោមតាមសេចក្តីចែងក្នុងមាត្រាទី ៥ ។

ខ- ការផ្លាស់ប្តូរនិយមន័យរបស់សំណល់គ្រោះថ្នាក់តាមប្រទេសនិមួយៗរបស់ខ្លួន អនុលោមតាមសេចក្តីចែងក្នុងមាត្រាទី ៣ អោយបានឆាប់រហ័សទៅតាមលទ្ធភាព ។

គ- សេចក្តីសំរេចនានា ដែលធ្វើឡើងដោយភាគីនិមួយៗ មិនអាចចាត់ទុកជាសេចក្តីយល់ព្រមរួមឬផ្នែកខ្លះក្នុងការនាំចូលសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតទៅចាក់ចោលនៅតំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ច្បាប់ជាតិនៃភាគីនោះ ។

ឃ- សេចក្តីសំរេចនានា ដែលកំណត់ឡើងដោយភាគីនិមួយៗ សំដៅរឹតកំណត់ ឬហាមឃាត់ការនាំចេញសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ។

ង- តំរូវការពត៌មានផ្សេងៗ អនុលោមតាមសេចក្តីចែងក្នុងវគ្គទី ៤ នៃមាត្រានេះ ។

៣- ភាគីនិមួយៗ ដែលមានច្បាប់ និងបទបញ្ញត្តិនានា ត្រូវធ្វើរបាយកាណ៍ដល់អង្គសន្និសិទ្ធភាគីតាមរយៈលេខាធិការដ្ឋាន ស្របតាមសេចក្តីចែងក្នុងមាត្រាទី ១៥ មុនពេលបំណាច់ឆ្នាំ ។ នៅក្នុងរបាយការណ៍នៃឆ្នាំកន្លងទៅ ត្រូវសរសេររាយការណ៍អំពី :

ក- ការជ្រើសតាំងសមាសភាពរបស់អាជ្ញាធរមានសមត្ថកិច្ច ឬក្រុមការងាររួម អនុលោមតាមសេចក្តីចែងក្នុងមាត្រាទី ៥ ។

ខ- ពត៌មានស្តីពីការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀតដែលគេបានពាក់ព័ន្ធរួមមាន :

- បរិមាណនៃការនាំចេញ ប្រភេទ លក្ខណៈ ប្រទេសដែលជាគោលដៅចាក់ចោល ប្រទេសឆ្លងកាត់ និងនិតិវិធីចាក់សំណល់ ដូចមានចែងនៅក្នុងសេចក្តីប្រកាស ។
- បរិមាណនៃការនាំចូល ប្រភេទ លក្ខណៈ ប្រភពបង្កើត និងនិតិវិធីនៃការចាក់ចោលសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀត ។
- ការបោះបង់ចោលដែលមិនលើសពីគំរោង ។
- ការខំប្រឹងប្រែងកាត់បន្ថយបរិមាណសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀត ជាពិសេសសំដៅលើការដឹកជញ្ជូន ។

គ- ពត៌មានស្តីពីវិធានការ ដែលត្រូវបានអនុម័តដើម្បីអនុវត្តនៅក្នុងអនុសញ្ញានេះ ។

ឃ- ពត៌មានស្ថិតិពិតប្រាកដ ត្រូវបានចងក្រងឡើងពីឥទ្ធិពលនៃការប៉ះពាល់ដល់សុខភាពមនុស្ស និងគុណភាពបរិស្ថាន ដែលជាមូលហេតុបណ្តាលមកពី ការបង្កើត ការដឹកជញ្ជូន និងការបោះបង់ចោលនៃសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ។

ង- ពត៌មានទាក់ទងនឹងកិច្ចព្រមព្រៀងជាលក្ខណៈទ្វេភាគី ពហុភាគី តំបន់រួម និងការរៀបចំកិច្ចព្រមព្រៀងដោយអនុលោមតាមសេចក្តីចែងក្នុងមាត្រាទី ១១ នៃអនុសញ្ញានេះ ។

ច- ពត៌មានស្តីពីភាពគ្រោះថ្នាក់ទាំងឡាយ ដែលកើតឡើងក្នុងពេលដឹកជញ្ជូន និងពេលចាក់ចោលសំណល់គ្រោះថ្នាក់ រឺសំណល់ដ៏ទៃទៀត និងពត៌មានស្តីអំពីវិធានការណ៍ដោះស្រាយបញ្ហានេះ។

ឆ- ពត៌មានលើការជ្រើសរើសវិធីសាស្ត្រចាក់សំណល់នៅក្នុងតំបន់ ដែលគ្រប់គ្រងដោយច្បាប់ជាតិ។

ជ- ពត៌មានស្តីអំពីវិធានការណ៍ទទួលខុសត្រូវលើការអភិវឌ្ឍន៍បច្ចេកវិទ្យាថ្មីដើម្បីកាត់បន្ថយ រឺបំបាត់ការផលិតសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀត ។

ឈ- ពត៌មានស្តីអំពីបញ្ហាផ្សេងៗ ដែលអង្គសន្និសិទភាគីចាត់ទុកថាមានការពាក់ព័ន្ធ ។

៤- ភាគីនីមួយៗដែលមានច្បាប់ជាតិនិងបទបញ្ញត្តិ ត្រូវធានាថារាល់សេចក្តីប្រកាសចំលងស្តីពីការអនុញ្ញាតលើ ការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ឬសំណល់ដ៏ទៃទៀត និងភាពទទួលខុសត្រូវ ចំពោះការដឹកជញ្ជូននេះនឹងត្រូវផ្ញើរដល់លេខាធិការដ្ឋាន នៅពេលភាគីយល់ឃើញថាការដឹកជញ្ជូនសំណល់ ទាំងនេះអាចបង្កការប៉ះពាល់ដល់បរិស្ថាន ។

## មាត្រាទី ១៤

## ផ្នែកថវិកា

១- ភាគីនិមួយៗបានឯកភាពថា អនុលោមតាមតំរូវការជាក់ស្តែងក្នុងតំបន់ និងអនុតំបន់ផ្សេងៗគ្នាដូចនេះគួរតែបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាល និងផ្លាស់ប្តូរបច្ចេកវិទ្យានៅក្នុងតំបន់ និងអនុតំបន់ដែលទាក់ទងនឹងការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ឬសំណល់ដ៏ទៃទៀត និងការកាត់បន្ថយការបង្កើតសំណល់ ។ ភាគីនិមួយៗត្រូវដោះស្រាយបង្កើតយន្តការថវិកាដោយខ្លួនឯង ។

២- ភាគីនិមួយៗត្រូវគិតគូទៅលើការបង្កើតថវិកា ដើម្បីជួយជាមូលដ្ឋានបណ្តោះអាសន្នក្នុងករណីបន្ទាន់ ដើម្បីកាត់បន្ថយការខូចខាតពីគ្រោះថ្នាក់ ដែលកើតឡើងដោយសារការដឹកជញ្ជូនឆ្លងដែន នៃសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ឬក្នុងកំឡុងពេលនៃដំណើរការចាក់ចោលសំណល់ទាំងនោះ ។

## មាត្រាទី ១៥
## អង្គសន្និសិទរបស់ភាគី

១- អង្គសន្និសិទរបស់ភាគី គឺជាការបង្កើតឡើងតាមរយៈភាគីទាំងអស់ ។ អង្គប្រជុំទីមួយនៃអង្គសន្និសិទរបស់ភាគី ត្រូវបានកោះអញ្ជើញដោយប្រធាននាយកប្រតិបត្តិកម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ (UNEP ) មុនរយៈពេលមួយឆ្នាំបន្ទាប់ពីចូលជាសមាជិកពេញសិទ្ធរបស់អនុសញ្ញានេះ ។ បន្ទាប់មកអង្គប្រជុំវិសាមញ្ញនៃអង្គសន្និសិទភាគី នឹងត្រូវប្រារព្ធឡើងក្នុងរយៈពេលទៀងទាត់មួយ ដែលកំណត់ដោយអង្គសន្និសិទ នាសម័យប្រជុំលើកទីមួយ ។

២- អង្គប្រជុំវិសាមញ្ញបន្ថែមរបស់អង្គសន្និសិទភាគី ត្រូវប្រារព្ធធ្វើក្នុងពេលផ្សេងទៀត បើសិនជាអង្គសន្និសិទចាត់ទុកជាការចាំបាច់ ឬតាមសំណើសុំរបស់ភាគីណាមួយ ដោយមានសំលេងគាំទ្រមួយភាគបីពីភាគីទាំងអស់ ។ ក្រោយពេលទទួលបានសំណើសុំក្នុងរយៈពេល ៦ខែ លេខាធិការដ្ឋានត្រូវជូនដំណឹងអំពីសំណើនោះជូនភាគីទាំងអស់ ។

៣- ក្នុងអង្គសន្និសិទ ភាគីនិមួយៗត្រូវធ្វើការឯកភាព និងទទួលយល់ព្រម ដោយអនុម័តច្បាប់ស្តីពីបែបបទសំរាប់សន្និសិទរបស់ភាគី និងសំរាប់បញ្ហាផ្សេងៗ ក៏ដូចជាច្បាប់ថវិកា សំរាប់កំនត់ការចូលរួមបរិច្ចាកថវិកាផ្ទាល់របស់ភាគីនិមួយៗចំពោះអនុសញ្ញានេះ ។

៤- នៅក្នុងអង្គប្រជុំលើកទីមួយ ភាគីនិមួយៗ ត្រូវស្វែងយល់ពីវិធានការចាំបាច់បន្ថែមដើម្បីជួយបំប៉នចំណេះដឹងបន្ថែមលើការងារទទួលខុសត្រូវក្នុងការការពារ និងការថែរក្សាបរិស្ថានផ្នែកទឹកសមុទ្រដែលមានក្នុងបរិបទនៃអនុសញ្ញានេះ ។

៥- សន្និសិទភាគី ត្រូវរក្សាបន្តការត្រួតពិនិត្យឡើងវិញជាប្រចាំ និងធ្វើការវាយតំលៃលទ្ធផលនៃការអនុវត្តន៍របស់សន្និសិទ្ធ និងលើសពីនេះត្រូវ :

ក- ជួយជំរុញអោយកាន់តែមានភាពចុះសំរុងគ្នាលើការអនុវត្តន៍គោលនយោបាយ យុទ្ធសាស្រ្ត និងវិធានការនានាសំរាប់កាត់បន្ថយភាពគ្រោះថ្នាក់នៃសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀតដល់សុខភាពមនុស្ស និងគុណភាពបរិស្ថាន ។

ខ- ធ្វើការពិគ្រោះនិងទទួលយល់ព្រម ទៅតាមតំរូវការ ឬធ្វើវិសោធនកម្មលើសន្និសិទ្ធ និងឧបសម្ព័ន្ធរបស់វា ដោយពិភាក្សាលើពត៌មានសំខាន់ៗ ដូចជាអ៊ីនធ័រអាលីយ៉ា (Inter- alia) ការស្រាវជ្រាវផ្នែកវិទ្យាសាស្រ្ត បច្ចេកទេស សេដ្ឋកិច្ច និងបរិស្ថាន ។

គ- ធ្វើការពិគ្រោះ និងទទួលខុសត្រូវលើការងារបន្ថែម ដែលអាចជាតំរូវការក្នុងការអនុវត្តន៍ឱ្យបានសំរេចនូវគោលបំណងរបស់អនុសញ្ញានេះ ក្នុងការបង្ហាញនូវបទពិសោធន៍ដែលធ្លាប់សំរេច

បានជោគជ័យក្នុងការងាររបស់ខ្លួន និងបទពិសោធន៍ក្នុងការងាររៀបចំភាគីអោយមានភាពចុះសំរុងគ្នាលើសេចក្តីចែងក្នុងមាត្រាទី ១១ ។

ឃ- ធ្វើការពិគ្រោះ និងទទួលយល់ព្រមលើពិធីការផ្សេងៗ នៅពេលមានសំណើ ។

ង- ចាត់តាំងបង្កើតអោយមានបុគ្គលសំរាប់ជំនួយការងាររបស់អនុសញ្ញា បើសិនចាត់ទុកថាជាការចាំបាច់ ។

៦- អង្គការសហប្រជាជាតិ អង្គភាពពិសេសរបស់ UN ក៏ដូចជាប្រទេស ដែលមិនមែនជាភាគីរបស់អនុសញ្ញានេះទេ អាចចូលរួមជាអ្នកសង្កេតការណ៍ក្នុងអង្គប្រជុំមួយនៃអង្គសន្និសិទ្ធរបស់ភាគី ។ បុគ្គលណា ឬភ្នាក់ងារដ៏ទៃទៀត ទោះបីជាបំរើការងារអោយជាតិ អន្តរជាតិ អន្តររដ្ឋាភិបាល ឬក្រៅរដ្ឋាភិបាលណាមួយ ដែលមានជំនាញច្បាស់លាស់ទាក់ទងនឹងសំណល់គ្រោះថ្នាក់ ឬសំណល់ដ៏ទៃទៀត ហើយបានជូនដំណឹងដល់លេខាធិការដ្ឋាន អំពីគោលបំណងចង់ចូលរួមក្នុងអង្គប្រជុំរបស់អង្គសន្និសិទ្ធភាគីក្នុងនាមជាអ្នកសង្កេតការណ៍នឹងអាចយល់ព្រម លើកលែងតែមានសំលេងមួយភាគបីរបស់អង្គសន្និសិទ្ធភាគីបានជំទាស់ ។

៧- អង្គសន្និសិទ្ធរបស់ភាគី ត្រូវទទួលរ៉ាប់រងរយៈពេលបីឆ្នាំ បន្ទាប់ពីចូលជាធរមានក្នុងអនុសញ្ញានេះ និងរាល់ ៦ឆ្នាំម្តង ត្រូវធ្វើការវាយតំលៃលើលទ្ធផលនិមួយៗ ហើយបើមានការចាំបាច់នឹងពិភាក្សាលើការអនុម័តទាំងស្រុងឬលើផ្នែកខ្លះនៃច្បាប់ហាមឃាត់ ការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀត ដើម្បីជាការជួយបង្ហាញអំពីពត៌មានថ្មីបំផុតនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងសេដ្ឋកិច្ច ។

## មាត្រាទី ១៦
## លេខាធិការដ្ឋាន

១- តួនាទីរបស់លេខាធិការដ្ឋាន :

ក- រៀបចំ និងចាត់ចែងការប្រជុំ តាមសេចក្តីចែងក្នុងមាត្រាទី ១៥ និង ១៧ ។

ខ- រៀបចំ និងបញ្ជូនរបាយការណ៍ ផ្អែកទៅលើពត៌មានដែលបានទទួល ស្របតាមមាត្រាទី ៣ ៤ ៦ ១១ និងទី ១៣ ហើយក៏ដូចជាពត៌មាននានា ដែលទទួលបាននៅក្នុងអង្គប្រជុំលើការផ្លាស់ប្តូរសមាសភាពក្នុងមាត្រាទី ១៥ ឬពត៌មានដែលបានទទួលពីអង្គភាពក្នុង និងក្រៅរដ្ឋាភិបាល ។

គ- រៀបចំរបាយកាណ៍ពីសកម្មភាពលើការអនុវត្តន៍តួនាទីរបស់ខ្លួន ស្របតាមអនុសញ្ញានេះហើយរាយការណ៍ជូនទៅអង្គសន្និសិទ្ធភាគី ។

ឃ- ធានាលើការសំរបសំរួលផ្នែកទំនាក់ទំនងការបរទេស ជាពិសេសលើផ្នែកចាត់តាំង និងការរៀបចំកិច្ចសន្យាផ្សេងៗ ដែលទាមទារឱ្យមានប្រសិទ្ធិភាពខ្ពស់ ក្នុងការបោះបង់ចោលសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀត ។

ង- ធ្វើការទំនាក់ទំនងជាមួយអាជ្ញាធរមានសមត្ថកិច្ច និងក្រុមការងាររួម ដែលបានបង្កើតឡើងអនុលោមតាមមាត្រាទី ៥ របស់អនុសញ្ញានេះ ។

ច- ប្រមូលពត៌មាននានាស្តីពីការដ្ឋានជាតិ ឬមធ្យោបាយនានាទាក់ទងនឹងការបោះបង់ចោលសំណល់គ្រោះថ្នាក់ ឬសំណល់ដ៏ទៃទៀតរបស់ភាគីនិមួយៗ ហើយធ្វើការផ្សព្វផ្សាយពត៌មានទាំងនេះដល់ភាគីឯទៀត ។

ឆ- ទទួល និងបញ្ជូនបន្តរាល់ពត៌មាននានាពីភាគីមួយទៅភាគីមួយទៀតអំពី :

- ប្រភពជំនួយផ្នែកបច្ចេកទេស និងផ្នែកបណ្តុះបណ្តាល
- ជំនាញបច្ចេកទេស និងវិទ្យាសាស្ត្រ
- គន្លឹះនៃការណែនាំ និងឯកទេស
- ការរកប្រភពធនធាន
- **នៅពេលមានសំណើ លេខាធិការដ្ឋានជានជួយភាគីនិមួយៗតាមការជាក់ស្តែង ដូចជាផ្នែក:**
- ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់អនុសញ្ញានេះ
- ការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀត
- បច្ចេកវិទ្យាបរិស្ថានដែលទាក់ទងនឹងសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀតដូចជាបច្ចេកវិទ្យាកាត់បន្ថយសំណល់ និងធ្វើអោយគ្មានសំណល់ ។
- ការវាយតំលៃលើសមត្ថភាព និងការជ្រើសរើសទីលាននៃការបោះបង់ចោលសំណល់ ។
- ការត្រួតពិនិត្យសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀត ។
- និងការទទួលខុសត្រូវ នៅពេលមានគ្រោះអាសន្នដោយសារសំណល់ ។

ជ- ផ្តល់ពត៌មានតាមសំណើរបស់ភាគីនីមួយៗលើទីប្រឹក្សា ឬការផ្តល់យោបល់អំពីវិធីសាស្ត្រនានាដែលធ្លាប់សំរេចបានលទ្ធផលល្អកន្លងមក សំរាប់ជាជំនួយលើការពិនិត្យពិច័យចំពោះការប្រកាសពីសកម្មភាពដឹកជញ្ជូនឆ្លងដែន ការព្រមព្រៀងលើការវេចខ្ចប់សំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀត ដែលទាក់ទងនឹងការប្រកាស ឬតាមហេតុការណ៍ជាក់ស្តែងលើសំណើផ្នែកសំភារៈគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀតតាមលក្ខណៈបច្ចេកទេសបរិស្ថាននៅពេល គេមានមូលហេតុគួរអោយទុកចិត្តថា សំណល់មានបញ្ហានេះមិនអាចគ្រប់គ្រងតាមលក្ខណៈបច្ចេកទេសបរិស្ថានបាន ។ ការចំណាយលើការពិនិត្យពិច័យនេះមិនមែនជាបន្ទុករបស់លេខាធិការដ្ឋានឡើយ ។

ញ- ជួយភាគីនិមួយៗតាមសំណើ ស្តីពីអត្តសញ្ញាណកម្មនៃការដឹកជញ្ជូនខុសច្បាប់ និងផ្សព្វផ្សាយជាបន្ទាន់ដល់ភាគីពាក់ព័ន្ធ អំពីពត៌មានដែលទទួលបានពីការដឹកជញ្ជូនខុសច្បាប់ ។

ដ- សហការជាមួយភាគីនិមួយៗ អង្គការអន្តរជាតិ និងអង្គភាពពាក់ព័ន្ធនានា ក្នុងការផ្តល់អ្នកឯកទេស និងសំភារៈបច្ចេកទេស សំរាប់ជាប្រយោជន៍ក្នុងការជួយជាបន្ទាន់ដល់ប្រទេសដែលកំពុងមានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារសំណល់ ។

ឋ- ការបែងចែកតួនាទីផ្សេងៗនេះ តាមគោលបំណងរបស់អនុសញ្ញា ក៏ដូចជាការកំណត់របស់អង្គសន្និសិទ្ធភាគីដែរ ។

២- តួនាទីរបស់លេខាធិការដ្ឋាន នឹងត្រូវអនុវត្តដោយកម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ ផ្អែកលើ

មូលដ្ឋានបណ្តោះអាសន្ន រហូតដល់ចុងបញ្ចប់អង្គប្រជុំលើកទីមួយរបស់អង្គសន្និសិទ្ធភាគី ដែលប្រារព្ធធ្វើឡើងអនុលោមតាមមាត្រាទី ១៥ ។

៣- នៅក្នុងអង្គប្រជុំលើកទីមួយរបស់ភាគី អង្គសន្និសិទ្ធភាគីត្រូវចាត់តាំងលេខាធិការដ្ឋាន មកពីក្នុងចំណោមអង្គការនៃអន្តររដ្ឋាភិបាល ដែលបានចុះហត្ថលេខាស្ម័គ្រចិត្ត ដើម្បីទទួលអនុវត្តតំណែងលេខាធិការដ្ឋានតាមអនុសញ្ញានេះ ។ នៅក្នុងអង្គប្រជុំនេះ អង្គសន្និសិទ្ធភាគីក៏ត្រូវវាយតំលៃលើការអនុវត្តន៍តួនាទីរបស់លេខាធិការដ្ឋានស្តីទីដែរ ជាពិសេសចំពោះសេចក្តីចែងនៅក្នុងវគ្គទី ១ នៃមាត្រានេះ និងដោះស្រាយសំរេចទៅពេលមានរចនាសម្ព័ន្ធត្រឹមត្រូវសំរាប់មុខតំណែងនេះ ។

## មាត្រាទី ១៧
## ការធ្វើវិសោធនកម្មអនុសញ្ញា

១- ភាគីនិមួយៗ អាចធ្វើសំណើក្នុងការធ្វើវិសោធនកម្មអនុសញ្ញានេះ ហើយភាគីដែលពាក់ព័ន្ធ នឹងកិច្ចព្រមព្រៀង មានសិទ្ធស្នើសុំក្នុងការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនោះ ។ ការធ្វើវិសោធនកម្មទាំងពីរខាងលើនេះ ត្រូវគិតគូពិចារណាអោយបានល្អិតល្អន់លើ អ៊ីនធ័រ អាលីយ៉ា (Inter-alia) ដែលទាក់ទងនឹងវិទ្យាសាស្ត្រ និងបច្ចេកទេស ។

២- ការធ្វើវិសោធនកម្មអនុសញ្ញានេះ ត្រូវតែមានការទទួលយល់ព្រមពីអង្គប្រជុំរបស់អង្គសន្និសិទ្ធភាគី ។ ការធ្វើវិសោធនកម្មចំពោះកិច្ចព្រមព្រៀង ត្រូវតែមានការឯកភាពពីអង្គប្រជុំរបស់ភាគី ដែលពាក់ព័ន្ធនឹងកិច្ចព្រមព្រៀង ។ រាល់លិខិតស្នើសុំធ្វើវិសោធនកម្មចំពោះអនុសញ្ញា និងកិច្ចព្រមព្រៀង នឹងត្រូវធ្វើរជូនភាគីនិមួយៗតាមរយៈលេខាធិកាដ្ឋានក្នុងរយៈពេល ៦ខែ មុនពេលចាប់ផ្តើមបើកអង្គប្រជុំ ។ លេខាធិកាដ្ឋានក៏ត្រូវផ្សព្វផ្សាយផងដែរ អំពីសំណើធ្វើវិសោធនកម្ម ដល់ហត្ថលេខីនៃអនុសញ្ញានេះសំរាប់ជាពត៌មាន ។

៣- ភាគីនិមួយៗ ត្រូវធ្វើការប្រឹងប្រែងដើម្បីសំរេចដល់ការយល់ព្រម លើសំណើសុំធ្វើវិសោធនកម្មនៅក្នុងអនុសញ្ញានេះដោយមតិទូទៅ ។ បើសិនការប្រឹងប្រែងនេះ មិនឈានដល់ការឯកភាពទេ មធ្យោបាយចុងក្រោយគឺការបោះឆ្នោតដើម្បីទទួលអនុមតិទៅលើសំលេងបីភាគបួននៃវត្តមានរបស់ភាគីនៅក្នុងអង្គសន្និសិទ ។ ហើយនឹងត្រូវបានរៀបចំដាក់ស្នើដោយលេខាធិការដ្ឋាន ចំពោះភាគីនិមួយៗ ដើម្បីទទួលការអនុម័ត ការឯកភាព ការបញ្ជាក់ជាផ្លូវការ ឬការទទួលយល់ព្រមរបស់ភាគីនិមួយៗ ។

៤- នីតិវិធីដែលបានបញ្ជាក់ក្នុងវគ្គទី ៣ ខាងលើនេះ ត្រូវអនុវត្តចំពោះការធ្វើវិសោធនកម្មចំពោះកិច្ចព្រមព្រៀងណាមួយ លើកលែងតែសំលេងពីរភាគបីរបស់ភាគី ឯកភាពលើគោលការណ៍បច្ចុប្បន្នមទាំងការបោះឆ្នោតនៅក្នុងអង្គប្រជុំនឹងមានលក្ខណៈគ្រប់គ្រាន់ដល់ការអនុម័តរបស់គេ ។

៥- រាល់ឯកសារនៃការធ្វើវិសោធនកម្មទាំងឡាយទាក់ទងនឹងការសច្ចានុម័ត ការអនុញ្ញាត ការបញ្ជាក់ជាផ្លូវការ ឬការទទួលយល់ព្រម នឹងត្រូវបានតំកល់ទុកនៅទីស្នាក់ការលេខាធិការដ្ឋាន ។ ការធ្វើវិសោធនកម្ម ដែលបានទទួលការអនុម័ត អនុលោមតាមការចែងនៅក្នុងវគ្គទី ៣ ឬទី ៤

ខាងលើ នឹងចូលជាធរមានក្រោយរយៈពេល ៩០ថ្ងៃ បន្ទាប់ពីទទួលបានលិខិតពីលេខាធិការដ្ឋានទាក់ទងនឹង ការសច្ចាប័ន ការអនុម័ត ការអនុញ្ញាត ការបញ្ជាក់ជាផ្លូវការ ឬការទទួលយល់ព្រមដោយមានសំលេង គាំទ្របីភាគបួនពីភាគី លើការធ្វើវិសោធនកម្មចំពោះអនុសញ្ញា និងយ៉ាងតិចពីរភាគបីចំពោះកិច្ចព្រមព្រៀង ។ ការធ្វើវិសោធនកម្មនឹងចូលជាធរមាន សំរាប់ភាគីទាំងអស់ក្នុងរយៈពេល ៩០ថ្ងៃ បន្ទាប់ពីភាគីបានដាក់ឱ្យពិនិត្យនូវឯកសារ ការធ្វើវិសោធនកម្មដែលមានការសច្ចាប័ន ការអនុញ្ញាត ការបញ្ជាក់ជាផ្លូវការ ឬការទទួលយល់ព្រម ។

៦- គោលបំណងរបស់មាត្រានេះ ពាក្យ "ភាគីបច្ចុប្បន្ន និងការបោះឆ្នោត" មានន័យថាភាគីដែលមានវត្តមានបច្ចុប្បន្ន និងការផ្តល់សំលេងគាំទ្រ ឬប្រឆាំង ។

## មាត្រាទី ១៨
## ការទទួលយល់ព្រម និងការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធ

១- ឧបសម្ព័ន្ធនៅក្នុងអនុសញ្ញានេះ ឬនៅក្នុងកិច្ចព្រមព្រៀងណាមួយ នឹងត្រូវបង្កើតបានជាផ្នែករួមផ្សំនៃអនុសញ្ញា ឬកិច្ចព្រមព្រៀងនេះនៅក្នុងករណីដែលមិនបានចែងឱ្យទូលំទូលាយ ឬក្នុងករណីដែលមានសេចក្តីយោងទៅនឹងអនុសញ្ញានេះ ឬកិច្ចព្រមព្រៀងនៃឧបសម្ព័ន្ធរួមផ្សំជំណាលគ្នា នឹងការយោងទៅនឹងឧបសម្ព័ន្ធនានា ។ ឧបសម្ព័ន្ធនេះត្រូវបានកំរិតទៅតាមបញ្ហាវិទ្យាសាស្ត្របច្ចេកទេស និងរដ្ឋបាល ។

២- លើកលែងតែមានចែងនៅក្នុងកិច្ចព្រមព្រៀងណាមួយ ចំពោះឧបសម្ព័ន្ធនោះ បើមិនដូច្នោះទេនិតិវិធីខាងក្រោម នឹងត្រូវអនុវត្តទៅតាមសំណើ ទៅតាមការអនុម័ត និងត្រូវចាត់ចូលជាធរមានដោយបន្ថែមឧបសម្ព័ន្ធទៅលើអនុសញ្ញានេះ ឬទៅលើកិច្ចព្រមព្រៀង ។

ក- ឧបសម្ព័ន្ធនៅក្នុងអនុសញ្ញា និងកិច្ចព្រមព្រៀងនេះ ត្រូវបានស្នើ និងធ្វើការអនុម័តអនុលោមទៅតាមនិតិវិធី ដែលបានចែងនៅក្នុងមាត្រាទី ១៧ វគ្គទី ២ ទី ៣ និងទី ៤ ។

ខ- ភាគីណាមួយ ដែលមិនអាចទទួលយល់ព្រមពីការស្នើបន្ថែមឧបសម្ព័ន្ធនៅក្នុងអនុសញ្ញានេះ ឬនៅក្នុងកិច្ចព្រមព្រៀងណាមួយ នោះភាគីត្រូវរាយការណ៍ជាលាយល័ក្ខអក្សរដល់ទីស្នាក់ការផ្ទុកឯកសាររបស់លេខាធិការដ្ឋាន ក្នុងរយៈពេល ៦ខែ គិតចាប់ពីពេលដែលទីស្នាក់ការធ្វើការទំនាក់ទំនងទៅភាគីនានាដើម្បីទទួលការអនុម័ត ។ ទីស្នាក់ការផ្ទុកឯកសាររបស់លេខាធិការដ្ឋានត្រូវជូនដំណឹងជាបន្ទាន់ដល់ភាគីនិមួយៗ នៅពេលបានទទួលសេចក្តីរាយការណ៍នោះ។ ភាគីនិមួយៗអាចផ្លាស់ប្តូរជំហររបស់ខ្លួន ស្តីពីការជំទាស់ទៅលើសេចក្តីប្រកាសកន្លងមកដោយទទួលយល់ព្រមវិញ ហើយឧបសម្ព័ន្ធនឹងចូលជាធរមានសំរាប់ភាគីទាំងអស់ ។

គ- ក្នុងរយៈពេល ៦ខែផុតកំណត់បន្ទាប់ពីពេលដែលទីស្នាក់ការផ្ទុកឯកសាររបស់លេខាធិការដ្ឋានបានបញ្ជូនដំណឹង នោះឧបសម្ព័ន្ធនឹងមានប្រសិទ្ធភាពសំរាប់ភាគីទាំងអស់ក្នុងអនុសញ្ញានេះ ឬសំរាប់កិច្ចព្រមព្រៀងពាក់ព័ន្ធផ្សេងៗ ដែលមិនបានដាក់ស្នើសេចក្តីប្រកាសស្របតាមសេចក្តីចែងនៃវគ្គ (ខ) ខាងលើ ។

៣- រាល់សំណើ លើការអនុម័តនិងការចូលជាធរមាន នៃការធ្វើវិសោធនកម្មចំពោះឧបសម្ព័ន្ធរបស់អនុសញ្ញានេះ ឬចំពោះកិច្ចព្រមព្រៀងផ្សេងៗ នឹងជាប្រធានបទសំខាន់សំរាប់ទំរង់ការតែមួយដូចគ្នានឹងសំណើលើការអនុម័ត និងការចូលជាធរមាននៃឧបសម្ព័ន្ធចំពោះអនុសញ្ញា ឬចំពោះកិច្ចព្រមព្រៀង ។ រាល់ការធ្វើវិសោធនកម្មឧបសម្ព័ន្ធ ត្រូវគិតគូលើ អ៊ីនធ័រ អាលីយ៉ា ដែលទាក់ទងនឹងការពិចារណាទៅលើវិទ្យាសាស្ត្រ និងបច្ចេកទេសសង្គម ។

៤- បើសិនការបន្ថែមឧបសម្ព័ន្ធ ឬការធ្វើវិសោធនកម្មចំពោះឧបសម្ព័ន្ធ មានការពាក់ព័ន្ធជាមួយនឹងអនុសញ្ញានេះឬកិច្ចព្រមព្រៀងផ្សេងៗ នោះការបន្ថែម ឬការធ្វើវិសោធនកម្មចំពោះឧបសម្ព័ន្ធមិនអាចនឹងចូលជាធរមាន រហូតដល់ការធ្វើវិសោធនកម្មចំពោះអនុសញ្ញាឬកិច្ចព្រមព្រៀងនេះចូលជាធរមានសិន ។

## មាត្រាទី ១៩
## តស៊ូតាម

ភាគីណាមួយ ដែលមានហេតុផលគួរអោយទុកចិត្តថា មានភាគីផ្សេងទៀតដែលកំពុងឬបានប្រព្រឹត្តល្មើសនឹងកាតព្វកិច្ចខ្លួនដែលមានចែងក្នុងអនុសញ្ញានេះ ភាគីនោះអាចរាយការណ៍ជូនលេខាធិការដ្ឋាន និងក្នុងព្រឹត្តិការណ៍ជាមួយគ្នានេះ ត្រូវរាយការណ៍ផ្ទាល់ ឬដោយប្រយោលដល់លេខាធិការដ្ឋានជាបន្ទាន់ អំពីភាគីដែលបានប្រព្រឹត្តបំពាននឹងអនុសញ្ញា ។ លេខាធិការដ្ឋាន នឹងត្រូវដាក់ស្នើរាល់ពត៌មានពាក់ពន្ធ័ទាំងអស់ ទៅគ្រប់ភាគីនីមួយៗដើម្បីពិនិត្យ ។

## មាត្រាទី ២០
## ដំណោះស្រាយនៃជំលោះ

១- ក្នុងករណីមានជំលោះរវាងគូភាគីទាំងឡាយ តាមរយៈការបកស្រាយ ការអនុវត្តន៍ផ្អែកទៅតាមអនុសញ្ញានេះឬកិច្ចព្រមព្រៀង ភាគីនិមួយៗត្រូវរកវិធីដោះស្រាយជំលោះ តាមរយៈការចរចាឬមធ្យោបាយសំរុះសំរួលណាមួយ តាមការជ្រើសរើសរបស់គេ ។

២- បើសិនភាគីពាក់ព័ន្ធ មិនអាចដោះស្រាយជំលោះរបស់គេ តាមរយៈមធ្យោបាយដែលបញ្ជាក់ក្នុងវគ្គទី ១ នៃមាត្រានេះ ហើយបើភាគីនៅតែបន្តជំលោះ ភាគីទាំងនោះត្រូវដាក់ជូនតុលាការអន្តរជាតិ ឬដាក់ជូនអាជ្ញាកណ្តាលដែលស្ថិតក្នុងលក្ខខ័ណ្ឌបានចែងក្នុងឧបសម្ព័ន្ធទី ៦ ហើយដែលមានចែងពីអាជ្ញាកណ្តាល ។ ទោះបីពុំបានទទួលជោគជ័យក្នុងការស្វែងរកការឯកភាពរួមលើការដាក់អោយពិនិត្យជំលោះទៅតុលាការអន្តរជាតិ ឬទៅអាជ្ញាកណ្តាលក្តី នោះមិនត្រូវអោយភាគីទាំងនោះរួចផុតពីការទទួលខុសត្រូវក្នុងការបន្តស្វែងរកដំណោះស្រាយជំលោះតាមមធ្យោបាយស្របតាមវគ្គទី ១ ឡើយ ។

៣- នៅពេលកំពុងធ្វើការសច្ចានុម័ត ការទទួលយល់ព្រម ការអនុញ្ញាត្ត ការបញ្ជាក់ជាផ្លូវការ ឬកំពុងឯកភាព ប្រទេសឬអង្គការនយោបាយសេដ្ឋកិច្ចរួម អាចធ្វើការប្រកាសទទួលស្គាល់

ជាផ្លូវការ ដូចជាភាពចាំបាច់នៃអ៊ីស្សូហ្វាកតូ ( Ipso Facto ) និងពុំចាំបាច់នូវការឯកភាពពិសេសទាក់ទងនឹងភាគីដែលមានកាតព្វកិច្ចដូចគ្នា :

ក- ការដាក់ជូនទៅតុលាការអន្តរជាតិនូវបញ្ហាជម្លោះ ដើម្បីធ្វើការត្រួតពិនិត្យ

ខ- ឬទៅអាជ្ញាកណ្តាល អនុលោមតាមនីតិវិធី ដែលមានចែងក្នុងឧបសម្ព័ន្ធទី ៦ ។

សេចក្តីប្រកាសនេះ នឹងត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋាន ដែលនឹងជូនបន្តដល់ភាគីឯទៀត ។

## មាត្រាទី ២១
## ការចុះហត្ថលេខា

អនុសញ្ញានេះ ត្រូវបានបើកដំណើរការចុះហត្ថលេខាដោយតំណាងប្រទេស ដោយណាមីប៊ីយ៉ា (Namibia) ដែលជាតំណាងឱ្យក្រុមប្រឹក្សាអង្គការសហប្រជាជាតិ សំរាប់ណាមីប៊ីយ៉ា (Namibia) និងដោយអង្គការដែលមានគោលនយោបាយ ឬសេដ្ឋកិច្ចរួម នាថ្ងៃទី ២២ ខែ មិនា ឆ្នាំ ១៩៨៩ ក្នុងទីក្រុងបាសែល នៅនាយកដ្ឋានសហព័ន្ធកិច្ចការបរទេសនៃប្រទេសស្វីសក្នុងទីក្រុង Berne កាលពីថ្ងៃទី ២៣ ខែ មិនា ដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៨៩ និងនៅទីស្នាក់ការអង្គការសហប្រជាជាតិប្រចាំទីក្រុងញូវយ៉កពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ១៩៨៩ ដល់ថ្ងៃទី ២២ ខែ មិនា ឆ្នាំ ១៩៩០ ។

## មាត្រាទី ២២
## ការសច្ចានុម័ត ការព្រមព្រៀង ការបញ្ជាក់ ឬការអនុម័តជាផ្លូវការ

១- អនុសញ្ញានេះ នឹងជាប្រធានបទសំខាន់ចំពោះការធ្វើសច្ចានុម័ត ការព្រមព្រៀង ឬការអនុម័តដោយណាមីប៊ីយ៉ា ( Namibia ) ដែលជាតំណាងក្រុមប្រឹក្សាអង្គការសហប្រជាជាតិសំរាប់ ណាមីប៊ីយា ( Namibia ) និងចំពោះការបញ្ជាក់ ឬអនុម័តជាផ្លូវការ ដោយអង្គការដែលមានគោលនយោបាយ ឬសេដ្ឋកិច្ចរួម ។ ចំពោះឯកសារស្តីពីការធ្វើសច្ចានុម័ត ការព្រមព្រៀង ការបញ្ជាក់ជាផ្លូវការឬការអនុម័ត នឹងត្រូវតំកល់ទុកនៅក្នុងទីស្នាក់ការផ្ទុកឯកសារលេខាធិការដ្ឋាន ។

២- យោងតាមវគ្គទី ១ ខាងលើ អង្គការណាមួយដែលក្លាយជាភាគីក្នុងអនុសញ្ញា ដោយពុំមែនជាសមាជិករដ្ឋាភិបាលណាមួយ ភាគីនោះនឹងត្រូវបានកំណត់កាតព្វកិច្ចទាំងអស់ ដោយអនុសញ្ញានេះ ។ ក្នុងករណីដែលអង្គការទាំងនេះ ជាសមាជិករដ្ឋាភិបាល ហើយបានក្លាយទៅជាភាគីនៃអនុសញ្ញា នោះអង្គការនិងសមាជិករដ្ឋាភិបាលត្រូវធ្វើការសំរេចចិត្ត ទៅលើការទទួលខុសត្រូវចំពោះការបំពេញកាតព្វកិច្ចរបស់ខ្លួន តាមការកំណត់របស់អនុសញ្ញា ។
ក្នុងករណីដូចគ្នានេះ អង្គការនិងសមាជិករដ្ឋាភិបាល នឹងមិនត្រូវផ្តល់អំណាចដល់ការអនុវត្តន៍សិទ្ធិចំពោះអនុសញ្ញានេះឡើយ ។

៣- យោងតាមវគ្គទី ១ ខាងលើ អង្គការនានា ត្រូវរាយការណ៍ពីការបញ្ជាក់ ឬការអនុញ្ញាតទៅលើសមត្ថភាពរបស់គេ ចំពោះការងារដែលកំណត់ដោយអនុសញ្ញា ។ អង្គការនេះ ក៏ត្រូវរាយការណ៍

ទៅទីស្នាក់ការផ្ទុកឯកសាររបស់លេខាធិការដ្ឋាន ថាតើនរណាដែលជាអ្នកទទួលខុសត្រូវ លើការរាយការណ៍ដល់ភាគី អំពីការកំណត់ចំពោះទំហំសមត្ថភាពរបស់គេ ។

## មាត្រាទី ២៣
## ការចូលរួម

១- អនុសញ្ញានេះ នឹងបើកចំហរចំពោះការចូលរួមពីប្រទេសនិមួយៗមកពីណាមីប៊ីយ៉ា (Namibia) ដែលតំណាងអោយក្រុមប្រឹក្សាអង្គការសហប្រជាជាតិសំរាប់ណាមីប៊ីយ៉ា និងអង្គការដែលមានគោលនយោបាយ រឺសេដ្ឋកិច្ចរួមបន្ទាប់ពីថ្ងៃដែលអនុសញ្ញានេះបានបញ្ចប់ការចុះហត្ថលេខាមក ។ ហើយឯកសារស្តីពីការចូលរួមនេះ នឹងត្រូវតំកល់ទុកនៅលេខាធិការដ្ឋាន ។

២- យោងតាមវគ្គទី ១ ខាងលើ នៅក្នុងឯកសារស្តីពីការចូលរួម អង្គការត្រូវរាយការណ៍អំពីទំហំសមត្ថភាព ចំពោះការងារដែលបានគ្រប់គ្រងដោយអនុសញ្ញា ។ ទន្ទឹមនឹងនេះដែរ អង្គការក៏ត្រូវបញ្ជាក់ប្រាប់ដល់ទីស្នាក់ការលេខាធិការដ្ឋាន អំពីបំលាស់ប្តូរសំខាន់ៗនៅក្នុងទំហំសមត្ថភាពរបស់គេ ។

៣- សេចក្តីចែងនៅក្នុងមាត្រាទី ២២ វគ្គទី ២ ត្រូវអនុវត្តចំពោះអង្គការដែលមានគោលនយោបាយ ឬសេដ្ឋកិច្ចរួម ដែលទទួលយល់ព្រមចំពោះអនុសញ្ញានេះ ។

## មាត្រាទី ២៤
## សិទ្ធិបោះឆ្នោត

១- លើកលែងតែសេចក្តីចែងនៅក្នុងវគ្គទី ២ នៃមាត្រានេះ ក្រៅពីនោះភាគីនិមួយៗដែលបានចុះកិច្ចសន្យាចូលជាសមាជិករបស់អនុសញ្ញានេះ ត្រូវមានសិទ្ធចូលរួមការបោះឆ្នោតបានម្តង ។

២- នៅក្នុងបញ្ហាសមត្ថភាពដូចមានចែងក្នុងមាត្រាទី ២២ វគ្គទី៣ និងមាត្រាទី២៣ វគ្គទី២ អង្គការដែលមានគោលនយោបាយ ឬសេដ្ឋកិច្ចរួម ត្រូវប្រើប្រាស់សិទ្ធរបស់គេសំរាប់បោះឆ្នោតជ្រើសរើសសមាជិកដែលមានចំនួនស្មើនឹង ចំនួនសមាជិករដ្ឋាភិបាលដែលជាភាគីរបស់អនុសញ្ញា ឬរបស់កិច្ចព្រមព្រៀង ។ ផ្ទុយទៅវិញ អង្គការនេះមិនត្រូវប្រើប្រាស់សិទ្ធរបស់គេដើម្បីបោះឆ្នោតទេ បើសិនសមាជិករដ្ឋាភិបាលរបស់គេ ប្រើប្រាស់ត្រឹមតែច្បាប់របស់គេប៉ុណ្ណោះ។

## មាត្រាទី ២៥
## ការចូលជាធរមាននៃអនុសញ្ញា

១- អនុសញ្ញានេះនឹងចូលជាធរមានក្រោយរយៈពេល ៩០ថ្ងៃបន្ទាប់ពីថ្ងៃដែលបានដាក់ជូនឯកសារទី ២០ (twentieth instrument) ស្តីពីការសច្ចានុម័ត ការទទួលយក ការបញ្ជាក់ជាផ្លូវការការអនុញ្ញាត្ត ឬការទទួលយល់ព្រម ។

២- រាល់ប្រទេសនិមួយៗឬអង្គការដែលមានគោលនយោបាយឬសេដ្ឋកិច្ចរួម ដែលទទួលយកការអនុម័ត ការបញ្ជាក់ជាផ្លូវការ ឬក៏ទទួលយល់ព្រមចំពោះអនុសញ្ញានេះ បន្ទាប់ពីថ្ងៃដែលបានដាក់ជូននូវឯកសារទី ២០ លើការសច្ចានុម័ត ការទទួលយក ការបញ្ជាក់ជាផ្លូវការ ការអនុញ្ញាត្ត ឬការទទួលយល់ព្រម នឹងចូលជាធរមានក្នុងរយៈពេល ៩០ថ្ងៃ បន្ទាប់ពីថ្ងៃដាក់នោះមក ។

៣- តាមគោលបំណងនៃសេចក្តីចែងក្នុងវគ្គទី ១ និងទី ២ ខាងលើ អង្គការដែលមាននយោបាយ ឬសេដ្ឋកិច្ចរួម ដែលបានដាក់ឯកសារណាមួយ នឹងមិនត្រូវបានយកមកបញ្ចូលបន្ថែមចំពោះការដាក់ឯកសារពាក់ព័ន្ធដែលធ្វើឡើងដោយសមាជិករដ្ឋាភិបាលនៃអង្គការដូចគ្នាឡើយ ។

## មាត្រាទី ២៦
## ការត្រៀមទុកនិងការប្រកាស

១- ការត្រៀមទុក ឬការលើកលែងពុំមានចែងក្នុងអនុសញ្ញានេះឡើយ ។

២- វគ្គទី ១ នៃមាត្រានេះ មិនធ្វើអោយរាំងស្ទះដល់ការធ្វើសេចក្តីប្រកាស ឬសេចក្តីថ្លែងការណ៍របស់ប្រទេសឬអង្គការនយោបាយសេដ្ឋកិច្ចរួមណាមួយ នៅពេលចុះហត្ថលេខា ធ្វើសច្ចានុម័ត ទទួលយក អនុញ្ញាត្ត ការបញ្ជាក់ជាផ្លូវការ ឬធ្វើការទទួលយល់ព្រមចំពោះអនុសញ្ញានេះ ។ ទោះបីយ៉ាងណាក៏ដោយ ក្នុងចំណោមច្បាប់ និងបទបញ្ញត្តិរបស់ប្រទេសឬអង្គការនយោបាយសេដ្ឋកិច្ចរួម គឺមានលក្ខណៈសមស្របនឹងការចែងនៃអនុសញ្ញា ដោយផ្តល់នូវសេចក្តីប្រកាស ឬសេចក្តីថ្លែងការណ៍ទៅតាមពាក្យសុំរបស់គេ សំដៅលើការបដិសេធ ឬផ្លាស់ប្តូរលទ្ធផលស្របច្បាប់ដូចមានចែងក្នុងអនុសញ្ញា ។

## មាត្រាទី ២៧
## ការដកពាក្យចេញពីសមាជិកភាព

ក្រោយរយៈពេលបីឆ្នាំ បន្ទាប់ពីថ្ងៃចូលជាភាគីពេញសិទ្ធនៃអនុសញ្ញា ភាគីនិមួយៗអាចដកពាក្យចេញពីសមាជិកភាពរបស់អនុសញ្ញានេះវិញនៅពេលណាមួយក៏បាន ដោយគ្រាន់តែសរសេរបញ្ជាក់ជាលាយលក្ខណ៍អក្សរ ជូនដំណឹងទៅទីស្នាក់ការតំកល់ឯកសាររបស់លេខាធិការដ្ឋាន ។

## មាត្រាទី ២៨
## ទីស្នាក់ការតំកល់ឯកសារ

អគ្គលេខាធិការរបស់អង្គការសហប្រជាជាតិ នឹងមាននាទីជាទីស្នាក់ការតំកល់ឯកសាររបស់អនុសញ្ញានិងកិច្ចព្រមព្រៀងផ្សេងៗដែលពាក់ព័ន្ធ ។

## មាត្រាទី ២៩
## អត្ថបទដែលមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់

អត្ថបទជាភាសារដើមដូចជា ភាសារអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ ដែលមានក្នុងអនុសញ្ញានេះ នឹងចាត់ទុកជាភាសារផ្លូវការត្រឹមត្រូវដូចគ្នា ។

ការចុះហត្ថលេខាខាងក្រោមជាសាក្សីឬតឹកតាងបញ្ជាក់ថា មានសិទ្ធអំណាចត្រឹមត្រូវនិងពេញលេញ បន្ទាប់ពីការចុះហត្ថលេខាលើអនុសញ្ញានេះ ។

-លើកគម្រោងប្រើប្រាស់ថវិកា សម្ភារៈ បរិក្ខារ មធ្យោបាយប្រើប្រាស់ និងកម្លាំងសម្រាប់ធ្វើសកម្មភាពតាមដំណាក់កាលនីមួយៗនៃការគ្រប់គ្រងគ្រោះមហន្តរាយដើម្បីដាក់ស្នើទៅថ្នាក់លើ និងទៅអង្គការនានា

-ធ្វើការប្រជុំមួយខែម្តងជាទៀងទាត់ ដើម្បីត្រួតពិនិត្យសកម្មភាព និងដោះស្រាយបញ្ហាដែលកើតមានរបស់ក្រុមប្រតិបត្តិការទាំងបី និងធ្វើការប្រជុំបន្ទាន់ក្នុងលក្ខណៈមានគ្រោះអាសន្ន។ ការប្រជុំនេះត្រូវធ្វើឡើងតាមការកោះអញ្ជើញរបស់ប្រធាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគ្រប់អភិបាលខេត្ត ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
អនុប្រធានទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

**ញឹម វណ្ណដា**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៤៤០....អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ពានជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តសៀមរាប

**សម្រេច**

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ពានជាតិ** ជូនលោក **ម៉ុន ថាវ៉េត** ដែលបានជួសជុលផ្លូវមួយខ្សែក្រាលគ្រួសក្រហម មានទទឹង ៧ ម៉ែត្រ បណ្តោយប្រវែង ១.០០០ ម៉ែត្រ ចេញពីផ្លូវសម្តេចព្រះសង្ឃរាជទេព វង្ស ត្រង់ចំណុច ភូមិតាកុល ទៅទល់ផ្លូវ ហ៊ុន សែន សន្តិភាព ក្នុងឃុំស្វាយដង្គំ ស្រុកសៀមរាប ដើម្បីជួយសំរួលចរាចរ ក្នុងមូលដ្ឋាន និងជាការរួមចំណែកក្នុងការអភិវឌ្ឍន៍ ក្រុងសៀមរាប ដោយចំណាយថវិកាអស់ចំនួន ១២.៥០០ ដុល្លាអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:...៤៤១...អនក្រ...បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលរាជធានីភ្នំពេញ

**សម្រេច**

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **Jockin Arputham** ប្រធានអង្គការ **Slum Dwellers International (SDI)** ដែលបានជួយជ្រោមជ្រែងដំណើរការសកម្មភាពចងក្រងសហគមន៍អ្នកក្រីក្រ នៅទីក្រុងភ្នំពេញ តាមរយៈសកម្មភាពសន្សំ-ឥណទាន និង រួមសហការបង្កើតយន្តការកែលំអសហគមន៍ ថ្នាក់សង្កាត់ កាន់តែមានប្រសិទ្ធភាពក្នុងការអនុវត្តន៍គោលការណ៍វិមជ្ឈការរបស់រាជរដ្ឋាភិបាល ចាប់តាំងពីឆ្នាំ ១៩៩៤ មក ទទួលបានលទ្ធផលល្អប្រសើរ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/៖

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០៦
នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:...៥៥២...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អភិបាលខេត្តព្រៃវែង

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន ០៥ រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកាផ្ទាល់ខ្លួន ក្នុងការកសាង ព្រះវិហារ ដងទង់ ខឿន ចាក់ដីបំពេញទីធ្លាវត្ត ធ្វើផ្លូវ និងកសាងសមិទ្ធផលនានាជាច្រើនទៀត នៅវត្តហាបូរ ឃុំមេបុណ្យ ស្រុកព្រៃវែង ខេត្តព្រៃវែង ដូចមានរាយព្រះនាមនិងនាមខាងក្រោមនេះ :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-ឯកឧត្តម **សាំង សារិន** | ទីប្រឹក្សាសម្តេច ជា ស៊ីម | ថវិកាចំនួន ១២.១២០ ដុល្លារ |
| ២-ឯកឧត្តម **ម៉ែន អ៊ាន** | អភិបាលរងទី២ ខេត្ត | ថវិកាចំនួន ១១.៥៧០ ដុល្លារ |
| ៣-លោក **ឃុន វណ្ណា** | សប្បុរសជនខេត្តបន្ទាយមានជ័យ | ថវិកាចំនួន ១០.២៥០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-ព្រះតេជគុណ **ជា មាសមេ** | ចៅអធិការវត្តហាបូរ | ថវិកាចំនួន ៥.១៦០ ដុល្លារ |
| ២-លោក **អ៊ឹង យ៉ាន** | ក្រុមប្រឹក្សាឃុំមេបុណ្យ | ថវិកាចំនួន ៥.០១០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦
**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៤៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន០៣រូប ដែលមានសទ្ធាជ្រះថ្លា ចូលរួមជួយកសាង ព្រះវិហារ កុដិថ្ម របង ខ្លោងទ្វារ និងសមិទ្ធផលនានាជាច្រើនទៀត នៅក្នុងពុទ្ធសីមាវត្តអង្គពាយមានជ័យ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល និងនៅ *វត្តស្រែអណ្តូង* ឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ដូចមានរាយព្រះនាមនិងនាមខាងក្រោមនេះ :-

**ក-មេដាយមាសស្ថាបនាជាតិ :**

-ឧបាសិកា **ហែម អ៊ឹម** រស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១០.០០០ ដុល្លារ

**ខ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-ព្រះតេជគុណ **សុខ ឆាន់** ព្រះគ្រូចៅអធិការវត្តស្រែអណ្តូង បច្ច័យ ចំនួន ៤.៦៨០ ដុល្លារ

២-ឧបាសិកា **ថៃ សឿង** ថវិកា ចំនួន ៤.៤៦០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អភិបាលខេត្តកណ្តាល និងអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៤៤៤ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃមន្ទីរធម្មការ និងសាសនា ខេត្តសៀមរាប ចំនួន១៦រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិជាច្រើនឆ្នាំកន្លងមក ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយមាសការងារ :**

-លោក **ឌុយ ហួយ** ប្រធានមន្ទីរធម្មការនិងសាសនា ខេត្តសៀមរាប

**ខ.មេដាយប្រាក់ការងារ :**

១-លោក **វណ្ណ ប៊ុណ្ណា** ប្រធានការិយាល័យ ធម្មការ និង សាសនាមន្ទីរ
២-លោកស្រី **ឌុត ទិលំយ** ប្រធានការិយាល័យ រដ្ឋបាលមន្ទីរ
៣-លោក **ខិម សាលី** ប្រធានការិយាល័យ ពុទ្ធិកសិក្សា និងបណ្ណាល័យមន្ទីរ
៤-លោក **ស្រី ស៊ីផុន** ប្រធានការិយាល័យ ធម្មការនិងសាសនា ស្រុកស្រីស្នំ
៥-លោក **ធិន សុផន** ប្រធានការិយាល័យ ធម្មការនិងសាសនា ស្រុកពួក
៦-លោក **ឃ្លីម ឆប** ប្រធានការិយាល័យ ធម្មការនិងសាសនា ស្រុកក្រឡាញ់

**គ.មេដាយសំរិទ្ធការងារ :**

១-លោកស្រី **សៅ សុខៀន** អនុប្រធានការិយាល័យ រដ្ឋបាលមន្ទីរ
២-លោកស្រី **ចាន់ សុខុន** អនុប្រធានការិយាល័យ រដ្ឋបាលមន្ទីរ
៣-លោកស្រី **ស៊ិន ស៊ីយ៉ឿន** មន្ត្រីធម្មការ និងសាសនា ស្រុកសូទ្រនិគម
៤-លោក **ទ័ាន់ ជាសុខា** អនុប្រធានការិយាល័យ ធម្មការ និងសាសនាមន្ទីរ

| | | | |
|---|---|---|---|
| ៥-លោក | **លិញ** | **ម៉ៅ** | អនុប្រធានការិយាល័យ ពុទ្ធិកសិក្សា និងបណ្ណាល័យមន្ទីរ |
| ៦-លោក | **សួង** | **ស** | មន្ត្រីធម្មការ និង សាសនា ស្រុកវ៉ារិន |
| ៧-លោក | **ម៉ៃ** | **សំអាន់** | មន្ត្រីធម្មការ និង សាសនា មន្ទីរ |
| ៨-លោក | **មាស** | **ម៉ីន** | មន្ត្រីធម្មការ និង សាសនា មន្ទីរ |
| ៩-លោក | **កុយ** | **សែ** | មន្ត្រីធម្មការ និង សាសនា ស្រុកជីក្រែង |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និង អភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។/៕

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយថ្នាក់ស្ថាបនាជាតិ** ផ្តល់ជូនសប្បុរសជន ចំនួន០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងរបងព័ទ្ធជុំវិញអធិការដ្ឋាននគរបាលស្រុកប្រាសាទបាគង អគារឈើនៅអធិការដ្ឋាន នគរបាលស្រុកស្រីស្នំ និងអគារប៉ុស្តិ៍នគរបាលរដ្ឋបាលបល្ល័ង្ក នៃស្នងការដ្ឋាននគរបាល ខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម :-

១-លោក អនុសេនីយ៍ឯក **មាស ពិដោរ** អធិការ នៃអធិការដ្ឋាន នគរបាលស្រុកស្រីស្នំ បានបរិច្ចាគថវិកា ចំនួន ៥.៧៦៨ ដុល្លារ

២-លោក អនុសេនីយ៍ឯក **មិន ចន្ថារ** អធិការ នៃអធិការដ្ឋាន នគរបាលស្រុកប្រាសាទបាគង បានបរិច្ចាគថវិកា ចំនួន ៥.៥០០ ដុល្លារ

៣-លោក អនុសេនីយ៍ទោ **ធូ ថាន** នាយប៉ុស្តិ៍ នគរបាល រដ្ឋបាលបល្ល័ង្ក នៃអធិការដ្ឋាននគរបាល ស្រុកប្រាសាទបាគង បានបរិច្ចាគថវិកា ចំនួន ៥.១០០ ដុល្លារ

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តសៀមរាប ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៤៤៦ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

.....

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេនព្រះតេជគុណ **គិន ចន្ថា** ព្រះគ្រូសូត្រស្តាំ *វត្តអង្គពពាយមានជ័យ* ដែលបានខិតខំយ៉ាងសកម្ម ក្នុងការដឹកនាំចលនាពុទ្ធបរិស័ទ ព្រមទាំងមានសទ្ធាជ្រះថ្លា ចូលរួមជួយកសាង ព្រះវិហារ កុដិថ្ម របង ខ្លោងទ្វារ និងសមិទ្ធផលនានាជាច្រើនទៀត នៅក្នុងពុទ្ធសីមាវត្តអង្គពពាយមានជ័យ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល និងនៅវត្តស្រែអណ្តូង ឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង អស់បច្ច័យ ចំនួន ៥៦៣.៥០៧ ដុល្លារ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អភិបាលខេត្តកំពង់ឆ្នាំង និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៦
**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៤៤៧៥ អនក្រ.ត្រ.ត

# អនុក្រឹត្យ
## ស្តីពីការផ្តល់មេដាយសុវត្ថារា
៣៧

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **អស្សឫទ្ធិ** ជូនលោក **ឃុត សាខន** ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ។

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល ៈ**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៤៤៩...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចំនួន ១៥៤រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច តាមកម្មវិធីនយោបាយរបស់ រាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយមាសការងារ :**

| | | | |
|---|---|---|---|
| ១-លោក | **នេត** | **មុន្នី** | ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ |
| ២-លោក | **ភាំង** | **លាងខ័ណ្ឌ** | អតីតប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ |
| ៣-លោក | **ឈីវ** | **ប៊ុនហៃ** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ មូលដ្ឋាន |
| ៤-លោក | **វង្ស** | **វ៉ូដាវុឌ្ឍ** | អនុប្រធានទី១ នាយកដ្ឋានលទ្ធកម្មសាធារណៈ |
| ៥-លោក | **ចាន់** | **ស៊ឹ** | អនុប្រធាននាយកដ្ឋានពន្ធដារ |
| ៦-លោក | **ឡាយ** | **ឫទ្ធី** | នាយករងទីចាត់ការគយ និងរដ្ឋាករ |
| ៧-លោក | **ម៉ី** | **រិន** | អនុប្រធានរតនាគារជាតិ |
| ៨-លោក | **គុយ** | **សាវុធ** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៩-លោក | **ហែម** | **ស៊ីវន** | ប្រធានការិយាល័យសារពើភ័ណ្ឌ នៃនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ |
| ១០-លោក | **មាស** | **ចាន់ដេត** | ប្រធានការិយាល័យគណនេយ្យ នៃនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ១១-លោក | **វង្ស** | **ដាវ** | ប្រធានការិយាល័យនីតិកម្មហិរញ្ញវត្ថុ |

| | | | |
|---|---|---|---|
| ១២-លោក | ម៉ុក | ស៊ីផា | ប្រធានការិយាល័យត្រួតពិនិត្យ នៃនាយកដ្ឋានបុគ្គលិក |
| ១៣-លោក | ហ៊ុន | ពិសិដ្ឋ | មន្ត្រីនាយកដ្ឋាននីតិកម្ម |
| ១៤-លោក | យឹម | យិនរ៉ុង | អតីតមន្ត្រីនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ១៥-លោក | ម៉ែន | ណារុន | អនុប្រធានការិយាល័យសារពើភ័ណ្ឌ នៃនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ |
| ១៦-លោក | ហេង | សុខណ្ណ | មន្ត្រីនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ១៧-លោក | ហុង | ថា | អតីតប្រធាននាយកដ្ឋានពន្ធដារ |
| ១៨-លោក | ស៊ឹម | អៀង | ប្រធាននាយកដ្ឋានពន្ធដារ |
| ១៩-លោក | អ៊ី | សីហា | អនុប្រធាននាយកដ្ឋានពន្ធដារ |
| ២០-លោក | អោម | ចន | ប្រធានសាខាពន្ធដារ រាជធានីភ្នំពេញ |
| ២១-លោក | តេង | ថៃ | ប្រធានសាខាពន្ធដារ ខេត្តតាកែវ |
| ២២-លោក | ទី | សុផាត | ប្រធានសាខាពន្ធដារ ខេត្តសៀមរាប |
| ២៣-លោក | ជុក | គឹមហាប់ | ប្រធានសាខាពន្ធដារ ខេត្តបាត់ដំបង |
| ២៤-លោក | នាក់ | សារី | ប្រធានសាខាពន្ធដារ ខេត្តស្វាយរៀង |
| ២៥-លោក | នាង | សារឿន | ប្រធានសាខាពន្ធដារ ខេត្តកណ្តាល |
| ២៦-លោក | ឈីវ | សារិន | ប្រធានសាខាពន្ធដារ ខេត្តកំពង់ស្ពឺ |
| ២៧-លោកស្រី | ស៊ុយ | សុខា | អតីតប្រធានសាខាពន្ធដារ ខេត្តពោធិ៍សាត់ |
| ២៨-លោក | ខឹម | យុទ្ធី | ប្រធានសាខាពន្ធដារ ខេត្តព្រៃវែង |
| ២៩-លោក | កែវ | ឆាន់ | អតីតប្រធានសាខាពន្ធដារ រាជធានីភ្នំពេញ |
| ៣០-លោក | នុត | លន | អតីតប្រធានសាខាពន្ធដារ ក្រុងកែប |
| ៣១-លោក | អឿ | សារុន | ប្រធានសាខាពន្ធដារ ខេត្តក្រចេះ |
| ៣២-លោក | ជា | ពិសិដ្ឋ | ប្រធានសាខាពន្ធដារ ខេត្តកំពត |
| ៣៣-លោក | អ៊ឹង | ឡេង | ប្រធានសាខាពន្ធដារ ខេត្តមណ្ឌលគិរី |
| ៣៤-លោក | ឯក | ចំនួនសិរី | ប្រធានសាខាពន្ធដារ ខេត្តកោះកុង |
| ៣៥-លោក | ញ៉ៀម | ម៉ុនអាន | អនុប្រធានសាខាពន្ធដារ ខេត្តស្វាយរៀង |
| ៣៦-លោក | សុខ | សារ៉ាត | អនុប្រធានសាខាពន្ធដារ ខេត្តសៀមរាប |
| ៣៧-លោក | អៀង | សុភាព | អនុប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុនៃនាយកដ្ឋានពន្ធដារ |
| ៣៨-លោក | ចំនួន | សុផល | អតីតប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តសៀមរាប |
| ៣៩-លោក | អ៊ុន | សំអុល | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តកំពង់ឆ្នាំង |
| ៤០-លោក | លុយ | ម៉ុនហុង | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តកំពង់ចាម |
| ៤១-លោក | ឈួន | ឡេង | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តព្រៃវែង |
| ៤២-លោក | គង់ | សម្បូណ៌ | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តពោធិ៍សាត់ |
| ៤៣-លោក | វស់ | លន់ | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តកណ្តាល |
| ៤៤-លោក | ពូត | សយ | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តស្វាយរៀង |
| ៤៥-លោក | គីង | ចាន់លី | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តតាកែវ |
| ៤៦-លោក | ហួត | ផែល | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តមណ្ឌលគិរី |

| | | | |
|---|---|---|---|
| ៤៧-លោក | ឈឹម | គ្រីហ្វុង | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តបន្ទាយមានជ័យ |
| ៤៨-លោក | ជា | ពារ | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តកំពង់ធំ |
| ៤៩-លោក | មាស | រដ្ឋាវុឌ្ឍ | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តព្រះវិហារ |
| ៥០-លោក | រាម | សុមាន | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុងប៉ៃលិន |
| ៥១-លោក | ទ័ត | ច័ន្ទដារី | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានីភ្នំពេញ |
| ៥២-លោក | ខាំ | សែ | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តរតនគីរី |
| ៥៣-លោក | ឡុង | ផល | អតីតប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តស្ទឹងត្រែង |
| ៥៤-លោក | អ៊ុច | តាំងគ្រីន | អនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានីភ្នំពេញ |
| ៥៥-លោកស្រី | ឡាយ | សំណាង | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តកំពង់ចាម |
| ៥៦-លោកស្រី | ស៊្រុន | គីមស្រួយ | អតីតអនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តព្រៃវែង |
| ៥៧-លោក | ញៀប | យី | ប្រធានការិ.រដ្ឋបាលនិងហិរញ្ញវត្ថុ នៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តកំពង់ឆ្នាំង |
| ៥៨-លោក | ស៊ិន | សម្ផល្លា | ប្រធានសាខាគយ និងរដ្ឋាករ ខេត្តកំពង់ចាម |
| ៥៩-លោក | គីម | ពិសិដ្ឋ | ប្រធានសាខាគយ និងរដ្ឋាករ ខេត្តកណ្តាល |
| ៦០-លោក | ស្រី | សៀង | ប្រធានសាខាគយ និងរដ្ឋាករ ខេត្តបាត់ដំបង |
| ៦១-លោក | ជា | វ៉ាន់នី | ប្រធានសាខាគយ និងរដ្ឋាករ ខេត្តស្វាយរៀង |
| ៦២-លោក | ហ៊ុច | គីមហេង | ប្រធានសាខាគយ និងរដ្ឋាករ ខេត្តបន្ទាយមានជ័យ |
| ៦៣-លោក | ឃុត | សារិនឌី | ប្រធានសាខាគយ និងរដ្ឋាករ ខេត្តព្រៃវែង |
| ៦៤-លោក | រស់ | គីមសៀន | អនុប្រធានសាខាគយ និងរដ្ឋាករ ខេត្តបន្ទាយមានជ័យ |
| ៦៥-លោក | សិរិទ្ធិ | អេង | អនុប្រធានសាខាគយ និងរដ្ឋាករ ខេត្តបន្ទាយមានជ័យ |
| ៦៦-លោក | ឆាំង | វណ្ណថា | ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក នៃទីចាត់ការគយនិងរដ្ឋាករ |
| ៦៧-លោក | សំ | សុខា | ប្រធានសាខាគយ និងរដ្ឋាករ ខេត្តកំពត |
| ៦៨-លោក | អ៊ុក | វណ្ណច័ន្ទ | អនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក នៃទីចាត់ការគយនិងរដ្ឋាករ |
| ៦៩-លោក | កែម | រ៉េន | ប្រធានសាខាគយ និងរដ្ឋាករ ខេត្តកំពង់ចាម |
| ៧០-លោក | ស៊ុក | គីមហេន | ប្រធានសាខាគយ និងរដ្ឋាករ ខេត្តបាត់ដំបង |
| ៧១-លោក | សាយ | បូរិន | ប្រធានទីស្នាក់ការគយ និងរដ្ឋាករ ក្អមសំណរ |
| ៧២-លោក | ទូ | វណ្ណា | ប្រធានទីស្នាក់ការគយ និងរដ្ឋាករ ត្រពាំងផ្លុង នៃសាខាគយ និង រដ្ឋាករខេត្តកំពង់ចាម |
| ៧៣-លោក | ចន | ចន្ថា | ប្រធានទីស្នាក់ការគយ និងរដ្ឋាករដារ |
| ៧៤-លោក | និត្យ | រិទ្ធ | ប្រធានស្តីទីទីស្នាក់ការគយ និងរដ្ឋាករ បាវិត |
| ៧៥-លោក | លី | រ៉ៃបូ | អនុប្រធានក្តាប់រួមទីស្នាក់ការគយ និងរដ្ឋាករ ស្ថានីយ៍រថភ្លើង នៃសាខាគយ និងរដ្ឋាករ ខេត្តបាត់ដំបង |
| ៧៦-លោក | ឆាំង | វ៉ាន់ថន | ប្រធានទីស្នាក់ការគយ និងរដ្ឋាករ ភ្នំដិន |
| ៧៧-លោក | យឹម | តាង | អនុប្រធានក្តាប់រួមទីស្នាក់ការគយ និងរដ្ឋាករ ជ្រៃធំ |
| ៧៨-លោក | ផន់ | ផល្លី | អនុប្រធានទីស្នាក់ការគយ និងរដ្ឋាករ ស្ថានីយ៍រថភ្លើង នៃ សាខាគយ និងរដ្ឋាករ ខេត្តបាត់ដំបង |

| | | | |
|---|---|---|---|
| ៧៩-លោក | លឹម | ចន្ទថៃ | ប្រធានរតនាគារ ខេត្តពោធិ៍សាត់ |
| ៨០-លោក | ឆេត | សាម៉ិន | ប្រធានរតនាគារ ខេត្តព្រៃវែង |
| ៨១-លោក | ម៉ុម | សារឿន | ប្រធានរតនាគារ ខេត្តរតនគិរី |
| ៨២-លោក | នួន | សុន | ប្រធានរតនាគារ ខេត្តស្វាយរៀង |
| ៨៣-លោកស្រី | ភុល | ចារិន | ប្រធានរតនាគារ ខេត្តកំពង់ចាម |
| ៨៤-លោក | ម៉ុម | ចាន់លី | ប្រធានរតនាគារ ខេត្តព្រះវិហារ |
| ៨៥-លោក | លន់ | សំអុល | ប្រធានរតនាគារ ខេត្តសៀមរាប |
| ៨៦-លោក | យុទ្ធ | ស្ទីតនី | ប្រធានរតនាគារ ខេត្តបន្ទាយមានជ័យ |
| ៨៧-លោក | ឌី | ស៊ូនិ | ប្រធានរតនាគារ ខេត្តស្ទឹងត្រែង |
| ៨៨-លោក | ខ៊ូច | សីរចំនួន | ប្រធានរតនាគារ ក្រុងព្រះសីហនុ |
| ៨៩-លោក | កេន | ចាន់ធី | អនុប្រធានរតនាគារ ខេត្តរតនគិរី |

**ខ-មេដាយប្រាក់ការងារ :**

| | | | |
|---|---|---|---|
| ១-លោក | អ៊ិន | សំបុក | ប្រធាននាយសាខាពន្ធដារ ខេត្តកំពង់ចាម |
| ២-លោក | សែម | សាខន | ប្រធានសាខាពន្ធដារ ខេត្តស្ទឹងត្រែង |
| ៣-លោក | ផន | ចុល | ប្រធានសាខាពន្ធដារ ខេត្តរតនគិរី |
| ៤-លោក | គ្រច់ | ម៉ាប់ | អនុប្រធានសាខាពន្ធដារ ខេត្តកំពង់ធំ |
| ៥-លោក | អ៊ិន | សុន | អតីតអនុប្រធានសាខាពន្ធដារ ក្រុងព្រះសីហនុ |
| ៦-លោក | ឃុត | សំអាត | អតីតអនុប្រធានសាខាពន្ធដារ ខេត្តកំពត |
| ៧-លោក | ស៊ិន | ហាក់ | អនុប្រធានសាខាពន្ធដារ ខេត្តតាកែវ |
| ៨-លោក | ចិប | ជៀន | អនុប្រធានក្តាប់រួមសាខាពន្ធដារ ខេត្តក្រចេះ |
| ៩-លោក | សុខ | សាគន្ធ | អនុប្រធានសាខាពន្ធដារ ខេត្តកំពង់ឆ្នាំង |
| ១០-លោក | ចៅ | គាំឈិញ | អតីតអនុប្រធានសាខាពន្ធដារ ខេត្តបាត់ដំបង |
| ១១-លោក | ផាន់ | សាម៉ិន | អតីតអនុប្រធានសាខាពន្ធដារ ខេត្តបាត់ដំបង |
| ១២-លោក | ឌី | សារ៉ិត | អនុប្រធានសាខាពន្ធដារ ខេត្តបន្ទាយមានជ័យ |
| ១៣-លោកស្រី | ម៉ិម | ឆ៉ាត | អតីតមន្ត្រីស្នាក់ការពន្ធដារ ស្រុកក្រគរ នៃសាខាពន្ធដារ ខេត្តពោធិ៍សាត់ |
| ១៤-លោក | ពួន | ប៉ិន | អតីតប្រធានស្នាក់ការពន្ធដារ ស្រុកល្វាឯម នៃសាខាពន្ធដារ ខេត្តកណ្តាល |
| ១៥-លោក | ឡាយ | សេខ | អនុប្រធានស្នាក់ការពន្ធដារស្រុកខ្សាច់កណ្តាល នៃសាខាពន្ធដារ ខេត្តកណ្តាល |
| ១៦-លោក | ហែម | ពៅ | ប្រធានផ្នែករដ្ឋបាលនិងបុគ្គលិក នៃសាខាពន្ធដារ ខេត្តពោធិ៍សាត់ |
| ១៧-លោក | ឃុត | សាម៉ុន | ប្រធានស្នាក់ការពន្ធដារ ស្រុកស្វាយរៀង |
| ១៨-លោក | ឃួន | ណាត | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តកំពង់ស្ពឺ |
| ១៩-លោក | នួច | ហឿន | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តក្រចេះ |
| ២០-លោក | ម៉ី | រិន | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុងកែប |
| ២១-លោក | ឆន់ | មានប៊ុន | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តកោះកុង |

| | | | |
|---|---|---|---|
| ២២-លោក | ម៉ី | ម៉ៅ | អនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តកំពង់ឆ្នាំង |
| ២៣-លោក | ត្រាក់ | ហៀក | អនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តតាកែវ |
| ២៤-លោកស្រី | ស្វាយ | ចំនួស៊ីសុផា | អនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តព្រះវិហារ |
| ២៥-លោក | ម៉ែន | សុវណ្ណ | អនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តពោធិ៍សាត់ |
| ២៦-លោក | ជា | ឈន | ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ នៃមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្តពោធិ៍សាត់ |
| ២៤-លោកស្រី | ស្វាយ | ចំនួស៊ីសុផា | អនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តព្រះវិហារ |
| ២៥-លោក | ម៉ែន | សុវណ្ណ | អនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តពោធិ៍សាត់ |
| ២៦-លោក | ជា | ឈន | ប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ នៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តពោធិ៍សាត់ |
| ២៧-លោក | ស | ស្រេង | ប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ នៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានីភ្នំពេញ |
| ២៨-លោក | ឈឹម | ឡេងឆាយ | មន្ត្រីទទួលបន្ទុកសារពើភ័ណ្ឌ នៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានីភ្នំពេញ |
| ២៩-លោក | អេន | សំអុល | ប្រធានសាខាគយ និងរដ្ឋាករ ខេត្តតាកែវ |
| ៣០-លោក | គង់ | សំ | ប្រធានស្តីទីសាខាគយ និងរដ្ឋាករ ខេត្តកោះកុង |
| ៣១-លោក | ស៊ុំ | ស៊ុំជេត | អនុប្រធានសាខាគយ និងរដ្ឋាករ ខេត្តបន្ទាយមានជ័យ |
| ៣២-លោក | ឌៀង | សុមេធ | អតីតអនុប្រធានសាខាគយ និងរដ្ឋាករ ក្រុងព្រះសីហនុ |
| ៣៣-លោក | នី | សឿន | អនុប្រធានសាខាគយ និងរដ្ឋាករ ខេត្តកោះកុង |
| ៣៤-លោក | ហ៊ុំ | សុផាត | អនុប្រធានសាខាគយ និងរដ្ឋាករ ខេត្តកំពត |
| ៣៥-លោក | ជិត | សុខា | អនុប្រធានសាខាគយ និងរដ្ឋាករ ខេត្តកំពត |
| ៣៦-លោក | ម៉ិត | សារឿន | អនុប្រធានសាខាគយ និងរដ្ឋាករ ខេត្តតាកែវ |
| ៣៧-លោក | កាយ | ម៉ែត | អនុប្រធានសាខាគយ និងរដ្ឋាករ ខេត្តកណ្តាល |
| ៣៨-លោក | យឹម | ជូម៉េង | អនុប្រធានសាខាគយ និងរដ្ឋាករ ខេត្តព្រៃវែង |
| ៣៩-លោក | ហ៊ុន | ទាសនា | អនុប្រធានសាខាគយ និងរដ្ឋាករ ខេត្តស្វាយរៀង |
| ៤០-លោក | ស្រ៊ី | នី | អតីតប្រធានសាខាគយ និងរដ្ឋាករ ខេត្តតាកែវ |
| ៤១-លោក | នួន | ឡុន | ប្រធានទីស្នាក់ការគយ និងរដ្ឋាករស្រែអំបិល នៃសាខាគយ និងរដ្ឋាករខេត្តកោះកុង |
| ៤២-លោក | ហ៊ុយ | សុជាតិ | ប្រធានទីស្នាក់ការគយ និងរដ្ឋាករអូរយ៉ាដាវ នៃសាខាគយ និងរដ្ឋាករខេត្តស្ទឹងត្រែង |
| ៤៣-លោក | គួ | ខេមរិន្ទ | ប្រធានទីស្នាក់ការគយ និងរដ្ឋាករកំពង់ក្រសាំង នៃសាខាគយ និងរដ្ឋាករខេត្តតាកែវ |
| ៤៤-លោក | ឈឹម | ចំនួថា | អនុប្រធានទីស្នាក់ការគយ និងរដ្ឋាករក្អមសំណរ នៃសាខាគយ និងរដ្ឋាករខេត្តកណ្តាល |
| ៤៥-លោក | ហុង | គីមហេង | អនុប្រធានទីស្នាក់ការគយ និងរដ្ឋាករកំពង់ក្រសាំង នៃសាខាគយ និងរដ្ឋាករខេត្តតាកែវ |

| | | | |
|---|---|---|---|
| ៤៦-លោក | ផូង | វណ្ណា | អនុប្រធានទីស្នាក់ការគយ និងរដ្ឋាករបាវិត នៃសាខាគយ និងរដ្ឋាករខេត្តស្វាយរៀង |
| ៤៧-លោក | ខែក | វ៉េន | អតីតប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក រតនាគារជាតិ |
| ៤៨-លោក | ឌូច | រ័ត្នមុនី | ប្រធានរតនាគារ ខេត្តកំពង់ស្ពឺ |
| ៤៩-លោក | សុខ្ខ | ឃុនថាល់ | ប្រធានរតនាគារ ក្រុងប៉ៃលិន |
| ៥០-លោក | គ្រី | ឡុងហេង | អនុប្រធានរតនាគារ ខេត្តកំពង់ចាម |
| ៥១-លោក | ឡេង | គីមលៀង | អនុប្រធានរតនាគារ ខេត្តពោធិ៍សាត់ |
| ៥២-លោក | ជា | រ៉ាត | អនុប្រធានរតនាគារ ខេត្តស្វាយរៀង |
| ៥៣-លោក | ពុយ | យ៉ាត | អនុប្រធានរតនាគារ ខេត្តស្ទឹងត្រែង |

**គ-មេដាយសេវកម្មការងារ :**

| | | | |
|---|---|---|---|
| ១-លោក | ច្រឹក | ឆាង | ប្រធានផ្នែកប្រថាប់ត្រានិងតែមប្រើនៃសាខាពន្ធដារខេត្តតាកែវ |
| ២-លោក | ពៅ | ឌិន | អតីតប្រធានផ្នែករដ្ឋបាលនិងបុគ្គលិក នៃសាខាពន្ធដារខេត្តព្រៃវែង |
| ៣-លោក | ហាប់ | ម៉ុនលី | ប្រធានផ្នែករដ្ឋបាលនិងបុគ្គលិក នៃសាខាពន្ធដារ ខេត្តកំពត |
| ៤-លោក | អេង | វុត្ថា | ប្រធានផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ នៃសាខាពន្ធដារខេត្តកំពង់ចាម |
| ៥-លោក | អ៊ុំ | សែម | ប្រធានផ្នែករដ្ឋបាល និងបុគ្គលិក នៃសាខាពន្ធដារខេត្តស្វាយរៀង |
| ៦-លោកស្រី | មាស | រ៉ាវី | ប្រធានប៉ុស្តិ៍គណនេយ្យដើមខ្សែ នៃសាខាពន្ធដារខេត្តស្វាយរៀង |
| ៧-លោក | នង | សារុន | ប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ នៃមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្តមណ្ឌលគិរី |
| ៨-លោក | សៅ | សាវ៉េត | ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ នៃមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រុងប៉ៃលិន |
| ៩-លោក | ឈឹម | សំអាង | ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ នៃមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្តស្វាយរៀង |
| ១០-លោក | ជា | សុផល | ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ នៃមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្តបាត់ដំបង |
| ១១-លោក | មាស | ហ៊ាង | ប្រធានការិយាល័យសារពើភ័ណ្ឌ នៃមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្តកណ្តាល |
| ១២-លោក | ឆុំ | សារិន | ប្រធានរតនាគារ ខេត្តមណ្ឌលគិរី |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០៦

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៤៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនលោកវរសេនីយ៍ឯក BRIAN G. JACKSON, MSM , CD អនុព័ន្ធយោធា នៃប្រទេសកាណាដា ដែលមានស្នាដៃក្នុងការបំពេញភារកិច្ច នៅព្រះរាជាណាចក្រកម្ពុជា សំរេចបានលទ្ធផលល្អប្រសើរ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចក្នុងមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៤០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

៣៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនលោកវរសេនីយ៍ឯក **Alexander A .V Zorin** អនុព័ន្ធយោធាអមស្ថានទូតសហព័ន្ធរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃក្នុងការមកបំពេញភារកិច្ច នៅកម្ពុជា សំរេចបានលទ្ធផលល្អប្រសើរ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួល បានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:......៤៥១.....អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៥/០៩ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និង នេសាទ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ អស្សឫទ្ធិ ជូនជនាញការបរទេស ចំនួន ០២រូប ដែលមានស្នាដៃល្អក្នុងការធ្វើសហប្រតិបត្តិការជួយអភិវឌ្ឍន៍ សាលាជាតិកសិកម្ម កំពង់ចាម ដូចមានរាយនាមខាងក្រោម :-

1-Mr.JOHN SILER អ្នកសម្របសម្រួលគម្រោងសាលាជាតិ កសិកម្ម កំពង់ចាម
2-Ms.ITO MISAKI អ្នកស្ម័គ្រចិត្តជប៉ុន តាមរយៈអង្គការ (JICA)

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ៥ ឆ្នាំ២០០៦

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៥៧ អនក្រ.តក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## ស ម្រ េ ច

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១-វរសេនីយ៍ទោ | **ឃី** | **នៃយ៉ា** | អត្តលេខ ០១១៦៩៤ | នាយទាហានការពារផ្ទាល់ |
| ២-វរសេនីយ៍ទោ | **សរ** | **សារ៉ន** | អត្តលេខ ០០៣៧៨៦ | នាយទាហានការពារផ្ទាល់ |
| ៣-វរសេនីយ៍ទោ | **ឡាត់** | **ជុំ** | អត្តលេខ ០០៤០៧៧ | នាយទាហានការពារផ្ទាល់ |
| ៤-វរសេនីយ៍ទោ | **ជ៉ា** | **សារឿន** | អត្តលេខ ០០៣៣២៦ | នាយទាហានការពារផ្ទាល់ |
| ៥-វរសេនីយ៍ទោ | **ហួន** | **ម៉ិនធឿន** | អត្តលេខ ០០១១៩៤ | នាយទាហានការពារផ្ទាល់ |
| ៦-វរសេនីយ៍ទោ | **ឡាំ** | **ម៉ិនលុច្ស** | អត្តលេខ ០២១១៩៧ | នាយទាហានការពារផ្ទាល់ |
| ៧-វរសេនីយ៍ទោ | **ហួត** | **សាបាន** | អត្តលេខ ០០៤០៦០ | នាយទាហានការពារផ្ទាល់ |

| | | | | | |
|---|---|---|---|---|---|
| ៨-វរសេនីយ៍ទោ | សោម | សួគ៌ | អត្តលេខ | ០០៤០០២ | នាយទាហានការពារផ្ទាល់ |
| ៩-វរសេនីយ៍ទោ | នូ | គិរត្ន | អត្តលេខ | ០០៤០៩៧ | នាយទាហានការពារផ្ទាល់ |
| ១០-វរសេនីយ៍ទោ | មុិញ | ពិសិដ្ឋ | អត្តលេខ | ០១២៣៩១ | នាយទាហានការពារផ្ទាល់ |
| ១១-វរសេនីយ៍ទោ | សុីម | ផាន | អត្តលេខ | ០០៥២៧១ | នាយទាហានការពារផ្ទាល់ |
| ១២-វរសេនីយ៍ទោ | សួន | សៅណារ៉ា | អត្តលេខ | ០០៤០៣៩ | នាយទាហានការពារផ្ទាល់ |
| ១៣-វរសេនីយ៍ទោ | មុំ | មុើ | អត្តលេខ | ០០៤០០៦ | នាយទាហានការពារផ្ទាល់ |
| ១៤-វរសេនីយ៍ទោ | ចឹត | តាន | អត្តលេខ | ០០៣៧៧៥ | នាយទាហានការពារផ្ទាល់ |
| ១៥-វរសេនីយ៍ទោ | ណាំ | គិរុណា | អត្តលេខ | ០០៤០២៧ | នាយទាហានការពារផ្ទាល់ |
| ១៦-វរសេនីយ៍ទោ | ឈិន | ទូច | អត្តលេខ | ០០២៤១០ | នាយទាហានការពារផ្ទាល់ |
| ១៧-វរសេនីយ៍ទោ | អុឹម | ចណ្ណឆេង | អត្តលេខ | ០០៤០៨៦ | នាយទាហានការពារផ្ទាល់ |
| ១៨-វរសេនីយ៍ទោ | សោម | សួគ៌និដា | អត្តលេខ | ០០២៣២២ | នាយទាហានការពារផ្ទាល់ |
| ១៩-វរសេនីយ៍ទោ | ឌឹម | សារី | អត្តលេខ | ០០២៣៣៧ | នាយទាហានការពារផ្ទាល់ |
| ២០-វរសេនីយ៍ទោ | យចំ | បុិនថាត | អត្តលេខ | ០០៤០៨០ | នាយទាហានការពារផ្ទាល់ |
| ២១-វរសេនីយ៍ទោ | ជឹម | ខេមរា | អត្តលេខ | ០០៤០៤១ | នាយទាហានការពារផ្ទាល់ |
| ២២-វរសេនីយ៍ទោ | លឹម | រចនា | អត្តលេខ | ០០១០៦៤ | នាយទាហានការពារផ្ទាល់ |
| ២៣-វរសេនីយ៍ទោ | ទុន | ចាន់ដារ៉ា | អត្តលេខ | ០០៤០៥១ | នាយទាហានការពារផ្ទាល់ |
| ២៤-វរសេនីយ៍ទោ | ធី | សម្បត្តិ | អត្តលេខ | ០០៣៧៨៣ | នាយទាហានការពារផ្ទាល់ |
| ២៥-វរសេនីយ៍ទោ | សុខ | សំរាំង | អត្តលេខ | ០០៣០៣៣ | នាយទាហានការពារផ្ទាល់ |
| ២៦-វរសេនីយ៍ទោ | បេ | សុខណ្ណដេត | អត្តលេខ | ០៤៣៩៦២ | នាយទាហានការពារផ្ទាល់ |
| ២៧-វរសេនីយ៍ទោ | បុិន | ឆាយ | អត្តលេខ | ០០៥១៧៣ | នាយទាហានការពារផ្ទាល់ |
| ២៨-វរសេនីយ៍ទោ | សួន | សុខរ៉ា | អត្តលេខ | ០០៤០០៨ | នាយទាហានការពារផ្ទាល់ |
| ២៩-វរសេនីយ៍ទោ | សុិន | ហួរ | អត្តលេខ | ០២១១០៩ | នាយទាហានការពារផ្ទាល់ |
| ៣០-វរសេនីយ៍ទោ | ឃួន | សុគន្ធ | អត្តលេខ | ០១១៨១៦ | នាយទាហានការពារផ្ទាល់ |
| ៣១-វរសេនីយ៍ទោ | ជិន | ណារ្រី | អត្តលេខ | ០០៣៣៣៨ | នាយទាហានការពារផ្ទាល់ |
| ៣២-វរសេនីយ៍ទោ | ម៉ឹម | សុីថា | អត្តលេខ | ០០៣៣៣៦ | នាយទាហានការពារផ្ទាល់ |
| ៣៣-វរសេនីយ៍ទោ | អុិត | សំ | អត្តលេខ | ០០៤០៩១ | នាយទាហានការពារផ្ទាល់ |

| | | | | | |
|---|---|---|---|---|---|
| ៣៤-វរសេនីយ៍ទោ | ឃិន | ច័ន្ទធួន | អត្តលេខ | ០០៤០៩២ | នាយទាហានការពារផ្ទាល់ |
| ៣៥-វរសេនីយ៍ទោ | ប៊ុន | ដារ៉ា | អត្តលេខ | ០០៥២៧៦ | នាយទាហានការពារផ្ទាល់ |
| ៣៦-វរសេនីយ៍ទោ | ស៊ឹម | ប៊ុនថន | អត្តលេខ | ០១៧៦៦១ | នាយទាហានការពារផ្ទាល់ |
| ៣៧-វរសេនីយ៍ទោ | សេត | សៀងហៃ | អត្តលេខ | ០១១៦៩៩ | នាយទាហានការពារផ្ទាល |
| ៣៨-វរសេនីយ៍ទោ | ព្រាប | សារិន | អត្តលេខ | ០០៤០៣៧ | នាយទាហានការពារផ្ទាល់ |
| ៣៩-វរសេនីយ៍ទោ | ឃួន | ចណ្ណា | អត្តលេខ | ០០៤០១៣ | នាយទាហានការពារផ្ទាល់ |
| ៤០-វរសេនីយ៍ទោ | អន | ណាគ្រី | អត្តលេខ | ០១១៦២៩ | នាយទាហានការពារផ្ទាល់ |
| ៤១-វរសេនីយ៍ទោ | គង់ | សាង | អត្តលេខ | ០០២០៩០ | នាយទាហានការពារផ្ទាល់ |
| ៤២-វរសេនីយ៍ទោ | ឡេង | ប៊ុណ្ណា | អត្តលេខ | ២៣២៤០២ | នាយទាហានការពារផ្ទាល់ |

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ....៤៥៣....អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខងារ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## ស ម្រេ ច

**មាត្រា១** : ត្រូវបានតែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម :

១-វរសេនីយ៍ឯក **យ៉ាង តិរុណ** អត្តលេខ ០០៣៨៧២ ជា នាយការិយាល័យសេនានុព័ន្ធ និងជាទីប្រឹក្សាយោធាអមស្ថានទូតកម្ពុជាប្រចាំទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ជំនួសលោកវរសេនីយ៍ឯក **តែប សម្បត្តិ** ដែលត្រូវចប់អាណត្តិ

២-វរសេនីយ៍ទោ **អ៊ិន សុផាន់ណា** អត្តលេខ ០២១៦៩១ ជា នាយការិយាល័យសេនានុព័ន្ធ និងជា ទីប្រឹក្សាយោធាអមស្ថានទូតកម្ពុជាប្រចាំទីក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម ជំនួស លោកវរសេនីយ៍ឯក **ពិន សេដ្ឋទូល** ដែលត្រូវចប់អាណត្តិ

៣-វរសេនីយ៍ទោ **ឈឹម សារុំ** អត្តលេខ ០០៣៣១៦ ជា នាយការិយាល័យសេនានុព័ន្ធ និងជា ទីប្រឹក្សាយោធាអមស្ថានទូតកម្ពុជាប្រចាំទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន ជំនួស លោកវរសេនីយ៍ឯក **អៀង លីសត្ថិ** ដែលត្រូវចប់អាណត្តិ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៤៥៤ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការតម្លើងឋានន្តរស័ក្ដិ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០៤ ស្ដីពីការកែសម្រួលរចនាសម្ព័ន្ធ និងប្ដូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## ស ម្រ េ ច

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម :

១-វរសេនីយ៍ទោ **អ៊ុន សុផាន់ណា** អត្តលេខ ០២១៦៩១ នាយការិយាល័យសេនាធិការ និងជាទីប្រឹក្សា យោធាអមស្ថានទូតកម្ពុជាប្រចាំទីក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម

២-វរសេនីយ៍ទោ ឈឹម សារុំ អត្តលេខ ០០៣៣១៦ នាយការិយាល័យសេនានុព័ន្ធ និងជាទីប្រឹក្សាយោធាអមស្ថានទូតកម្ពុជាប្រចាំទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:...៤៥៥...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី
៣៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូននាយទាហាន នៃក្រុមបេសកកម្ម យោធាបារាំង ចំនួន ០៥រូប ដែលមកបំពេញភារកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីជួយបណ្តុះបណ្តាល និងអភិវឌ្ឍន៍កងយោធពលខេមរភូមិន្ទ ដូចមានរាយនាមខាងក្រោម :-

១-វរសេនីយ៍ទោ **Antoine FONT** ប្រធានគំរោងសហប្រតិបត្តិការសាលាបណ្តុះបណ្តាលនាយទាហានថ្នាតពង
២-វរសេនីយ៍ទោ **Marc GHIRINGHELLI** ប្រធានគំរោងសិក្សាភាសាបារាំង និងការគ្រប់គ្រងធនធានមនុស្ស
៣-វរសេនីយ៍ត្រី **Christophe FIX** ប្រធានទទួលបន្ទុករដ្ឋបាល និងសំរបសំរួលកិច្ចការយោធា
៤-វរសេនីយ៍ទោ **Jean- François LENGELE** ប្រធានគំរោងទីប្រឹក្សាសេនាធិការអមកងរាជអាវុធហត្ថលើផ្ទៃប្រទេស
៥-វរសេនីយ៍ទោ **Jean LANGLOIS d'ESTAINTOT** ជំនាញការយោធា គំរោងបណ្តុះបណ្តាលនាយទាហានសាលាថ្នាតពង

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៦
**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តតាកែវ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនព្រះសង្ឃ និងសប្បុរសជន ចំនួន ០៤រូប ដែលបានបរិច្ចាគថវិកា ជួយកសាងសមិទ្ធផលផ្សេងៗ នៅវត្តតាតែ ឃុំញ៉ែងញ៉ង ស្រុកត្រាំកក់ ខេត្តតាកែវ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :**

១-ព្រះតេជគុណ **ខេព សំណាង** ចៅអធិការវត្តតាតែ មានស្នាព្រះហស្តល្អក្នុងការដឹកនាំកសាងវត្ត

២-ឯកឧត្តម **សុះ យ៉ុន** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានជួយកសាង អស់ថវិកា ចំនួន ១០០.០០០ ដុល្លារ

៣-ឯកឧត្តម អ្នកឧកញ៉ា បណ្ឌិត **ចន់ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជួយកសាង អស់ថវិកា ចំនួន ១០០.០០០ ដុល្លារ

**ខ.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :**

-លោក បណ្ឌិត **សំ សារ៉ែន** នាយកសាលា កសិកម្ម កំពង់ចាម បានជួយកសាង អស់ថវិកា ចំនួន ៨០.០០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ:.......៥៥.....សសរ

## សេចក្តីសំរេច

## ស្តីពី

## ការបង្កើតក្រុមគម្រោងធ្វើអោយប្រសើរឡើងនូវរាជកិច្ច

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០០៤ ស្តីពីឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើតអង្គភាពសំរបសំរួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលមាត្រា ៥ នៃអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី២១ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើតអង្គភាពសំរបសំរួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌

- បានឃើញអនុក្រឹត្យលេខ ១២៨ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងគម្រោងកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌
- បានឃើញសេចក្តីសំរេចលេខ ០៦០/០៦ សសរ ក.ក.ច.ន.យ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ ២០០៦ ស្តីពីការបង្កើតក្រុមប្រតិបត្តិគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា
- យោងតាមការចាំបាច់នៃការងារ

## សម្រេច

**ប្រការ១ ..**

បង្កើតក្រុមគម្រោងធ្វើអោយប្រសើរឡើងនូវរាជកិច្ច ដើម្បីអនុវត្តគម្រោងទី ២ ស្តីពីការធ្វើអោយប្រសើរឡើងនូវចីរភាពនៃរាជកិច្ច និងទិន្នន័យច្បាប់នៃគម្រោងសិទ្ធិទទួលបានយុត្តិធម៌ នៅកម្ពុជា ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០៦ របស់រាជរដ្ឋាភិបាល ដែលគាំទ្រដោយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ។

**ប្រការ ២ ..**

ក្រុមគម្រោងធ្វើអោយប្រសើរឡើងនូវរាជកិច្ច មានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១. លោកជំទាវ ឆាយ វ៉ាន់នឿន | អគ្គនាយកអគ្គនាយកដ្ឋានរាជកិច្ច | ប្រធាន |
| ២. លោក តូច សុផារ៉ា | អគ្គនាយករងអគ្គនាយកដ្ឋានរាជកិច្ច | អនុប្រធាន |
| ៣. លោកស្រី សម សុភាព | ប្រធាននាយកដ្ឋានរាជកិច្ច | សមាជិក |
| ៤. លោកស្រី ងិន ផលរត្ន័ | ប្រធានលេខាធិការដ្ឋាន | ជំនួយការ |

**ប្រការ ៣ ..**

សមាជិកក្រុមគម្រោងលើកកំពស់ការយល់ដឹងសិទ្ធិមូលដ្ឋាននៅកំរិតសហគមន៍ បំពេញការងារតាមការចាត់តាំងរបស់ប្រធានក្រុមគម្រោង។

ក្នុងការអនុវត្តគម្រោង ប្រធានអាចស្នើសុំការចូលរួមពីមន្ត្រីដទៃទៀតនៃអគ្គនាយកដ្ឋានរាជកិច្ច និងក្រសួង ស្ថាប័នពាក់ពន្ធ័។

**ប្រការ ៤ ..**

ក្រុមគម្រោងធ្វើអោយប្រសើរឡើងនូវរាជកិច្ច មានភារកិច្ចជាអាទិ៍ដូចខាងក្រោម :

- សិក្សារៀបចំកម្មវិធីសកម្មភាព សម្រាប់អនុវត្តគម្រោងធ្វើអោយប្រសើរឡើងនូវរាជកិច្ចដាក់ជូននាយកគម្រោងថ្នាក់ជាតិពិនិត្យ ដាក់ជូនក្រុមប្រតិបត្តិគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា ពិនិត្យ និងសម្រេច
- សិក្សារៀបចំ និងអនុវត្តផែនការសកម្មភាព ពង្រឹងសមត្ថភាពនៃអគ្គនាយកដ្ឋានរាជកិច្ច និងស្ថាប័នទទួលបន្ទុកនៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើអោយមាននិរន្តរភាពលើការរៀបចំ និងការផ្សព្វផ្សាយរាជកិច្ចក្នុងទម្រង់ជាការបោះពុម្ព និងតាមអេឡិចត្រូនិច
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំ បង្កើត និងអនុវត្តកម្មវិធីអប់រំច្បាប់ នៅថ្នាក់ខេត្ត ស្រុក និងឃុំ
- ធ្វើរបាយការណ៍ជាប្រចាំអំពីការអនុវត្តកម្មវិធីរបស់ខ្លួនជូនចនាយកគម្រោងថ្នាក់ជាតិពិនិត្យ ដាក់ជូនក្រុមប្រតិបត្តិគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា ពិនិត្យ និងសម្រេច
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់នាយកគម្រោងថ្នាក់ជាតិ និងក្រុមប្រតិបត្តិគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា ។

**ប្រការ ៥ .-**

ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច អគ្គនាយកនៃអគ្គនាយកដ្ឋានរាជកិច្ច ប្រធាននាយកដ្ឋានបុគ្គលិក អស់លោក លោកស្រីដូចមានឈ្មោះក្នុងប្រការ ២ ខាងលើ និងអង្គភាពពាក់ព័ន្ធនៃទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ០៦ ឆ្នាំ២០០៦

**សុខ អាន**

**ចំលងជូន:**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- ក្រសួងយុត្តិធម៌
- ក្រសួងមហាផ្ទៃ
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៤០៣ សហវ.ប្រក

ភ្នំពេញ, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៦

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតក្រុមដឹកនាំការងាររៀបចំពិនិត្យកែលំអរ កម្មវិធីសកម្មភាពអាទិភាព និង បើកផ្តល់សាច់ប្រាក់

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**
**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**
**រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ**
**រដ្ឋមន្ត្រីក្រសួងកិច្ចការនារី**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

. បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

. បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

. បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ

. បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី

បានឃើញ ព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខនស/រកម/ ១២៩៩/១៥ ចុះថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ នៃ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០២

បានឃើញ ព្រះរាជក្រមលេខ នស/រកម/១០០៤/០០៥ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ២០០៤

បានឃើញ អនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បានឃើញ អនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បានឃើញ ប្រកាសអន្តរក្រសួងលេខ ០០២សហវ.ប្រក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ២០០៥ ស្តីពីការបង្កើតក្រុមដឹកនាំការងារបើកផ្តល់សាច់ប្រាក់ដល់កិច្ចអភិវឌ្ឍន៍វិស័យសង្គម

យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ និង ក្រសួងកិច្ចការនារី

## សំរេច

**ប្រការ១**: បង្កើតក្រុមដឹកនាំការងាររៀបចំពិនិត្យកែលំអកម្មវិធីសកម្មភាពអាទិភាព និង បើកផ្តល់សាច់ប្រាក់សំរាប់ក្រសួងអាទិភាព ដែលមានសមាជិក ដូចរាយនាមខាងក្រោម:

| | | |
|---|---|---|
| ១. ឯកឧត្តម អូន ពន្ធ័មុនីរត្ន័ | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២ ឯកឧត្តម ជុំ គឹមឡេង | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៣. ឯកឧត្តម ទិន ឃន | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរតនាគារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. ឯកឧត្តម អ៊ុំន ចន្ថា | រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៥. ឯកឧត្តម អ៊ុក សុខុន | អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| ៦. ឯកឧត្តម វ៉ន្ន សារិន | អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| ៧. ឯកឧត្តម តែ គុយស៊ាង | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល | សមាជិក |
| ៨. ឯកឧត្តម ជា អឿង | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៩. ឯកឧត្តម គ៉ី សារ៉ុន | អគ្គនាយក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| ១០. ឯកឧត្តម ជួប សំរោត | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១១.ឯកឧត្តម ឡៅ ហ៊ុម | អគ្គនាយកបណ្តុះបណ្តាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១២.លោកស្រី យក់ សម្បត្តិ | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល | សមាជិក |
| ១៣.លោក សុខ សារាវុឌ្ឍ | ប្រធាននាយកដ្ឋានថវិកា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១៤.លោក ឡូច ឡេង | ប្រធាននាយកដ្ឋានហិរញ្ញកិច្ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៥.លោក ឆាយ ទុង | ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ២**: លេខាធិការដ្ឋានរបស់ក្រុមដឹកនាំការងាររៀបចំពិនិត្យកែលំអកម្មវិធីសកម្មភាពអាទិភាព និង បើកផ្តល់សាច់ប្រាក់សំរាប់ក្រសួងអាទិភាព ត្រូវបានបង្កើត និង មានសមាជិក ដូចខាងក្រោម:

| | | |
|---|---|---|
| ១. លោក ហ៊ីង សុវណ្ណ | អនុប្រធានទី១រតនាគារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. លោក ឡូ វាសនាគិរី | ប្រធាននាយកដ្ឋានផែនការ_ព័ត៌មានក្រសួងសុខាភិបាល | សមាជិក |
| ៣. លោក ជា គឹមឡុង | ប្រធាននាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល | សមាជិក |

៤. លោក ឈី សន្ធិ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

៥. លោក ខួច ម៉ុនលី ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សមាជិក

៦. លោក សាម សាយ ប្រធាននាយកដ្ឋានផ្គត់ផ្គង់-ហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

៧. លោក ជួរ ទុឌ្ឍី ប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សមាជិក

៨. លោក ស្វាយ ទិចិត្រ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរដ្ឋ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សមាជិក

៩. លោក អៀង ស៊ុនលី អនុប្រធានទី១ នាយកដ្ឋានហិរញ្ញកិច្ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១០. លោក ឈឹម សារ៉េត អនុប្រធានរតនាគារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១១. លោក ទន្សូ វ៉ិជាទុល្ស អនុប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

១២. លោកស្រី មាស សុខុម អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និង ផ្គត់ផ្គង់ ក្រសួងកិច្ចការនារី សមាជិក

១៣. លោក ស្រី ទុធ ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួងសុខាភិបាល សមាជិក

១៤.លោក ម៉ូ ចន្ទ័បូរ៉ា ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១៥. លោក ហ៊ុយ រ៉ាឌី ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

១៦. លោក ខិន ឫទ្ធី ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

១៧. លោក សេខ ចំរើន ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួងការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ សមាជិក

១៨. លោក ជូ ម៉ារី ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

១៩. លោក ទង់ ពេជ្រ ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួងកិច្ចការនារី សមាជិក

២០.លោកស្រី នាយ អ៊ឹម មន្ត្រីរៀបចំកម្មវិធីសកម្មភាពជាអាទិភាព PAP ក្រសួងកិច្ចការនារី សមាជិក

**ប្រការ៣:** ក្រុមដឹកនាំការងាររៀបចំពិនិត្យកែលំអកម្មវិធីសកម្មភាពអាទិភាព និង បើកផ្ដល់សាច់ប្រាក់សំរាប់ក្រសួងអាទិភាព ត្រូវទទួលបន្ទុក:

- កំណត់អោយបានអំពីមូលហេតុដែលនាំអោយការបើកផ្តល់សាច់ប្រាក់មានកំរិតទាប សំរាប់ក្រសួងអាទិភាព ព្រមទាំងផ្តល់អនុសាសន៍ដើម្បីកែលំអអោយកាន់តែប្រសើរឡើង
- ពិនិត្យ និងតាមដានការអនុវត្តន៍ថវិកាឆ្នាំ ជាពិសេសជំពូក ១៣ និង ជំពូក១១
- រៀបចំផែនការសកម្មភាពរយៈពេលខ្លីស្តីពីការបង្កើនសន្ទុះនៃការបើកផ្តល់សាច់ប្រាក់ ដោយផ្អែកតាមការសំរេចចិត្តនៃគោលនយោបាយអភិវឌ្ឍន៍វិស័យសង្គម ។
- កំណត់អោយបាននូវការលំបាកនានា និងពិនិត្យកែលំអកម្មវិធីសកម្មភាពអាទិភាព (PAP) របស់សាមីក្រសួង
- រៀបចំផែនការលំអិតដើម្បីកែលំអប្រពន្ធ័កម្មវិធីសកម្មភាពជាអាទិភាព (PAP) និង ពិនិត្យពិចារណាពីតំរូវការផ្នែកច្បាប់ដែលអាចអនុញ្ញាតដល់ការកែលំអកម្មវិធីសកម្មភាពជាអាទិភាពអោយទៅជាការគ្រប់គ្រងថវិកាតាមកម្មវិធី (Program Based Budgeting)

<u>ប្រការ៤</u>:

- លេខាធិការដ្ឋានមានសិទ្ធិអញ្ជើញជំនាញការបរទេសពាក់ព័ន្ធចូលរួមតាមការចាំបាច់ និង មានភារកិច្ចរៀបចំលិខិតអញ្ជើញចូលរួមប្រជុំដល់គ្រប់សមាជិកនៃក្រុមដឹកនាំការងាររៀបចំពិនិត្យកែលំអកម្មវិធីសកម្មភាពអាទិភាព និង បើកផ្តល់សាច់ប្រាក់ និងរៀបចំខ្លឹមសាររបៀបវារៈ កំណត់ហេតុ និងបញ្ជីវត្តមានអង្គប្រជុំ (អាចធ្វើឡើងជាភាសារអង់គ្លេសផងដែរ ) ជាពិសេស របាយការណ៍សង្ខេបស្តីពីស្ថានភាពបើកផ្តល់សាច់ប្រាក់របស់ក្រសួងស្ថាប័ននានា ដែលអនុវត្តកម្មវិធីសកម្មភាពអាទិភាព ជូនដៃគូអ្នកផ្តល់ជំនួយដែលពាក់ព័ន្ធនានា ។
- សមាជិកក្រុមការងារអាចអញ្ជើញមន្ត្រីជំនាញរបស់ខ្លួនអមជាមួយ ក្នុងកិច្ចដំណើរការប្រជុំ ។

<u>ប្រការ៥</u>: យោងតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អាណត្តិរបស់ក្រុមដឹកនាំការងាររៀបចំពិនិត្យកែលំអកម្មវិធីសកម្មភាពអាទិភាព និង បើកផ្តល់សាច់ប្រាក់ មានរយៈពេល មិនតិចជាង ២ ឆ្នាំ។

<u>ប្រការ៦</u>: ប្រកាសអន្តរក្រសួងលេខ ០០២ សហវ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ២០០៥ ស្តីពីការបង្កើតក្រុមដឹកនាំការងារបើកផ្តល់សាច់ប្រាក់ដល់កិច្ចអភិវឌ្ឍន៍វិស័យសង្គម ត្រូវនិរាករណ៍ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

<u>ប្រការ៧</u>: អគ្គលេខាធិការ អគ្គនាយក ខុទ្ទកាល័យ គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ក្រសួងការងារ និង បណ្តុះបណ្តាល វិជ្ជាជីវៈ និង ក្រសួងកិច្ចការនារី និង ឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ១ និង ប្រការ២ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

លី_ឡាយស្រេង

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិត កុល ផេង

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី
នគរូបនីយកម្ម និង សំណង់

អ៊ឹម ឈុនលឹម

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

វេជ្ជ. នុត_សុខុម

រដ្ឋមន្ត្រីក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និង នេសាទ

ជ័រ សារុន

រដ្ឋមន្ត្រី
ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

ញ៉េប ប៊ុនជិន

រដ្ឋមន្ត្រី
ក្រសួងកិច្ចការនារី

អ៊ឹង កន្ថាផាវី

<u>ចំលងជូន</u>

- គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា
- គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសុខាភិបាល
- គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងអភិវឌ្ឍន៍ជនបទ
- គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងកិច្ចការនារី
- ដូចប្រការ១ និងប្រការ២
- ឯកសារ និង កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ....០០៤....សហវ.....

**គណៈកម្មការអន្តរក្រសួង**

# សេចក្តីណែនាំ
# ស្តីពី
# ការប្រព្រឹត្តិទៅ និងភារកិច្ចរបស់គណៈកម្មការបណ្តឹងតវ៉ា ក្រោមគំរោងអភិវឌ្ឍន៍នានា

កន្លងមក គណៈកម្មការអន្តរក្រសួងទទួលបន្ទុកដោះស្រាយផលប៉ះពាល់បានសង្កេតឃើញថា ការអនុវត្តនីការងារបណ្តឹងតវ៉ារបស់គណៈកម្មការបណ្តឹងតវ៉ាក្រោមគំរោងអភិវឌ្ឍន៍នីមួយៗ មានលក្ខណៈខុសគ្នា ដោយគំរោងខ្លះមានពាក្យបណ្តឹងច្រើន គំរោងខ្លះមិនសូវមានពាក្យបណ្តឹង និងគំរោងខ្លះទៀតមានពាក្យបណ្តឹងក្រោយថ្ងៃផុតកំណត់ដែលបានកំណត់នៅក្នុងសៀវភៅផែនការ សកម្មភាពសំរាប់ការតាំងទីលំនៅឡើងវិញ ។ ទាំងនេះបញ្ជាក់ថា ការអនុវត្តនីការងារបណ្តឹងតវ៉ាក្រោមគំរោងមួយចំនួន ពុំសូវមានភាពរលូនឆ្លើយតបទៅនឹងតំរូវការរបស់ស្ថាប័នផ្តល់ជំនួយដែលជារឿយៗបានស្នើអោយគណៈកម្មការអន្តរក្រសួងធ្វើការកំណត់អំពីការប្រព្រឹត្តិទៅ និងភារកិច្ចរបស់គណៈកម្មការបណ្តឹងតវ៉ានេះ ។ ដូច្នេះ ដើម្បីឆ្លើយតបជាវិជ្ជមានទៅនឹងសំណូមពររបស់ភ្នាក់ងារផ្តល់ជំនួយ និងក្នុងគោលបំណងជំរុញអោយការអនុវត្តនីការងារបណ្តឹងតវ៉ាប្រព្រឹត្តិទៅបានដោយរលូននោះ គណៈកម្មការអន្តរក្រសួង សូមធ្វើការណែនាំដូចខាងក្រោម:

## ១- សមាសភាព និងភារកិច្ចរបស់គណៈកម្មការបណ្តឹងតវ៉ា

តាមការអនុវត្តនីជាក់ស្តែងនៃគំរោងអភិវឌ្ឍន៍ទាំងឡាយ មានប្រជាពលរដ្ឋមួយភាគធំពេញចិត្តនឹងគោលការណ៍ផ្តល់ប្រាក់សំណងដែលបានកំណត់ដោយទីប្រឹក្សាអន្តរជាតិខាងការងារដោះស្រាយផលប៉ះពាល់ និងការតាំងទីលំនៅឡើងវិញ តែក៏នៅមានប្រជាពលរដ្ឋមួយចំនួនតូចនៅតែចង់អោយមានគោលការណ៍ផ្តល់ប្រាក់សំណងខ្ពស់ជាង ។ ដូច្នេះ គណៈកម្មការបណ្តឹងតវ៉ា ត្រូវបានបង្កើតឡើងដើម្បីទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ ដែលមិនយល់ព្រមនឹងគោលការណ៍ផ្តល់ប្រាក់សំណង និងសិទ្ធិទទួលប្រាក់សំណងដែលកំណត់ដោយលទ្ធផលនៃការវាស់វែងរបស់ក្រុមការងារគណៈកម្មការអន្តរក្រសួង ។ គណៈកម្មការបណ្តឹងតវ៉ានេះ ត្រូវបានបង្កើតឡើងដោយសមាសភាពដូចខាងក្រោម:

| | |
|---|---|
| ក- អភិបាលខេត្ត | ជាប្រធាន |
| ខ- អភិបាលរងទី ១ ខេត្ត | ជាអនុប្រធាន |
| គ- ប្រធាន ឬអនុប្រធានមន្ទីរនៃក្រសួងពាក់ព័ន្ធ | ជាអនុប្រធាន |
| ឃ- ប្រធាន ឬអនុប្រធានការិយាល័យទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ង- ប្រធាន ឬអនុប្រធានការិយាល័យព្រហ្មទ័ណ្ឌកិរតស្រាលនៃស្នងការខេត្តដែលពាក់ព័ន្ធ | ជាសមាជិក |



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ច- ប្រធាន ឬអនុប្រធានសេនាធិការកងរាជអាវុធហត្ថខេត្តដែលពាក់ព័ន្ធ ជាសមាជិក

ឆ- អភិបាលស្រុកដែលពាក់ព័ន្ធ ជាសមាជិក

ជ- មេភូមិ មេឃុំ នៃភូមិ ឬឃុំដែលពាក់ព័ន្ធ ជាសមាជិក

ឈ- តំណាងអង្គការក្រៅរដ្ឋាភិបាល ជាសមាជិក

គណៈកម្មការនេះ មានភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោមៈ

- ណែនាំ និងពន្យល់ប្រជាពលរដ្ឋដែលរងនូវផលប៉ះពាល់ អោយយល់ពីដំណើរការនៃការរៀបចំសៀវភៅផែនការ សកម្មភាពសំរាប់ការតាំងទីលំនៅឡើងវិញរបស់ប្រជាពលរដ្ឋដែលរងនូវផលប៉ះពាល់ និងជ្រាបពីពេលវេលាសំរាប់អនុវត្តផែនការ សកម្មភាពសំរាប់ការតាំងទីលំនៅឡើងវិញរបស់ពួកគាត់ ។
- ណែនាំ និងពន្យល់ប្រជាពលរដ្ឋដែលរងនូវផលប៉ះពាល់ អោយយល់ពីគោលនយោបាយសំរាប់កំណត់សិទ្ធិទទួលប្រាក់សំណង ។
- ណែនាំ និងពន្យល់ប្រជាពលរដ្ឋដែលរងនូវផលប៉ះពាល់ អោយយល់ពីខ្លឹមសារនៃការប្តឹងតវ៉ាស្របតាមសៀវភៅផែនការ សកម្មភាពសំរាប់ការតាំងទីលំនៅឡើងវិញ ដែលបានរៀបចំឡើងដោយទីប្រឹក្សាជំនាញខាងការងារដោះស្រាយផលប៉ះពាល់ និងការតាំងទីលំនៅឡើងវិញ ។
- ទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ និងធ្វើការដោះស្រាយបញ្ហាក្នុងរយៈពេលដូចមានកំណត់ក្នុងចំនុច **២** និងចំនុច **៣** នៃសេចក្តីណែនាំនេះ ។
- ធ្វើការកត់ត្រាបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋរងនូវផលប៉ះពាល់ និងបែងចែកតាមប្រភេទអាទិភាពសំរាប់ដោះស្រាយ ។
- ធ្វើរបាយការណ៍ជារៀងរាល់ពីរ (២) សប្តាហ៍ម្តង ស្តីពីការវិវត្តន៍របស់គណៈកម្មការបណ្តឹងតវ៉ាទាក់ទងនឹងស្ថានភាពជាក់ស្តែងរបស់ប្រជាពលរដ្ឋដែលរងនូវផលប៉ះពាល់ ទោះជាប្រជាពលរដ្ឋរងនូវផលប៉ះពាល់ដោយសារគំរោងមិនមានប្តឹងតវ៉ាក៏ដោយ ។
- ចាប់ទទួលពាក្យបណ្តឹងនៅក្នុងសប្តាហ៍ទីមួយរហូតដល់សប្តាហ៍ទីបួន បន្ទាប់ពីការបញ្ចប់ទូទាត់ប្រាក់សំណង

**២- ដំណើរការនៃការអនុវត្តន៏ការងាររបស់គណៈកម្មការបណ្តឹងតវ៉ា**

ក្នុងករណីប្រជាពលរដ្ឋដាក់ពាក្យបណ្តឹងតាមរយៈអង្គការត្រួតពិនិត្យឯករាជ្យ ដោយហេតុផលថា ពួកគាត់មិនអាចទាក់ទងសមាជិកនៃគណៈកម្មការបណ្តឹងតវ៉ាបាន គណៈកម្មការបណ្តឹងតវ៉ាត្រូវរៀបចំទទួលពាក្យបណ្តឹងនេះ និងធ្វើការដោះស្រាយ ដោយផ្អែកតាមខ្លឹមសារដូចបានចែងក្នុងសៀវភៅផែនការ សកម្មភាពសំរាប់ការតាំងទីលំនៅថ្មី ។ ជារួមដំណើរការនៃការអនុវត្តន៏ការងាររបស់គណៈកម្មការបណ្តឹងតវ៉ា មានដូចខាងក្រោមៈ

- ជាដំបូង ប្រជាពលរដ្ឋ ធ្វើការប្តឹងតវ៉ាទៅក្រុមការងាររបស់គណៈកម្មការអន្តរក្រសួង និងអនុគណៈកម្មការខេត្ត មេភូមិ មេឃុំ ឬ តំណាងអង្គការក្រៅរដ្ឋាភិបាល ។ ក្នុងរយៈពេល ១៥ ថ្ងៃ បញ្ហាមិនអាចដោះស្រាយបាន ពាក្យបណ្តឹងត្រូវបានបញ្ជូនទៅការិយាល័យស្រុក/ខ័ណ្ឌ ដើម្បីពិនិត្យ និងដោះស្រាយ ។
- ក្នុងរយៈពេល ១៥ ថ្ងៃ ប្រសិនបើបញ្ហាមិនអាចដោះស្រាយបាន ការិយាល័យស្រុក/ខ័ណ្ឌ ត្រូវបញ្ជូនពាក្យបណ្តឹងទៅគណៈកម្មការបណ្តឹងតវ៉ាថ្នាក់ខេត្ត ដើម្បីពិនិត្យ និងដោះស្រាយ ។

2

- ក្នុងរយៈពេល ៣០ ថ្ងៃ បើបញ្ហាមិនអាចដោះស្រាយបាន គណៈកម្មការបណ្តឹងតវ៉ាថ្នាក់ខេត្ត នឹងបញ្ជូនសំណុំរឿងតវ៉ាទៅតុលាការខេត្ត-ក្រុង ដែលគំរោងអភិវឌ្ឍន៍ស្ថិតនៅ ដើម្បីធ្វើសេចក្តីសំរេចចុងក្រោយ ។

## ៣- រចនាសម្ព័ន្ធនៃការបណ្តឹងតវ៉ា



**៤- ថវិកាសំរាប់ដំណើរការនៃគណៈកម្មការបណ្តឹងតវ៉ា**

ថវិកាសំរាប់ប្រើប្រាស់ក្នុងដំណើរការបណ្តឹងតវ៉ា ត្រូវបានផ្តល់នៅពេលដែលមានពាក្យបណ្តឹងពីប្រជាពលរដ្ឋ តែបើគ្មានបណ្តឹងកើតឡើង គ្រប់សមាជិកនៃគណៈកម្មការបណ្តឹងតវ៉ា ក៏ត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃតាមគោលនយោបាយដែលបានកំណត់ផងដែរ ។ រាល់ការចំណាយត្រូវរៀបជាសំណើ ដោយភ្ជាប់មកជាមួយនូវវិក័យប័ត្រចំណាយ ។ សំណើសុំថវិកានេះ ត្រូវចុះហត្ថលេខាដោយប្រធានគណៈកម្មការបណ្តឹងតវ៉ា ។

បន្ទាប់ពីបានទទួលនូវសេចក្តីណែនាំនេះ គណៈកម្មការបណ្តឹងតវ៉ាក្រោមគំរោងអភិវឌ្ឍន៍នីមួយៗ ត្រូវអនុវត្តអោយបានត្រឹមត្រូវ ប្រកបដោយប្រសិទ្ធិភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ ២០០៦

**ប្រធានគណៈកម្មការអន្តរក្រសួង**

**រដ្ឋលេខាធិការ**

**វិវណ្ណ ឡេង**

ចំលងជូន

- គ្រប់ក្រសួងពាក់ព័ន្ធ
- គ្រប់អង្គភាព Resettlement
- សមាជិកគណៈកម្មការបណ្តឹងសារទុក្ខ
- ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry, Mines and Energy**
N°៧៨១ ឧរម.គរ-ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៧ខែ មិថុនា ឆ្នាំ២០០៦

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ២១៥៩/០៦ ត.វ.ក ចុះថ្ងៃទី០៧.០៦.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ហ្វ័រឈូន ហ្វេសិន លីមីធីត ចុះថ្ងៃទី០១.០៦.២០០៦

## សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ហ្វ័រឈូន ហ្វេសិន លីមីធីត( FORTUNE FASHIONS LIMITED.)តំណាងដោយ លោក តាំង ម៉េង សញ្ជាតិខ្មែរ អាយុ២២ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ 010356949 ចុះថ្ងៃទី២៧.០៩.២០០២ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "ហ្វ័រឈូន ហ្វេសិន លីមីធីត ( FORTUNE FASHIONS LIMITED. )"មានទីតាំងស្ថិតនៅ ភូមិទូលពង្រ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវផ្តល់ប្លង់គ្រឿងចក្រ-ម៉ាស៊ីន មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុ
រយៈពេលយ៉ាងយូរ ពីរខែ ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាព
ផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ
ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូ
សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់
និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត
ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះប្រការ
ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ
និងប្រធានក្រុមហ៊ុន ហ្វ៉ូរឈួន ហ្វេសិន លីមីធីត ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ឧ.រដ្ឋមន្ត្រី

ជួរលេខាធិការ

អ៊ិត-ប្រាំង

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N°៦៨៧ ឧរថ.កឧ.ប្រក.

រាជធានីភ្នំពេញ. ថ្ងៃទី២៧ខែមិថុនា ឆ្នាំ២០០៦

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ២០៦០/០៦ គ.វ.ក ចុះថ្ងៃទី ២៩.០៥.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន វេយ ជា ចុះថ្ងៃទី០២.០៥.២០០៦

## សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន វេយ ជា (WEI JIA CO., LTD.) តំណាងដោយលោក ZHANG WEI សញ្ជាតិចិន អាយុ២៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G00195182 ចុះថ្ងៃទី២៥.០៩.២០០០ បង្កើតរោងចក្រ "ផលិតប្រដាប់ព្យួរសម្លៀកបំពាក់" ដែលមានឈ្មោះថា " វេយ ជា ( WEI JIA )" មានទីតាំងស្ថិតនៅ ភូមិឫស្សីសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ហើយក្រុមហ៊ុនត្រូវផ្តល់លិខិតអនុញ្ញាតសាងសង់មកក្រសួង ក្នុងរយៈពេល២ខែ យ៉ាងយូរ ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "ផលិតប្រដាប់ព្យួរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន វេយ ជា ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ទី- រដ្ឋមន្ត្រី

ដូរសេខាធិការ

អ៊ិត-ប្រាំង

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N°៦៨៣ ឧ.ម.ក.ឧ.-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ០០២ អ.គ.វ.ខ/កស្ព/០៦ ចុះថ្ងៃទី២២.០៣.២០០៦ របស់អនុគណៈកម្មាធិការវិនិយោគខេត្តកំពង់ស្ពឺ
- យោងពាក្យស្នើរបស់ក្រុមហ៊ុន យុន ហ្វុង ប៊ីលឌីង មេធៀរៀល ខមភេនី អិលធីឌី ចុះថ្ងៃទី២៥.០៥.២០០៦

## សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន យុន ហ្វុង ប៊ីលឌីង មេធៀរៀល ខមភេនី អិលធីឌី (RUNFRONT BUILDING MATERIALS COMPANY LTD.) តំណាងដោយលោក YUAN CANXI សញ្ជាតិចិន អាយុ៦២ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G08685692 ចុះថ្ងៃទី២៧.០៩.២០០៣ បង្កើតរោងចក្រ "ផលិតស៊ីម៉ងត៍ពីផលិតផលពាក់កណ្តាលសំរេច" ដែលមានឈ្មោះថា " យុន ហ្វុង ប៊ីលឌីង មេធៀរៀល ខមភេនី អិលធីឌី ( RUNFRONT BUILDING MATERIALS COMPANY LTD.)" មានទីតាំងស្ថិតនៅ គីឡូម៉ែត្រលេខ៦៨ ផ្លូវជាតិលេខ៤ ភូមិត្រពាំង អត់ទឹក ឃុំគីរីវន្ត ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 Fax . 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវផ្តល់ប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងរយៈពេលយ៉ាងយូរ ២ខែ ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ"ផលិតស៊ីម៉ង់ត៍ពីផលិតផលពាក់កណ្តាលសំរេច"ហើយត្រូវធ្វើរបាយការណ៍ ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះនឹងប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកំពង់ស្ពឺ និងប្រធានក្រុមហ៊ុន យុន ហ៊ុង ប៊ីលឌីង មេធៀរៀល ខមភេនី អិលធីឌី ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ស.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

អ៊ិត-ប្រាំង

ចម្លងជូន :

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្តកំពង់ស្ពឺ

" ដើម្បីជូនជ្រាប "

-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ៧៨៤ ឧ.ប.ករ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ ២០០៦

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ន.ស/ រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ២០៦២/០៦ គ.វ.ក ចុះថ្ងៃទី២៩.០៥.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន កូវ៉ា អ៊ិនវេសមេន អ៊ិនធើណេសិនណល (ខេមបូឌា) ចុះថ្ងៃទី២៦.០៤.២០០៦

## សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន កូវ៉ា អ៊ិនវេសមេន អ៊ិនធើណេសិនណល (ខេមបូឌា) ( KOVA INVESTMENT INTERNATIONAL (CAMBODIA) CO., LTD.) តំណាងដោយ លោកស្រី NGUYEN THI HOE សញ្ជាតិវៀតណាម អាយុ៦០ឆ្នាំ កាន់លិខិតឆ្លងដែនលេខ A1385553B ចុះថ្ងៃទី២១.១០.២០០៤ បង្កើតរោងចក្រ "ថ្នាំលាប កុងតាក់ភ្លើង និង ទ្វារដែកអូតូ" ដែលមានឈ្មោះថា "កូវ៉ា អ៊ិនវេសមេន អ៊ិនធើណេសិនណល (ខេមបូឌា) ( KOVA INVESTMENT INTERNATIONAL (CAMBODIA))" មានទីតាំងស្ថិតនៅ ភូមិតាបឺប ឃុំបាវិត ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 Fax . 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវផ្តល់ប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល យ៉ាងយូរ ពីរខែ ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "ផលិតថ្នាំលាប កុងតាក់ភ្លើង និងទ្វារដែកអូតូ" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧ : ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តស្វាយរៀង និងប្រធានក្រុមហ៊ុន កូវ៉ា អ៊ិនវេសមេន អ៊ិនធើណេសិនណល (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ - សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្តស្វាយរៀង
" ដើម្បីជូនជ្រាប "
- ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ១៤៨៥ ឧរ៉ថ.ករ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០០៦

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ២០៩៤/០៦ គ.វ.ក ចុះថ្ងៃទី ៣១.០៥.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ចុះថ្ងៃទី ២៣.០៥.២០០៦

## សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ( CAMBO HANDSOME LTD.) តំណាងដោយ លោក LEE SIN JAE សញ្ជាតិកូរ៉េ អាយុ៤៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ TM 0638102 ចុះថ្ងៃទី០៩.០២.២០០៤ **បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ "** ដែលមានឈ្មោះថា **" ខេមបូ ហ៊ែនសាំ អិលធីឌី** (CAMBO HANDSOME LTD. )" មានទីតាំងស្ថិតនៅ ភូមិអង្គកែវ ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax . 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុន ត្រូវផ្តល់លិខិតអនុញ្ញាតសាងសង់ និង ប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងរយៈពេល ២ខែ យ៉ាងយូរ ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និងប្រធានក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ឧត្តមាធិការ

ស៊ុយ-សែម

ចម្លងជូន :

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្តកណ្តាល

" ដើម្បីជូនជ្រាប "

-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

លេខ ៧៩០ ស.អ.យ.

លិខិតចូល ថ្ងៃទី ២១ ខែ ៧ ឆ្នាំ 2006

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៦

# ប្រកាស
## ស្តីពីការបង្កើតមជ្ឈមណ្ឌលជីវិតថ្មីផ្តាច់របស់
## មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបន្ទាយមានជ័យ
## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី.
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា.
- បានឃើញព្រះរាជក្រមលេខ / នស.រកម / ០១៩៧ / ០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន.
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា.
- បានឃើញប្រកាសលេខ ៣៥៩ សអយ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត-ក្រុង.
- ពិនិត្យតាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១ :** បង្កើតមណ្ឌលមណ្ឌល **ជីវិតថ្មីផ្តាច់** អោយស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបន្ទាយមានជ័យ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាឈ្មោះថា **ជីវិតថ្មីផ្តាច់** ខេត្តបន្ទាយមានជ័យ ។

**ប្រការ២ :** ប្រធានមជ្ឈមណ្ឌលជីវិតថ្មីផ្តាច់របស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តបន្ទាយ-មានជ័យ មានឋានៈស្មើអនុប្រធានការិយាល័យនៃមន្ទីរខេត្ត-ក្រុង និងមានអនុប្រធានមួយចំនួនជាជំនួយការ ដែលមានឋានៈស្មើអនុប្រធានការិយាល័យស្រុក-ខណ្ឌ ។

**ប្រការ៣ :** នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គ-

នាយកដ្ឋានបច្ចេកទេស ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ប្រធាននាយកដ្ឋានយុវនីតិសម្បទា ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-បន្ទាយមានជ័យ និងប្រធានមជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់មានភារកិច្ចរៀង១ខ្លួន អនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**អ៊ិត សំហេង**

<u>**ចម្លងជូន**</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឆៀ ឆាញ់
- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- សាលាខេត្តបន្ទាយមានជ័យ " ដើម្បីជូនជ្រាប "
- ដូចប្រការ៣" ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

## អង្គការលេខមជ្ឈមណ្ឌលជីវិតថ្មីភ្លឺបាក់នៅថ្នាក់ខេត្ត
## ដែលស្ថិតក្រោមឱវាទរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
## ខេត្តបន្ទាយមានជ័យ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
លេខ ៧៩១ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០០៦

លិខិតចូល
ថ្ងៃទី...២១...ខែ...មិថុនា...ឆ្នាំ2006

**ប្រកាស**

**ស្តីពី**

**ការរៀបចំ និងការប្រព្រឹត្តិទៅរបស់មជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់**
**របស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបន្ទាយមានជ័យ**
**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី.
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា.
- បានឃើញព្រះរាជក្រមលេខ / នស.រកម / ០១៩៧ / ០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន.
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា.
- បានឃើញប្រកាសលេខ ៣៥៩ សអយ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត-ក្រុង.
- បានឃើញប្រកាសលេខ ៧៩០ សអយ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការបង្កើតមជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់.

**សម្រេច**

**ប្រការ១ :** ប្រកាសនេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់មជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់ ដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្តបន្ទាយមានជ័យ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។ មជ្ឈមណ្ឌលនេះមានតួនាទី ទទួលយកអ្នកញៀនគ្រឿង

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone (855) 23 726 086

ញៀន គ្រប់វ័យ គ្រប់ភេទ មកគ្រប់គ្រង ព្យាបាល អប់រំបណ្តុះបណ្តាល និង សមាហរណកម្មទៅក្នុងសហគមន៍វិញ ។

**ប្រការ២ :** មជ្ឈមណ្ឌលនេះមានតួនាទី និងភារកិច្ចដូចតទៅ :

**ក. ការទទួល និងគ្រប់គ្រង :**

- សហការជាមួយអាជ្ញាធរដែនដី អង្គភាពមានសមត្ថកិច្ច មាតាបិតា អាណាព្យាបាល អង្គការមិនមែនរដ្ឋាភិបាល ទទួលយកជនរងគ្រោះទាំងពីរភេទ ដូចមានចែងក្នុងប្រការ១ មកគ្រប់គ្រង ។
- លើកសំណើទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីសុំទទួលយក អ្នកញៀនគ្រឿងញៀន មកព្យាបាល និងស្តារនីតិសម្បទា
- ធ្វើកោសល្យវិច័យ ពិគ្រោះយោបល់ បំពេញទំរង់បែបបទឯកសារពាក់ព័ន្ធសាមីខ្លួន
- រៀបចំការស្នាក់នៅរបស់ជនរងគ្រោះតាមវ័យ តាមភេទ និងតាមប្រភេទបញ្ហា
- រៀបចំបទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌល ស្របតាមបទបញ្ញត្តិផ្សេងៗរបស់រដ្ឋ ដោយមានការឯកភាពពីក្រសួង.

**ខ. ការងារព្យាបាលស្តារនីតិសម្បទា និងធ្វើសមាហរណកម្ម :**

- ព្យាបាល ថែទាំសុខភាព ផ្តត់ផ្គង់ជីវភាព តាមរបបកំណត់របស់មជ្ឈមណ្ឌល និងជំនួយឧបត្ថម្ភពីមជ្ឈដ្ឋាននានា.
- ផ្តល់ប្រឹក្សា
- ផ្តល់ការអប់រំសីលធម៌ សុខភាព ផ្លូវចិត្ត បំណិនជីវិត
- បណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈស្របទៅតាមទីផ្សារការងារ ក្រោយពីអ្នកញៀនគ្រឿងញៀនមានភាពធូរស្បើយ.
- រៀបចំសកម្មភាព ហាត់ប្រាណ វប្បធម៌ សិល្បៈ កីឡា និងការកំសាន្តផ្សេងៗ
- ត្រួតពិនិត្យ តាមដានដំណើការវិវត្តរបស់ជនរងគ្រោះ នៅក្នុងមជ្ឈមណ្ឌល
- ផ្តល់លិខិតទទួលស្គាល់មុខជំនាញពេលប្រឡងបញ្ចប់វគ្គ
- លើកសំណើសុំធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀនដែលបានជាសះស្បើយ ទៅក្រុមគ្រួសារ អាណាព្យាបាល និងសហគមន៍វិញ.
- ទំនាក់ទំនងជាមួយក្រុមគ្រួសារ អាណាព្យាបាល ដើម្បីទទួលយកជនរងគ្រោះត្រឡប់ទៅក្រុមគ្រួសារ និងសហគមន៍វិញ.
- រៀបចំបែបបទបញ្ជូនជនរងគ្រោះទៅក្រុមគ្រួសារ អាណាព្យាបាល និងសហគមន៍វិញ.

**ប្រការ៣ :** មជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់របស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបន្ទាយមានជ័យ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាត្រូវបានដឹកនាំ ដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

**មជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់ មានរចនាសម្ព័ន្ធដូចតទៅ :**

១- ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ.

២- ផ្នែកទទួល និងគ្រប់គ្រង.

៣- ផ្នែកព្យាបាលស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន.

ផ្នែកនីមួយៗដឹកនាំដោយប្រធានមួយរូប និងអនុប្រធានពីររូបជាជំនួយការ ។

***តួនាទី និងភារកិច្ចរបស់ផ្នែកនីមួយៗ មានដូចខាងក្រោម :***

**១- ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ :**

***ជាជំនួយការរបស់មណ្ឌល ទទួលបន្ទុក :***

- លិខិតចេញ-ចូល
- ការងារតំកល់ឯកសារ
- រៀបចំកាលវិភាគប្រចាំថ្ងៃ
- រៀបចំសន្តិសុខ សណ្តាប់ធ្នាប់ នៅក្នុងមជ្ឈមណ្ឌល
- កសាងលិខិតរដ្ឋបាលផ្សេងៗ
- ពិធីការ អនាម័យ
- បូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- មន្ត្រីបុគ្គលិក ជីវប្រវត្តិ
- គ្រប់គ្រងសំភារៈបរិក្ខារ ចលនទ្រព្យ អចលនទ្រព្យ របស់មជ្ឈមណ្ឌល
- ថវិកា បៀវត្ស មន្ត្រីបុគ្គលិក
- ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ របស់មជ្ឈមណ្ឌល
- ធ្វើគំរោងថែទាំ ជួសជុលអាគារ មធ្យោបាយដឹកជញ្ជូន និងសំភារៈផ្សេងៗ
- ធ្វើរបាយការណ៍ ការប្រើប្រាស់ថវិកាតាមកាលកំណត់ ។

**២- ផ្នែកទទួល និងគ្រប់គ្រង :**

***ជាជំនួយការរបស់មណ្ឌល ទទួលបន្ទុក :***

- គ្រប់គ្រងស្ថិតិអ្នកញៀនគ្រឿងញៀន
- អនុវត្តន៍បែបបទទទួល
- ធ្វើកោសល្យវិច័យ សាកសួរកត់ត្រាជីវប្រវត្តិ
- បែងចែកសំលៀកបំពាក់ និងការស្នាក់នៅ តាមដំណាក់កាល វ័យ ភេទ
- ត្រួតពិនិត្យដំណើរការវិវឌ្ឍន៍របស់អ្នកញៀនគ្រឿងញៀន ។

**៣- ផ្នែកព្យាបាលស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន :**

***ជាជំនួយការរបស់មជ្ឈមណ្ឌល ទទួលបន្ទុក :***

- ផ្តល់ប្រឹក្សា ពិគ្រោះយោបល់
- រៀបចំកម្មវិធីព្យាបាលសុខភាព បន្សាបជាតិពុល
- រៀបចំសកម្មភាព ហាត់ប្រាណ
- អនុវត្តកម្មវិធីសិក្សា អប់រំសីលធម៌ អប់រំសុខភាព អប់រំច្បាប់ និងផលប៉ះពាល់ នៃការប្រើប្រាស់បំពាន

គ្រឿងញៀន.

- បណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ
- បែងចែកការសិក្សា និងបំពាក់បំប៉ននិវិន័យសិក្សាក្រៅប្រព័ន្ធ
- គ្រប់គ្រងបណ្ណាល័យ ថ្នាក់រៀន រោងជាង
- រៀបចំកម្មវិធីសំរួលដល់គ្រូ និងអ្នកឯកទេសផ្សេងៗ
- រៀបចំសកម្មភាព វប្បធម៌ សិល្បៈ កីឡា និងសាសនា
- ធ្វើរបាយការណ៍អំពីការសិក្សា និងការបង្ហាត់បង្រៀន
- រៀបចំការប្រលងបញ្ចប់វគ្គ និងផ្តល់លិខិតបញ្ជាក់ការសិក្សា
- លើកសំណើធ្វើសមាហរណកម្ម
- សម្របសម្រួលការងារធ្វើសំរាប់អ្នកញៀនគ្រឿងញៀន ដែលបានធ្វើសមាហរណកម្ម
- ត្រួតពិនិត្យ តាមដាន និងអន្តរាគមន៍អ្នកញៀនគ្រឿងញៀន ដែលបានសមាហរណកម្មទៅក្នុងសហគមន៍

**ប្រការ៤ :** នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ប្រធាននាយកដ្ឋានយុវនីតិសម្បទា ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តបន្ទាយមានជ័យ និងប្រធានមជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់មានភារកិច្ចរៀងៗខ្លួន អនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ខៀវ ចាញ់**
- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- សាលាខេត្តបន្ទាយមានជ័យ " ដើម្បីជូនជ្រាប "
- ដូចប្រការ៣" ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ៣៦៥ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៦

# ប្រកាស

## ស្តីពី

## របបឧបត្ថម្ភសំរាប់មណ្ឌលជីវិតថ្មីភ្នំបាត់

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១០៥/០០១ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៥អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញប្រកាសលេខ ៣៥៩ ស.អ.យ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-ក្រុង
- បានឃើញប្រកាសលេខ ២៥០ ស.អ.យ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការបង្កើតមជ្ឈមណ្ឌល ជីវិតថ្មីភ្នំបាត់
- បានឃើញប្រកាសលេខ ២៥១ ស.អ.យ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជីវិតថ្មីភ្នំបាត់
- បានឃើញសេចក្តីសំរេចលេខ ៥៥ សសរ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩២ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការកែសំរួលនិងបំពេញបន្ថែមប្រាក់ឧបត្ថម្ភចំពោះទារកកំព្រា កុមារកំព្រា ជនជរាពិការ ស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ

- ពិនិត្យ.ឃើញការចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១.~** ប្រកាសនេះ មានគោលបំណងកំណត់អំពីរបបឧបត្ថម្ភ ប្រចាំថ្ងៃ សំរាប់មជ្ឈមណ្ឌល **ជីវិតថ្មីភ្នំបាក់** ។

**ប្រការ ២.~** មជ្ឈមណ្ឌល **ជីវិតថ្មីភ្នំបាក់** ត្រូវអនុវត្តរបបឧបត្ថម្ភប្រចាំថ្ងៃ តាមសេចក្តីសំរេចលេខ ៥៥ សសរ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩២ របស់ក្រុមប្រឹក្សា រដ្ឋមន្ត្រី ស្តីពីការកែសំរួលនិងបំពេញបន្ថែម ប្រាក់ឧបត្ថម្ភចំពោះទារកកំព្រា កុមារកំព្រា ជនជរាពិការ ស្នាក់នៅក្នុងមជ្ឈមណ្ឌលសង្គ្រោះ របស់រដ្ឋ ។

**ប្រការ ៣.~** មជ្ឈមណ្ឌល**ជីវិតថ្មីភ្នំបាក់** អាចទទួលយកវិភាគទាន ពីក្រុមគ្រួសារ ឬអ្នកអាណាព្យាបាលនៃជនរងគ្រោះទៅតាមលទ្ធភាព ដើម្បីជាប្រយោជន៍ដល់ដំណើរការ និងអភិវឌ្ឍន៍មណ្ឌល ។

**ប្រការ ៤.~** មន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តបន្ទាយមានជ័យ មានភារកិច្ចគ្រប់គ្រងការប្រើប្រាស់ថវិកានេះ តាមបទប្បញ្ញត្តិជាធរមាន និងដោយតម្លាភាព ។

**ប្រការ ៥.~** នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋាន បច្ចេកទេស ប្រធាននាយកដ្ឋាន ហិរញ្ញវត្ថុនិងផ្គត់ផ្គង់ ប្រធាននាយកដ្ឋានយុវនីតិសម្បទា ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត បន្ទាយមានជ័យ និងប្រធានមជ្ឈមណ្ឌល ជីវិតថ្មីភ្នំបាក់ មានភារកិច្ចរៀង១ខ្លួន អនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងការពារជាតិ
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងយុត្តិធម៌
-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **នៀ ឆាញ់**
-អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
-សាលាខេត្តបន្ទាយមានជ័យ "ដើម្បីជូនជ្រាប"
-ដូចប្រការ៥ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ